ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៨ ខែមករា លេខ ១ ព.ស. ២៤៩៨ គ.ស. ១៩៥៦

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

### ផ្នែកសាសនា

ទំព័រ

— ជយកថា . . . . . . . . . . . . . . ព្រះឧបាលិវង្ស សួរ-បាយ . . . . ៣
— ជិតពេកមើលមិនឃើញ . . . . . . . . . យុនបណ្ណានុរ័ក្ស ប៊ូ-ប៉ូ . . . . ១៩
— បញ្ញាសជាតក ភាគទី ៤ (តមក) . . . បណ្ឌិតមហា ឈឹម-ស៊ុមន៍ . . . ២៤

### ផ្នែកអក្សរសាស្ត្រ

— ពេជ្រព្រះរាជា . . . . . . . . . . . លោក ស៊ិន-ហ៊ាន . . . . . . . ៣៤
— រឿងភ្នំសំពៅនៅខែត្របាត់ដំបង . . . . អ្នកស្រី សារិះយ៉ាន . . . . . . . ៤៥
— រឿងសាមកុក (តមក) . . . . . . . . នាកញ៉ា នូ-កន . . . . . . . . ៥៣
— ដំណឹងតាមខ្យល់ក្នុងកន្តារៈ (តៈក) . . លោក ផេង-ជ្រីវ . . . . . . . ៦០
— រឿងបល្ល័ង្កទិព្យ (តមក) . . . . . . . លោក ភ៉ាយ-ប៊ុក . . . . . . . ៧១
— សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ . . លោក បាប-ពិន . . . . . . . ៧៨

### កំណត់និងប្រវត្តិការណ៍

— ពិធីអនុសំវច្ឆរៈមហាសន្និបាតលើកទី ១២
នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំ ១៩៥៦. . . . . . ពុទ្ធសាសនបណ្ឌិត្យ . . . . . . . ៨៩

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២៣០រ,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## *TABLE DES MATIÈRES*

### PARTIE RELIGIEUSE:

*Page*

— Jayakatha . . . . . . . . . . *Vên. SO-HAY* . . . . . . 3

— Tout ce qui se trouve trop près n'est pas visible . . . . . . . *M. BOU-PO* . . . . . . . 19

— Pannasajataka-vol. 4 (suite.) . *M. CHHIM-SOUM* . . . . 24

### PARTIE LITTERAIRE:

— Conte "Le Diamant du Raja" .. *M. SIN-HEAN* . . . . . 34

— Historique du Phnom-Sampeou *Mme SRIN-SARIS-YANN* . 45

— Histoire de SAMKOK (suite). . *Oknha NOU-KAN*. . . . . 53

— Le souffle du désert (suite) . *M. PHENG-CHRIV* . . . 60

— Les trente deux récits du TRONE (suite) . . . . . . . *M. RAY BUC*. . . . . . 71

— Activités de la Commission des Moeurs et Coutumes. . . . . . *M. CHAP-PIN* . . . . . 78

### NOTES ET CHRONIQUES:

—Réunion annuelle des dignitaires religieux pour l'année 1956 . . *Institut Bouddhique* . . . . . 89

Prix d'abonnement annuel (comprenant 12 numéros) 230$00

# ផ្នែកសាសនា

## ជយគាថា

ព្រះឧបាលិវង្ស ស៊ូរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក

*រៀបរៀង*

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ

ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។

*វេលានេះ សូមសំដែងអំពីពាក្យថា "ជ័យ" ដូចសេចក្តីអធិប្បាយតាមបាលីនិងអដ្ឋកថា តទៅនេះ ។*

*ពាក្យ "ជ័យ" ប្រែថា "ការឈ្នះឬជំនះ" ផ្ទុយគ្នា នឹងពាក្យ "បរាជ័យ" ដែលប្រែថា "ចាញ់" ។ អ្នកខ្លះដោយចូលចិត្តខុស យកពាក្យ "អបរាជ័យ" មកប្រើនិយាយក្នុងប្រយោគថា "ចាញ់" ទៅវិញ តាមដែលពិតនោះ "អបរាជ័យ" ប្រែថា "មិនចាញ់" បានសេចក្តីថា "ឈ្នះ" ដូចជាពាក្យថា "ជ័យ" ដែរ ។ ដំណើរនេះ សូមចាំឲ្យជាក់ថា* ជ័យ *"ការឈ្នះ"* បរាជ័យ *"ការចាញ់"* អបរាជ័យ *"មិនចាញ់គឺឈ្នះ" ។*

*ពួកបុថុជ្ជនភាគច្រើន សុទ្ធតែត្រូវការចង់បាននូវជ័យជំនះ មិនមាននរណាមួយបដិសេធបោលនូវជ័យជំនះឡើយ ។ ការឈ្នះមានច្រើន*

យ៉ាងគឺ ឈ្នះដោយចំបាំង, ដោយភោគសម្បត្តិ, ដោយល្បែងភ្នាល់ មានបៀរប៉ោជាដើម ។ អ្នកដែលចុះស្នាមក្នុងចំបាំង ឬក្នុងការភ្នាល់ សុទ្ធតែត្រូវការបង់ឈ្នះគេជាដរាប ខំរកឧបាយកលដើម្បីឲ្យបានតែខាងឈ្នះ ។

គូប្រណាំងប្រដែងតាំងពីម្នាក់ម្ខាងឡើងទៅ សុទ្ធតែប្រឹងប្រែងដោយកម្លាំងកាយនឹងកម្លាំងប្រាជ្ញា ប្រាជ្ញាដណ្តើមយកជ័យជំនះទាំងអស់គ្នា តែការឈ្នះនោះមានតែមួយ, បើអ្នកម្ខាងយកជ័យបាន, អ្នកម្ខាងក៏ត្រូវបាននូវបរាជ័យ គឺថា បើអ្នកឈ្នះមាន, អ្នកចាញ់ក៏មាន, បើមិនមានអ្នកឈ្នះ, អ្នកចាញ់ក៏មិនមានដែរ ។

មនុស្សលោកច្រើនដែលត្រូវការបង់បាននូវជ័យជំនះនោះ ព្រោះការឈ្នះរមែងបានកិត្តិសព្ទល្បីល្បាញផង បានសិទ្ធិអំណាចតេជះបរិបូណ៌ ខ្ពង់ខ្ពស់ ទាំងលាភយសសក្តិបរិវាររុងរឿងផង ។ ការឈ្នះរបស់ប្រជាជនក្នុងលោកនេះជាសភាវៈមិនទៀង តែងអណ្តែត តែងធ្លាក់ទៅលើពួកជនឯណោះម្តងឯណេះម្តង ឥតមានឋិតនៅក្នុងពួកជនមួយៗជាទៀងប្រាកដឡើយ គឺថា ជួនកាលជ័យជំនះទៅលើអ្នកនោះ, ជួនកាលមកនៅលើអ្នកនេះ ស្រេចនឹងឥទ្ធិពលរបស់មនុស្ស, បើអ្នកណាមានឥទ្ធិពលខ្លាំងពូកែជាង អ្នកនោះក៏ត្រូវបាននូវជ័យជំនះ, បើអ្នកណាមានឥទ្ធិពលខ្សោយជាង អ្នកនោះក៏ត្រូវបាននូវបរាជ័យ គឺការចាញ់ ។

ក្នុងព្រះពុទ្ធសាសនា ក៏មានគោលបំណងក្នុងការឈ្នះ និយមយកជ័យជំនះនេះដែរ ប៉ុន្តែមិនមែនជ័យជំនះ ដូចជាជ័យជំនះរបស់ប្រជាជន

គ្នាលោកនេះឡើយ ។ ព្រោះហេតុនោះពាក្យថា "ជ័យ" ដែលប្រែថា "ការឈ្នះឬជំនះ" នេះ ត្រូវចែកចេញជា ២ យ៉ាងគឺៈ

១_ ពហិជ័យ ការឈ្នះខាងក្រៅ

២_ អជ្ឈត្តជ័យ ការឈ្នះខាងក្នុង ។

## អធិប្បាយពង្រីកសេចក្តី

១_ ការឈ្នះខាងក្រៅ, ការឈ្នះខាងក្រៅសំដៅយកការឈ្នះអ្នកដទៃដោយល្បិចក្ខាលក្តី ដោយការប្រឡងក្តី ដោយការច្បាំងក្តី ឬដោយហេតុណាមួយក្តី ។ ការឈ្នះនេះជាករណីយកិច្ចក្នុងផ្លូវលោកដែលប្រជាជនត្រូវការចង់បានពន់ពេកណាស់ ។ ពួកជនដែលឈ្នះអ្វីមួយ ជួនកាលឈ្នះដោយផ្លូវសុចរិត, ជួនកាលដោយផ្លូវទុច្ចរិត ។ បើឈ្នះដោយផ្លូវសុចរិត ក៏រាប់ថាជាការប្រសើរគ្រាន់បើក្នុងផ្លូវព្រះពុទ្ធសាសនា, បើឈ្នះដោយផ្លូវទុច្ចរិត ឈ្មោះថាជាអំពើអាក្រក់ក្រៃពេក, អ្នកដែលឈ្នះដោយផ្លូវទុច្ចរិតនោះ ក៏អាចដឹងខ្លួនថាទុច្ចរិតដែរ ប៉ុន្តែចេះតែធ្វើទាំងបំពាន ។ ការឈ្នះខាងក្រៅនេះ គឺឈ្នះមនុស្សផងគ្នា គេរាប់ថាជាឧត្តមគតិក្នុងផ្លូវលោកមួយដែរ តែមិនមែនជាស្ថាពរជាប់មាំមួនយូរតទៅឡើយ តែងត្រូវប្រែប្រួលទៅវិញជាធម្មតា ។

ការឈ្នះទឹងការចាញ់នេះ ឈ្មោះថាជាអំពើត្រឡប់ត្រឡិន មិនមែននាំឲ្យមានសន្តិភាពទេ ដោយហេតុថា ការឈ្នះខាងក្រៅនេះ កាលបើអ្នកណាបានហើយ អ្នកនោះត្រូវខំប្រឹងប្រែងរក្សាទុកឲ្យជំនះរបស់ខ្លួន

ដោយប្រយ័ត្នជាទីបំផុត ។ ការរក្សាទុកនូវជ័យជំនះនោះសោត គឺនាំមកនូវសេចក្ដីទុក្ខព្រួយភ័យបារម្ភយ៉ាងក្រៃលែងណាស់ទៅទៀត ។

អ្នកណាប្រាថ្នាចង់បានជ័យជំនះខាងក្រៅ អ្នកនោះរមែងទទួលទុក្ខលំបាកគ្រោះថ្នាក់ខាតបង់ជាច្រើនប្រការណាស់ គឺថាអ្នកដែលបាននូវជ័យជំនះឈ្មោះថាប្រមូលមកនូវសេចក្ដីទុក្ខភ័យ ។ អ្នកឈ្នះតែងបាននូវការគុំគួនអំពីអ្នកចាញ់ ចំណែកខាងអ្នកចាញ់ គឺរមែងដេកកើតទុក្ខក្ដៅក្រហាយជានិច្ច ។ ការឈ្នះនិងចាញ់នេះ ឃើញថាសុទ្ធតែជាផ្លូវនាំមកនូវទុក្ខទោស ។

ពាក្យថា “ការឈ្នះ, ការចាញ់នៃមនុស្សផងគ្នា” ដូចអធិប្បាយមកនេះ ឈ្មោះថាជាអំពើខាងក្រៅក្របខ័ណ្ឌនៃព្រះពុទ្ធសាសនា គឺអំពើមិនប្រកបដោយធម្មគតិក្នុងផ្លូវព្រះពុទ្ធសាសនាឡើយ ។

៣.— **ការឈ្នះខាងក្នុង,** ការឈ្នះខាងក្នុងសំដៅយកជំនះកិលេសខ្លួនឯង ដែលមាននៅក្នុងខ្លួនរបស់យើងគ្រប់គ្នា ។ ការឈ្នះខាងក្នុងនេះ ត្រូវតាមគោលបំណងនៃព្រះពុទ្ធសាសនា ដែលតែងនិយមសរសើរជាទីបំផុត ថាជាកិច្ចប្រសើរជាងការអ្វីៗទាំងអស់ ។ កិលេសដែលមាននៅក្នុងខន្ធសន្ដានរបស់បុថុជ្ជនមានច្រើនយ៉ាង តែបើកប់ដោយខ្លីមាន ៣ យ៉ាងគឺ លោភៈ១ ទោសៈ១ មោហៈ១ ។ កិលេសទាំង ៣ យ៉ាងនេះ ទុកជាឫសគល់នៃកិលេសឯទៀតៗ, អ្នកដែលមានឧបាយល្អ ប្រកបដោយញាណគតិ ខំព្យាយាមលះបង់នូវកិលេស ៣ យ៉ាងនេះ មិនបណ្ដោយឲ្យខ្លួននៅជាទាសភាពនៃកិលេសដែលអាចគ្រប

សង្កត់ញាំញីបាន ខំប្រឹងតស៊ូដោយកុសលធម៌ជាច្រើនយ៉ាង មានការធ្វើទានរក្សាសីលជាដើម, ខំប្រឹងប្រតិបត្តិធម៌ដើម្បីបង្ក្រាំងនឹងកិលេសក្នុងខ្លួន ដកបទាល់តែឈ្នះមិនឲ្យមានកិលេសទាំងនោះ កកើតឡើងគ្របសង្កត់ខ្លួនឯងទៀតបាន ។ ការឈ្នះកិលេសនេះឈ្មោះថាជាជ័យជំនះដ៏ប្រសើរបំផុត ចាត់ជាចរិយាល្អក្នុងផ្លូវធម៌ដោយពិត សមដូចពុទ្ធ-ភាសិតថា

អត្តាហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា

ប៉ុណ្ណោះជាដើម ប្រែថា "ការឈ្នះខ្លួនឯងជាការប្រសើរ ប៉ែកខាងពពួកជនដែលឈ្នះក្រៅពីនេះ (ពុំប្រសើរឡើយ) ព្រោះថាការឈ្នះខ្លួនឯងនោះ កាលបើយើងឈ្នះកបហើយ មិនអាចនឹងត្រឡប់ចាញ់វិញបានទេ ទោះបីមនុស្សក្តី ទេវតាក្តី ព្រហ្មក្តី មារក្តី ក៏ដណ្តើមយកជ័យជំនះអំពីខ្លួនយើងវិញពុំបានឡើយ" ។

យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ

សេចក្តីថា "ជនណាឈ្នះពួកមនុស្ស ក្នុងសង្គ្រាមទាំងពាន់នាក់ក៏ដោយ ចំណែកខាងបុគ្គលនោះ ឈ្នះខ្លួនឯងតែម្នាក់បានឈ្មោះថាជាបុគ្គលដ៏ខ្ពង់ខ្ពស់ជាងអ្នកឈ្នះក្នុងសង្គ្រាម" ។

## អធិប្បាយការឈ្នះខ្លួនឯង

ការឈ្នះខ្លួនឯងជាការប្រសើរជាងការឈ្នះអ្នកដទៃ, ពុទ្ធភាសិតនេះ

បំភ្លឺសេចក្តីឲ្យឃើញថា ការឈ្នះខ្លួនឯងទើបល្អ, ការចាញ់ខ្លួនឯងមិនល្អឡើយ ។

ពាក្យថា "ខ្លួនឯង" នេះបាលីហៅថា "អត្តា" ប្រែថា "ខ្លួន ឬ ចិត្ត" សំស្ក្រឹតថា "អាត្មន" ក្លាយទៅជាអាត្មា គឺបានដល់ចិត្ត ចេតសិកដែលមាននៅក្នុងកាយរបស់មនុស្ស-សត្វ ។ មនុស្សទាំងអស់ក្នុងលោកនេះ តែងតែមានធម្មជាតិ គឺកំណើតនៃធម៌មួយដែលជាតួនាម ឥតមានរូបពណ៌សម្បុរ ហើយមិនអាចមើលឃើញច្បាស់ដោយមំសចក្ខុទេ តែបើមិនបានទូន្មានសង្កត់សង្កិនក៏អាចនាំកាយឲ្យវិនាស, កាលបើគេបានទូន្មានឲ្យបានបទល្អហើយ ក៏រមែងនាំមកនូវសេចក្តីសុខចំរើនដោយពិត ។ ធម្មជាតិនោះឯង គឺចិត្តទំងចេតសិក ត្រង់នឹងពាក្យខ្មែរយើងថា "ខ្លួន" ។ សំដីដែលនិយាយថា "ខ្លួន" នេះជាប្រធាននៃកិច្ចការទាំងខាងល្អទាំងខាងអាក្រក់, កាលបើបុគ្គលប្រព្រឹត្តល្អក៏ព្រោះខ្លួនដែលបានបទល្អ គឺថាខ្លួនហ្នឹងឯងជាបច្ច័យនាំឲ្យបុគ្គលធ្វើល្អ, កាលបើខ្លួនយើងប្រកបដោយកិលេសគ្រោតគ្រាតខ្លាំង ឈ្មោះថាយើងមានខ្លួនអាក្រក់, កាលបើខ្លួនអាក្រក់ក៏រមែងដឹកនាំកាយវាចាឲ្យធ្វើអាក្រក់ផ្សេងៗ មានការសម្លាប់សត្វ, លួចទ្រព្យគេជាដើម ។

ពាក្យថា "ឈ្នះខ្លួនឯង" សំដៅយកការប្រយ័ត្ន, ការទប់ស្កាត់ខ្លួនមិនឲ្យខ្លួនលុះទៅក្នុងអំណាចនៃកិលេសមានលោភៈជាដើមបាន, មួយទៀត ការឈ្នះខ្លួនឯងនេះ ដោយវិធីយ៉ាងសង្ខេបមាន ២ យ៉ាង គឺ សញ្ញមវិធី បានដល់ការសង្រួមប្រយ័ត្ននូវអារម្មណ៍ទាំងខាងក្នុងទាំងខាង

ក្រៅ មិនបណ្ដោយឲ្យបាបធម៌ទាំងឡាយមានអភិជ្ឈា ឬ លោភៈ ជាដើមគ្របសង្កត់ចិត្តរបស់យើងបាន ១, ២ មវិធី បានដល់ការទូន្មានពត់តម្រង់ចិត្ត, គាប់ចិត្ត, ទន់ទាញចិត្តមិនបណ្ដោយឲ្យចិត្តសេពគប់នូវអារម្មណ៍មិនល្អ ផ្ចង់ចិត្តឲ្យបិតនៅក្នុងអំណាចនៃបញ្ញា គឺវិបស្សនាបញ្ញា រហូតទាល់តែបានមគ្គផលនិព្វាន ១ ។

ការទប់ខ្លួនបានដោយវិធីពីរយ៉ាង មិនឲ្យចិត្តលុះលង់ដោយអំណាចកិលេសដូចអធិប្បាយមកនេះ ឈ្មោះថា "ឈ្នះខ្លួនឯង" ។ ការធ្វេសប្រហែសបណ្ដែតបណ្ដោយឲ្យចិត្តត្រាច់ផ្គាត់ទៅតាមទំនើង ឥតមានការប្រយ័ត្នទប់ទល់ ឈ្មោះថា "ចាញ់ខ្លួនឯង" ។ ការឈ្នះខ្លួនឯងលោកកប់ថា ជាការប្រសើរ ដោយហេតុថា ជំនះនោះជាជំនះឈ្នះពប មិនត្រឡប់ចាញ់វិញឡើយ ។ កាលបើបុគ្គលមានជ័យជំនះឈ្នះកិលេសទាំងគ្រោតគ្រាត កណ្ដាល ល្អិត អស់រលីងចាកខន្ធសន្ដានហើយ ឈ្មោះថាជាអ្នកបានដល់នូវព្រះនិព្វាន, ឈ្មោះថាជាអ្នកឈ្នះពបតទៅ ឥតមានអ្នកណាមួយដណ្ដើមយកជ័យជំនះនោះឲ្យត្រឡប់ទៅជាចាញ់វិញបានឡើយ, ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធទ្រង់សរសើរថា "ការឈ្នះខ្លួនឯងជាការប្រសើរ" ដូចបរិយាយមកនេះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងធម៌ទេសនាទុកជាគោល ដើម្បីឲ្យប្រជាជនប្រតិបត្តិយកជ័យជំនះ ខាងក្នុងសន្ដានដូចព្រះគាថាក្នុងគម្ពីរធម្មបទខុទ្ទកនិកាយ ដែលបានដកលំទុកក្នុងបទខាងដើមថា

អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។

ប្រែថា "បុគ្គលគប្បីឈ្នះនូវមនុស្សក្រោធដោយសេចក្ដីមិនក្រោធ, គប្បីឈ្នះនូវមនុស្សមិនល្អ ដោយសេចក្ដីល្អ, គប្បីឈ្នះនូវមនុស្សកំណាញ់ ដោយការឲ្យ, គប្បីឈ្នះនូវមនុស្សអ្នកនិយាយមិនពិតដោយពាក្យពិត" ។

ពុទ្ធភាសិតនេះ សំដែងអំពីវិធីយកជ័យជំនះ បួនវិធីផ្ចាញ់ ដែលអាចញែកចេញជា ៤ អត្ថបទ ដូចសេចក្ដីអធិប្បាយចំពោះអត្ថបទមួយៗ តទៅនេះ ៖

១— ឈ្នះនូវមនុស្សក្រោធដោយសេចក្ដីមិនក្រោធ បានសេចក្ដីថា "មិនតបតដោយកាយវាចាចិត្ត គឺមិនព្រមឲ្យចិត្តកម្រើកក្រេវក្រោធទៅរកមនុស្សអ្នកក្រោធ" ។ ធម្មតាសេចក្ដីក្រេវក្រោធទុកដូចជាភ្លើង, ឯការអត់ធន់តស៊ូចំពោះភ្លើងនោះទុកដូចជាទឹកសម្រាប់លត់ ។ ចំណែកខាងទឹកច្រើនតែឈ្នះភ្លើងជាដរាប ព្រោះហេតុនោះការទប់ចិត្តមិនក្រេវក្រោធរបស់ខ្លួនឯងបាន មិនឲ្យតបតធ្ងងទៅរកបុគ្គលអ្នកក្រោធ ឈ្មោះថាជាអ្នកឈ្នះនូវបុគ្គលអ្នកក្រោធផងឈ្នះនូវភ្លើងកិលេស គឺសេចក្ដីក្រោធរបស់ខ្លួនផង;

២— ឈ្នះមនុស្សមិនល្អដោយសេចក្ដីល្អ សេចក្ដីថា មនុស្សមិនល្អនោះ សំដៅយកមនុស្សអ្នកប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត គឺជាមនុស្សទ្រុស្តសីល ឬជាមនុស្សអន្ធពាល ។ កាលបើត្រូវការ

ចរ៍ឈ្នះមនុស្សអន្ធពាលនោះ ត្រូវផ្ចាញ់ដោយឧបាយដ៏ល្អរបស់ខ្លួន គឺតាំងខ្លួនឲ្យជាអ្នកប្រព្រឹត្តសុចរិត, មានសីលធម៌, មានកល្យាណធម៌ ដើម្បីឃោសនាបង្ហាញឲ្យច្បាស់ដល់មនុស្សអាក្រក់អន្ធពាលឲ្យរឿយៗ ។ ការប្រព្រឹត្តល្អទៅកេមនុស្សអាក្រក់ដូច្នេះ ឈ្មោះថាជាវិធីសម្រាប់ផ្ចាញ់មួយដ៏ប្រសើរបំផុតក្នុងរវាងមនុស្សសប្បុរសនឹងអសប្បុរស ទាំងឈ្មោះថាជាឧត្តមគតិនៃពុទ្ធបរិស័ទអ្នកមានខន្តិធម៌ក្នុងព្រះពុទ្ធសាសនាផង ។

៣— ឈ្នះមនុស្សកំណាញ់ដោយការឲ្យ សេចក្តីថា មនុស្សកំណាញ់ គឺមនុស្សដែលស្វិតស្វាញលាក់លៀមទ្រព្យសម្បត្តិមិនបរិច្ចាគជួយបំពេញកិច្ចណាមួយ ចំពោះបុគ្គលមានមាតាបិតាឬបព្វជិតអ្នកមានសីលធម៌ជាដើម ឬចំពោះសាសនា ជាមនុស្សធ្ងន់ដោយលោភៈ ច្រើនគិតឃើញតែត្រឹមសេចក្តីសុខរបស់ខ្លួនក្នុងបច្ចុប្បន្នតែប៉ុណ្ណោះ ។ កាលបើត្រូវការផ្ចាញ់មនុស្សកំណាញ់នោះ គប្បីផ្ចាញ់ដោយការឲ្យ ។ ព្រោះការឲ្យ ជាឧបាយមួយដែលផ្ទុយគ្នានឹងសេចក្តីកំណាញ់, ការឲ្យទុកជាកិច្ចដ៏ប្រសើរ ដែលអាចបង្ហាញឲ្យឃើញច្បាស់នូវសេចក្តីល្អរបស់ខ្លួនដល់អ្នកដទៃ ដើម្បីបង្រៀនណែនាំអ្នកដែលកំណាញ់នោះឲ្យយល់ឃើញទោសនៃសេចក្តីកំណាញ់ ឬ នាំឲ្យមានសេចក្តីរង្កៀសដល់ខ្លួន ព្រោះហេតុនោះការបរិច្ចាគឲ្យដោយធូរទូលាយ លោកចាប់ថាជាគ្រឿងស្ងប់ទឹកចិត្តដ៏ប្រសើរ ។

៤— ឈ្នះមនុស្សអ្នកនិយាយមិនពិតដោយពាក្យពិត សេចក្តីថា មនុស្សអ្នកពោលពាក្យមិនពិត គឺមនុស្សដែលចូលចិត្តតែ

និយាយកុហកកូតករ ឬអួតអាងលើកដំកើងខ្លួនឯង ដោយអាងហេតុផល ទាញឧទាហរណ៍ដើម្បីឲ្យគេជឿតាមសំដីខ្លួន, ឲ្យគេកោតខ្លាច, ឲ្យគេសរសើរ ភាសាបាលីថា "អត្តុក្កំសី បរវម្ភី" ប្រែថា "បុគ្គលអ្នកបួលចិត្តតែខាងលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ" ។ មនុស្សបែបនេះ ច្រើនតែនិយាយបំផ្លើសដាន ពុំសូវមានពាក្យសំដីពិតទេ ។ កាលបើត្រូវការផ្ចាញ់មនុស្សដែលពោលពាក្យមិនពិតនោះ គប្បីផ្ចាញ់ដោយការនិយាយពាក្យពិតទៅរក គឺពាក្យដែលទៀងទាត់, ពាក្យដែលមានប្រយោជន៍ប្រកបដោយឧត្តមគតិ ជាពាក្យមានហេតុផល មានខ្លឹមសារពិតប្រាកដ ៗ

សេចក្តីអធិប្បាយមកនេះរួបរួមទៅឃើញថា "មនុស្សល្អ ច្រើនតែឈ្នះមនុស្សអាក្រក់ ឬ អំពើល្អឈ្នះអំពើអាក្រក់" ដំណើរនេះគួរតាំងជាបញ្ហាទុក ដើម្បីផ្ញើសេចក្តីអធិប្បាយដល់លោកអ្នកមានប្រាជ្ញាគ្រាន់នឹងដោះស្រាយតទៅ ៖

មនុស្សម្នាក់មានចិត្តអាក្រក់ធាប់ខឹងកាចក្រេវក្រោធ, មនុស្សម្នាក់ទៀតមានចិត្តល្អមិនធាប់ក្រេវក្រោធ ។ មនុស្សដែលមានចិត្តកាចក្រេវក្រោធនោះ អាចប្រទូស្តបៀតបៀនមនុស្សស្លូតរហូតដល់ក្ស័យជីវិតក៏បាន ធ្វើឲ្យលំបាកទុក្ខវេទនាក៏បាន ហេតុអ្វីបានជានិយាយថា មនុស្សល្អឈ្នះមនុស្សអាក្រក់? មួយទៀតមនុស្សម្នាក់ ជាអ្នកប្រព្រឹត្តធ្វើចោរកម្ម. មនុស្សម្នាក់ទៀតជាអ្នករកទទួលទានដោយសម្មាអាជីវៈ ។ បើអ្នកប្រកបដោយសម្មាអាជីវៈ ចេះតែអត់ធន់ចំពោះមនុស្សអ្នកប្រព្រឹត្តចោរកម្មនោះ មុខជាអ្នកប្រព្រឹត្តចោរកម្មនោះ លួចប្លន់យកទ្រព្យសម្បត្តិអស់ពុំខានមែន

ឬ? មួយទៀតមនុស្សម្នាក់ជាអ្នកកំណាញ់ស្វិតស្វាញ, មនុស្សម្នាក់ទៀតជាអ្នកមានចិត្តទូលាយក្នុងការឲ្យ ។ មនុស្សកំណាញ់មុខជានឹងបេះតែសុំយកទ្រព្យសម្បត្តិអំពីអ្នកចិត្តទូលាយអស់ពុំខានមែនឬ? មួយវិញទៀត មនុស្សម្នាក់ជាអ្នកកុហកបោកប្រាស, មនុស្សម្នាក់ជាអ្នកស្លូតពិតត្រង់ ។ មើលទៅមុខជានឹងត្រូវមនុស្សកុហកបោកប្រាសនោះបញ្ឆោតយកទ្រព្យសម្បត្តិ អំពីអ្នកស្លូតត្រង់អស់មិនលែងមែនឬ?

បញ្ហាទាំងនេះ សូមលោកអ្នកពិចារណា ហើយដោះស្រាយតាមសមត្ថភាពតទៅផងចុះ ចំណែកយើងអ្នកនិពន្ធនេះ សូមឆ្លើយដោះស្រាយជូនទុកជាមុនដោយសង្ខេបដូចតទៅនេះ ៖

មនុស្សល្អនឹងមនុស្សអាក្រក់. កាលបើយើងពិចារណាដោយគ្រោតគ្រាតក៏ឃើញថា មនុស្សអាក្រក់ឈ្នះមនុស្សល្អពិតមែន, តែបើពិចារណាឲ្យល្អិតម៉ត់ក៏អាចឃើញថា មនុស្សអាក្រក់មិនឈ្នះមនុស្សល្អបានឡើយ ។ ព្រោះថាមនុស្សអាក្រក់បើទុកជាឈ្នះមនុស្សល្អក៏ឈ្នះដោយសារតែកម្លាំងកាយប៉ុណ្ណោះ បើតាមពាក្យថ្មីដែលគេនិយាយថា "ឈ្នះដោយកម្លាំងបាយ" ។ ការឈ្នះដោយកម្លាំងអន្ធពាលនេះមិនបានឋិតថេរយូរអង្វែងតទៅទេ នឹងត្រូវត្រឡប់ចាញ់វិញដោយឆាប់រហ័សពុំខាន ។ ការឈ្នះតាមផ្លូវរបស់ព្រះពុទ្ធសាសនា ដែលលោករាប់ថាជាគោលធម៌ដ៏ប្រសើរនោះ គឺឈ្នះដោយចិត្តបរិសុទ្ធ, ដោយឧបាយប្រាជ្ញាដ៏ប្រសើរសម្រាប់ខ្លួនគ្រប់ៗគ្នា គឺឈ្នះកិលេសក្នុងសន្តានរបស់ខ្លួន ដោយការអត់សង្កត់, ដោយការទូន្មាន ហ្វឹកហាត់, ដុសខាត់

ចិត្តឲ្យស្អាតចាកកិលេសទាំងឡាយមានលោភៈ ទោសៈ ជាដើម ទាល់តែចិត្តបានបទបែបល្អ រហូតដល់បានមគ្គផលនិព្វាន ដូច្នេះទើបឈ្មោះថាជាការឈ្នះដ៏ប្រសើរបំផុត មិនត្រឡប់ចាញ់វិញឡើយ ។ មួយទៀតការកាត់សេចក្តីឲ្យដឹងថា "មនុស្សខាងណាចាញ់, ខាងណាឈ្នះ" នោះត្រូវពិនិត្យមើលមតិភាគច្រើននឹងភាគតិចនៃប្រជាជន តើមនុស្សអាក្រក់នឹងមនុស្សល្អ មានមហាជនពេញចិត្តខាងណាច្រើនជាង? បើតាមសេចក្តីពិត មនុស្សភាគច្រើនតែងស្រឡាញ់ពេញចិត្តមនុស្សល្អ, គេសរសើរមនុស្សល្អជាដរាប, ទាំងរដ្ឋាភិបាលក៏ត្រូវការស្រឡាញ់តែមនុស្សល្អ, ជួយយកអាសាកាន់ជើងមនុស្សល្អ, ការពារមនុស្សល្អ, តែងដាក់ទោសទណ្ឌកម្មធ្ងន់ដល់មនុស្សអាក្រក់ ដូចយើងក៏បានឃើញស្រាប់មកហើយ ។

ព្រះពុទ្ធសាសនាមិននិយមយកការឈ្នះដោយកម្លាំងកាយ ឬកម្លាំងអាវុធដែលជាអំពើទុច្ចរិតទេ ព្រោះថាការឈ្នះដូច្នោះជាទារុណកម្មអាក្រក់ក្រៃលែងពេកណាស់ ដូចយ៉ាងសង្គ្រាមដែលកើតឡើង អាចនាំឲ្យវិនាសខូចខាតជីវិតមនុស្សសត្វទ្រព្យសម្បត្តិ មិនមែនតិចឡើយ ទាំងតែទីងដីងចាញ់ឈ្នះ ។ ពួកអ្នកចាញ់ក៏ខូចខាតឥស្សរភាព, ពួកអ្នកឈ្នះ ទោះបីមានកិត្តិស័ព្ទ ថាជាអ្នកឈ្នះពិតមែន តែត្រូវបានទទួលពៀរវេរាទុក្ខមកវិញពុំខាន ព្រោះអ្នកចាញ់នោះ ក៏មានសេចក្តីឈឺចាប់ក្នុងចិត្តឥតឧបមា តែងមានចិត្តអាឃាតចងកម្មពៀរ ចំពោះអ្នកឈ្នះ ដោយការគុំគួនជានិច្ចទៅរកអ្នកឈ្នះ ។ កាលបើមានចិត្តចងពៀរយ៉ាងនេះ

តើពៀរនឹងរម្ងាប់ស្ងប់បាត់ទៅដូចម្ដេចកើត  សមដូចពុទ្ធភាសិតថា

យេ វេរំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ  សេចក្ដីថា "ពួកជនណាចងពៀរទុក  ពៀររបស់ជនពួកនោះមិនស្ងប់រម្ងាប់ទៅបានឡើយ" ។

សេចក្ដីនេះបំភ្លឺឲ្យឃើញច្បាស់ថា "កាលបើពៀរនៅមានដល់គ្នានឹងគ្នា សេចក្ដីសុខសប្បាយវៃឆ្ងាយក៏កើតមិនបាន" ។

ចំណែកខាងអ្នកឈ្នះក៏ចេះតែមានទុក្ខ-ភ័យ  ព្រួយជានិច្ចចំពោះបរបក្ស,  ទើបឯខាងអ្នកចាញ់ក៏ចេះតែស្វែងរកឱកាសដើម្បីតស៊ូដណ្ដើមយកជ័យជំនះមកវិញ  ម្ល៉ោះហើយក៏ត្រូវរៀបចំត្រៀមខ្លួនជានិច្ច ។

ការឈ្នះនឹងការចាញ់នេះ,  កាលបើពីរជនបានពិចារណាឃើញដូច្នេះហើយ  រមែងមិនត្រូវការចង់បាននូវការឈ្នះអំពីអ្នកដទៃឡើយ, តែងខំប្រឹងប្រែងស្វែងរកសន្តិវិធី គឺផ្លូវស្ងប់ដើម្បីបន្ទ្រុះបន្ទ្រោមនូវកិលេសមានលោភៈជាដើមរបស់ខ្លួន យកជ័យជំនះតែចំពោះខ្លួនមិនបាច់ប្រណាំងប្រជែងយកជ័យអំពីគេឡើយ  នោះទើបនាំមកនូវសេចក្ដីសុខសន្តិភាពគ្រប់ឥរិយាបថដោយពិតប្រាកដ  សមដូចពុទ្ធភាសិតថាៈ

ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ

សេចក្ដីថា "បុគ្គលលុះតែលះបង់ចោលនូវជ័យនឹងបរាជ័យ គឺការឈ្នះនឹងការចាញ់ចេញបាន ទើបស្ងប់រម្ងាប់ដេកនៅជាសុខ" ។

ពិតណាស់ សេចក្ដីស្ងប់នេះជាសុខដ៏ប្រសើរបំផុត ជាងហេតុដទៃ

ទាំងអស់ដែលមានឡើងនោះ មិនមែនកើតមកអំពីការឈ្នះមនុស្សនឹងមនុស្សផងគ្នាឡើយ ព្រោះការឈ្នះមនុស្សផងគ្នានោះ គ្រាន់តែជាការយកប្រៀបគ្នាប៉ុណ្ណោះ មិនមែនបានសេចក្ដីស្ងប់ចិត្ត ដែលកើតអំពីការឈ្នះនោះទេ ។ អ្នកឈ្នះគេព្រោះហេតុតែបរិបូណ៌ដោយកម្លាំងកាយឬកម្លាំងអាវុធ, អ្នកចាញ់គេ ក៏ព្រោះតែខ្វះកម្លាំងកាយកងអាវុធប៉ុណ្ណោះ ។ សេចក្ដីស្ងប់តែងកើតមាន ព្រោះការគេចវេះចេញចាកពួកគណៈផង, ព្រោះចិត្តដែលប្រាសចាកកិលេសផង មិនមែនកើតឡើងអំពីបុគ្គលអ្នកឈ្នះនឹងអ្នកចាញ់ឡើយ ។ អ្នកទាំងពីរ គឺអ្នកឈ្នះនឹងអ្នកចាញ់សុទ្ធតែជាអ្នកបណ្ដុះបណ្ដាលឲ្យកើតទុក្ខភ័យពៀរវេរាដល់គ្នានឹងគ្នា ពុំមែននាំឲ្យកើតសេចក្ដីស្ងប់ឡើយ ។

ការឈ្នះចាញ់នៃមនុស្សផងគ្នានេះ កាលបើធីរជនបានពិចារណាក៏អាចឃើញច្បាស់ថា សុទ្ធតែជាអំពើដែលគួរលះបង់ចោលឲ្យស្រឡះមិនគួរប្រាថ្នាចង់បាន មិនគួរចង់ជួបប្រទះសោះ ។ តាមមារយាទរបស់ចិត្តបុថុជ្ជន ច្រើនតែប៉ុនប៉ងប្រាថ្នាដើម្បីជ័យជំនះលើគេទាំងអស់ ឥតមាននរណាមួយប្រាថ្នាយកត្រង់ការចាញ់គេឡើយ ។ ប៉ុន្តែការចាញ់គេនោះបើទុកជាមិនមានអ្នកប្រាថ្នាពិតមែន តែអាចកើតមានឡើងជាធម្មតា ។ អ្នកចង់ឈ្នះគេ ត្រឡប់ជាចាញ់គេក៏មាន, អ្នកធ្លាប់ចាញ់គេត្រឡប់ទៅឈ្នះគេក៏មាន ព្រោះហេតុនោះការឈ្នះចាញ់របស់មនុស្សផងគ្នានេះសុទ្ធតែជាទោស ជាសត្រូវនាំមកនូវសេចក្ដីចង្រៃទុក្ខភ័យវិនាសហិនហោចជាពន្ទឹកមហិមា ។

កល្យាណជនទាំងឡាយ! កាលបើត្រូវការចង់បានសេចក្ដីសុខក្សេមក្សាន្តដ៏ធំទូលាយ ត្រូវលះបង់នូវជ័យនិងបរាជ័យឲ្យដាច់ស្រឡះ ទើបឈ្នះសេចក្ដីទុក្ខបាន ។

## អស់តណ្ហាឈ្នះសេចក្ដីទុក្ខ

សេចក្ដីប្រាថ្នា, ការអន្ទះសា, ការសស្ទុះសស្ទាប្លការចង់ឈ្នះគេ ទាំងអស់នេះហៅថា "តណ្ហា" ។ បើយើងនៅមានតណ្ហាដរាបណា, យើងក៏នៅមានសេចក្ដីទុក្ខគ្រប់យ៉ាងដរាបនោះ, បើយើងអស់តណ្ហា, យើងក៏ឈ្នះសេចក្ដីទុក្ខទាំងពួងដែរ, សមដូចពុទ្ធភាសិតក្នុងធម្មបទខុទ្ទកនិកាយថា: តណ្ហក្ខយោ សព្ពទុក្ខំ ជិនាតិ 'ការអស់ទៅនៃតណ្ហារមែងឈ្នះនូវទុក្ខទាំងពួង" ។

ពុទ្ធភាសិតនេះ បង្ហាញសេចក្ដីឲ្យឃើញថា "សេចក្ដីទុក្ខគ្រប់យ៉ាងគឺទុក្ខអំពីសេចក្ដីចាស់គ្រាំគ្រាក្ដី, ទុក្ខអំពីការឈឺចាប់ក្ដី, ទុក្ខអំពីសេចក្ដីស្លាប់ព្រាត់ប្រាសក្ដី, ទុក្ខអំពីចម្បាំងកំហឹងដល់ក្ដី សុទ្ធតែកើតអំពីកិលេសទាំងអស់" ។ ឯកិលេសដែលជាឫសគល់នៃកិលេសឯទៀតៗនោះបានដល់ លោភៈ ការជាប់ជំពាក់ក្នុងអារម្មណ៍មិនចេះឆ្អែតស្កប់ស្កល់, ទោសៈ ការខឹងក្រេវក្រោធចំពោះសត្វ ឬ សង្ខារ, មោហៈ ការវង្វេងភ័ន្តច្រឡំ ។ កិលេសទាំងនេះលោកហៅថាប្រភពកិលេស គឺជាដែនកើតនៃកិលេសទាំងឡាយមានតណ្ហាជាដើម ដែលជាបច្ច័យនាំសត្វឲ្យចំស្ទុះពន្ទុះស្វែងរកនូវអារម្មណ៍ផ្សេងៗ, កាលបើស្វែងរកបានក៏អរសប្បាយ, កាលបើស្វែង

រកមិនបាន ក៏កើតទុក្ខទោមនស្សក្តៅក្រហាយចិត្ត ជាហេតុនាំឲ្យប្រណាំងប្រជែងដេញដើងគ្នាក្នុងការស្វែងរក ។

បុគ្គលដែលមានកិលេសក្រាស់ក្នុងសន្តានស្វែងរកមុនដំបូងដោយផ្លូវសុចរិតក៏មាន, ទុច្ចរិតក៏មាន, លុះកាលជាខាងក្រោយមក កាលបើស្វែងរកដោយផ្លូវសុចរិតមិនបាន នូវអារម្មណ៍ដូចបំណង ក៏ស្វែងរកផ្លូវទុច្ចរិត មានការប្រើឧបាយដោយសម្ងាត់ក៏មាន ដោយការប្រព្រឹត្តបំពានបំពេញមុខក៏មាន តាមតែប្រទះគិតយកឲ្យតែខាងបានប្រយោជន៍មកខ្លួន ឬត្រកូលខ្លួន ទោះបីបះពាល់សិទ្ធិរបស់អ្នកណាមួយក៏ឥតកោតញញើតឡើយ ។ ការស្វែងរកនោះ, បើចេះតែប្រព្រឹត្តទៅដោយស្រួលល្អ មិនមានអ្នកណាមួយហ៊ានជំទាស់ទេ ក៏ឈ្មោះថាមានភ័ព្វបានផលល្អ យូរអង្វែងតទៅ ។ ការប្រព្រឹត្តស្វែងរករបស់បុគ្គលអ្នកមានកិលេសក្រាស់នោះ កាលបើចេះតែរីកធំទូលាយ, ឫទ្ធិអំណាចក៏កើតមានឡើងដោយលំដាប់ ៗ កាលបើឫទ្ធិអំណាចមានបរិបូណ៌ហើយ, ការប្រព្រឹត្តរំលោភឈ្លានពានជិះជាន់លើមនុស្សផងគ្នាក៏កាន់តែមានឡើងឥតឈប់ឈរឡើយ, ម្ល៉ោះហើយ ការប្រព្រឹត្តរំលោភដោយហេតុតែចង់បានសុខដ៏ធំទូលាយមកលើខ្លួនម្នាក់ ៗ នោះក៏រមែងប៉ះពាល់ដំពប់ទៅលើសិទ្ធិអ្នកណាមួយក្នុងថ្ងៃណាមួយពុំខាន ។

ជយកថា ចប់

# ជិតពេកមើលមិនឃើញ[១]

យុគបណ្ណានុរក្ស ប៊ូ - ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

សំនួរ – យើងច្រើនតែសំគាល់ឃើញថា ខ្លួនយើងល្អសព្វគ្រប់ទាំងអស់ ឥតខ្វះកន្លះសោះ ចុះហេតុអ្វីបានជាអ្នកដទៃគេនៅតែយល់ឃើញថា យើងនៅមានសេចក្ដីអាក្រក់ខ្វះ រឿងនេះ ព្រោះហេតុផលដូចម្ដេច ?

ចម្លើយ – ព្រោះយើងនៅជិតខ្លួនឯងពេកណាស់ បានជាត្រួតត្រាមើលខ្លួនមិនសព្វគ្រប់ សូម្បីគ្រាន់តែមើលមុខខ្លួនឯងក៏មិនឃើញផង បើចង់ឃើញ ត្រូវយកកញ្ចក់មកឆ្លុះមើល បើចង់ឲ្យឃើញខាងក្រោយទៀត ត្រូវថែមកញ្ចក់ ១ ទៀត ។ ចំណែកអ្នកដទៃមើលឃើញខ្លួនយើងបានច្បាស់ណាស់ ព្រោះគេនៅឆ្ងាយឃ្លាតពីខ្លួនយើង មានឱកាសពិនិត្យមើលបានជាក់លាក់ ។ ឯអ្នកដទៃនោះ ក៏មិនឃើញខ្លួនឯងច្បាស់ ដូចជាយើងមិនឃើញខ្លួនយើងដែរ ។

យើងមិនសូវយកចិត្តទុកដាក់ក្នុងសេចក្ដីប្រព្រឹត្តិរបស់យើង ដោយការឧស្សាហ៍ត្រួតត្រាមើល ដូចជាយើងគ្មានកញ្ចក់ឆ្លុះមុខ យើងត្រួតត្រាដោយការសមគំនិតនឹងខ្លួនឯងច្រើនពេក បានជាយើងមើលមិនឃើញសេចក្ដីអាក្រក់របស់យើង ដូចជាយើងឆ្លុះកញ្ចក់ហើយ ប៉ុន្តែយកកញ្ចក់

---

១ ប្រែចាកច្បាប់ធម្មចក្ក ព. ស. ២៤៨១ ។

មកដាក់ផ្ទាប់ជាប់នឹងសាច់មុខតែម្ដង ឬកញ្ចក់នោះនៅឆ្ងាយពីមុខយើងពេក ក៏ឥតមើលឃើញអ្វីសោះ ហាក់ដូចជាមិនបានឆ្លុះកញ្ចក់ដែរ លុះតែដាក់កញ្ចក់ឲ្យឆ្ងាយល្មមប្រមាណ ទើបឆ្លុះឃើញមុខច្បាស់ ។ ការត្រួតត្រាមើលសេចក្ដីប្រព្រឹត្តិរបស់ខ្លួនក៏យ៉ាងនោះដែរ បើត្រួតត្រាមើលដោយសមគំនិតតែខាងខ្លួនឯងពេកទៅ ក៏ដូចជាឆ្លុះកញ្ចក់យកមកដាក់ខ្ទប់មុខតែម្ដង ឬដាក់ឆ្ងាយពីខ្លួនពេកឥតឃើញអ្វីសោះ ។ ហេតុនេះ ត្រូវត្រួតត្រាមើលខ្លួនឯងដោយមិនចូលដៃនឹងខ្លួនឯង ទើបបានឃើញសេចក្ដីល្អអាក្រក់ពិតប្រាកដ ដូចឆ្លុះកញ្ចក់ដាក់ពីមុខឲ្យឆ្ងាយល្មម ។ សរុបសេចក្ដីថា ការដែលអ្នកដទៃមើលឃើញសេចក្ដីអាក្រក់របស់យើងច្រើនជាងយើងឃើញខ្លួនឯងនោះ ដោយមានហេតុ ២ ប្រការ គឺយើងនៅជិតខ្លួនឯងហួសពេក ១ យើងច្រើនតែសមគំនិតនឹងខ្លួនឯងពេក ១ ។

មានចម្លើយម្យ៉ាងទៀតថា បានជាយ៉ាងនោះ ព្រោះមានហេតុផល ៤ ប្រការគឺ ព្រោះសេចក្ដីនិយមចូលចិត្តផ្សេងគ្នា ១ ព្រោះយើងមានសេចក្ដីឃើញសមគំនិតតែខាងខ្លួនឯង ១ ព្រោះយើងធ្វើខុសដោយមិនដឹងខ្លួន ១ ព្រោះសេចក្ដីល្អដែលយើងមាននោះ មិនជាទីចូលចិត្តរបស់អ្នកដទៃ ១ ។

ត្រង់ប្រការទី ១ ដែលថា ព្រោះសេចក្ដីនិយមចូលចិត្តផ្សេងគ្នានោះ គឺមានច្បាប់របស់ធម្មតាថា នានាចិត្តំ ចិត្តរមែងផ្សេងៗគ្នា កាលបើចិត្តផ្សេងគ្នាហើយ សេចក្ដីនិយមចូលចិត្តក៏ផ្សេងគ្នាដែរ កាលបើសេចក្ដីនិយមចូលចិត្តផ្សេងគ្នាហើយ សេចក្ដីយល់ឃើញរហូតដល់ការធ្វើក៏ផ្សេង

គ្នាដែរ ៗ បើមនុស្សមានច្រើនប៉ុន្មាន គំនិតសេចក្ដីនិយមចូលចិត្ត, សេចក្ដីយល់ឃើញ, នឹងការធ្វើ ក៏រមែងតែបែកខ្ញែកប្លែក ៗ គ្នាទៅប៉ុណ្ណោះ ដែលនឹងឲ្យត្រូវត្រង់គ្នានោះតិចណាស់ ៗ រួមសេចក្ដីថា អ្នកណានិយមយ៉ាងណា ក៏ចូលចិត្តយ៉ាងនោះ ៗ អ្នកណានិយមក្នុងខ្លួន ក៏ប្រកាន់យកខ្លួនជាធំ (អត្តាធិបតេយ្យ) ៗ អ្នកណានិយមក្នុងលោក ក៏ប្រកាន់យកលោកជាធំ (លោកាធិបតេយ្យ) ៗ អ្នកណានិយមក្នុងធម៌ ក៏ប្រកាន់យកធម៌ជាធំ (ធម្មាធិបតេយ្យ) ៗ សេចក្ដីនិយមផ្សេងគ្នានេះ មានរឿងក្នុងព្រះសុត្តន្តបិដកជាឧទាហរណ៍ថា គ្រាមួយ ព្រះភជាច្រើនព្រះអង្គកើតជជែកទាស់ទែងខ្វែងគំនិតគ្នា អង្គមួយយល់ឃើញថារូបល្អ ៗ អង្គមួយយល់ឃើញថាសំឡេងល្អ ៗ អង្គមួយយល់ឃើញថាក្លិនល្អ ៗ អង្គមួយយល់ឃើញថារសល្អ ៗ អង្គមួយយល់ឃើញថាផោដ្ឋព្វៈល្អ ៗ អង្គមួយយល់ឃើញថាធម្មារម្មណ៍ល្អ ៗ មានសេចក្ដីយល់ឃើញមិនចុះសម្រុងគ្នាដូច្នេះ ៗ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "មហាបពិត្រទាំងឡាយ ! រឿងនេះប្រកាន់យកសេចក្ដីចូលចិត្តជាប្រមាណ គឺថា បើអ្នកណាចូលចិត្តយ៉ាងណា យ៉ាងនោះហើយជាសេចក្ដីល្អរបស់អ្នកនោះ, ដូច្នេះ ៗ យើងចូលចិត្តទៅម្យ៉ាង អ្នកដទៃចូលចិត្តទៅម្យ៉ាង របស់ដែលយើងចូលចិត្ត គេបែរជាមិនចូលចិត្តវិញ របស់ដែលយើងយល់ឃើញថាល្អ គេបែរថាជាមិនល្អវិញ គឺថាយើងឬរបស់នៃយើងអាក្រក់នោះឯង ៗ

ត្រង់ប្រការទី ២ ដែលថា ព្រោះយើងមានសេចក្ដីយល់ឃើញសមគំនិតតែខាងខ្លួនឯងនោះ គឺកាលគំនិត, សេចក្ដីនិយម, សេចក្ដីយល់

ឃើញ, សេចក្ដីគាប់ចិត្តនឹងការធ្វើផ្សេងគ្នា មានឡើងហើយ សេចក្ដីយល់ឃើញថាខ្លួនត្រូវក៏មានឡើងដែរ ហើយនឹកជានិច្ចថា យើងល្អសព្វគ្រប់ទាំងអស់ អ្នកដទៃមិនអាចប្រៀបផ្ទឹមនឹងយើងបានឡើយ សូម្បីយើងទីងខុសសែនខុស ក៏នៅតែនឹកថាខ្លួនត្រូវជាដរាប សូម្បីយើងខូចក្រៃលែងខូច ក៏នៅតែនឹកថាខ្លួនល្អជានិច្ច ព្រោះទោសគឺមានះទិដ្ឋិនោះមកបិទបាំង ទើបធ្វើឲ្យយើងមើលមិនឃើញសេចក្ដីខ្វះខាតរបស់ខ្លួន ៗ សេចក្ដីល្អដែលយើងប្រកាន់យកនេះត្រូវតែអ្នកដទៃសំឡឹងមើលទើបនឹងដឹងថាខូចបង់ត្រង់ណាបាន ៗ យើងចេះតែនឹកថា យើងល្អពេញទី ប៉ុន្តែសេចក្ដីអាក្រក់ដែលជ្រៀតជ្រែកនៅក្នុងចន្លោះខ្លួនយើងនោះនឹងកើតប្រាកដក្នុងភ្នែករបស់អ្នកដទៃមិនខាន ៗ ព្រះដ៏មានព្រះភាគបានត្រាស់ព្រះគាថាទុកក្នុងធម្មបទ ដើម្បីនឹងបន្ទូលប្រាប់រឿងនេះថា សុទស្សំ វជ្ជមញ្ញេសំ ទោសរបស់អ្នកដទៃឃើញបានងាយ អត្តនោ បន ទុទ្ទសំ ចំណែកទោសរបស់ខ្លួនឯងឃើញបានក្រ បរេសំ ហិ សោ វជ្ជានិ ឱបុនាតិ យថា ភុសំ ព្រោះថា គេរមែងបាចសាចទោសទាំងឡាយដល់ជនពួកដទៃ ដូចមនុស្សបាចអង្កាមដូច្នោះ អត្តនោ បន ឆាទេតិ តែថា រមែងបិទបាំងទោសរបស់ខ្លួនទុក កលឹវ កិតវា សឋោ ដូចជានាយព្រានបិទបាំងកាយដោយគ្រឿងបិទបាំងដូច្នោះ ៗ

ត្រង់ប្រការទី ៣ ដែលថា ព្រោះគេធ្វើការខុសដោយមិនដឹងខ្លួននោះ គឺក្នុងកាលយើងមានសេចក្ដីល្អហើយ យើងស្រវឹងឬក្អើតក្អើនក្អេប

ខ្លួនក្នុងសេចក្តីល្អរបស់យើងដែលពេកទៅ (ប្រមាទ) ទាល់តែជាហេតុឲ្យធ្វើអំពើអាក្រក់ដោយមិនដឹងខ្លួន ទាំងកំពុងតែធ្វើអាក្រក់ដូច្នោះ ក៏មិនដឹងថាយើងធ្វើអាក្រក់ផង បេះតែប្រកាន់ថាយើងធ្វើល្អត្រឹមត្រូវជានិច្ច ដោយអំណាចមោហៈមកគ្របសង្កត់ ទើបធ្វើឲ្យយើងវង្វេងដូចស្រវឹងសុរា ។ សេចក្តីអាក្រក់ដូច្នោះយើងសំឡឹងមើលមិនឃើញ ប៉ុន្តែទឹងត្រូវកើតមានប្រាកដក្នុងភ្នែករបស់អ្នកដទៃ គឺអ្នកដទៃគេមើលកំហុសរបស់យើងឃើញច្បាស់ណាស់ ។

ត្រង់ប្រការ ៤ ដែលថា ព្រោះសេចក្តីល្អរបស់យើងមាន តែមិនជាទីចូលចិត្តរបស់អ្នកដទៃនោះ គឺសេចក្តីល្អរបស់យើងមានមែនហើយ បើទុកជាត្រឹមត្រូវតាមសេចក្តីនិយមរបស់គេក៏ដោយ គេក៏នៅតែត្រូវការចង់ឲ្យយើងវិសេសលើសឡើងជាងមុននោះទៅទៀត ។ ចំណែកសេចក្តីល្អដែលគេចូលចិត្តនោះ យើងមិនទាន់មាននៅឡើយ បានជាគេឃើញថាយើងមិនទាន់ល្អដល់កម្រិតទេ គឺថានៅតែមានអាក្រក់មិនខានឡើយ ។

មួយទៀត មនុស្សគ្រប់រូបនឹងឲ្យល្អព្រមសព្វគ្រប់ទាំងអស់ឥតខ្វះកន្ទុះនោះរកមិនបានទេ តែងមានល្អខ្លះ អាក្រក់ខ្លះជាធម្មតា ប៉ុន្តែអ្នកដទៃទៅសំឡឹងយកតែត្រង់ចំណែកអាក្រក់ ត្រង់ចំណែកល្អមិនបានសំឡឹងមើលផងទេ បានជាឃើញថា យើងនៅមានសេចក្តីអាក្រក់ខ្លះមិនខាន ។

# បញ្ញាសជាតក

## ភាគទី ៤

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## វដ្ដង្គុលីរាជជាតក ទី ២០

លោកអាចារ្យ ឈឹម-ណាក ប្រែពីបាលី

---

ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

ខ្ញុំបានស្តាប់មកយ៉ាងនេះថា សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់សម្រេចសម្រាន្តព្រះឥរិយាបថ ក្នុងវត្តជេតពន ជាអារាមរបស់អនាថ-បិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

សម័យនោះឯង ព្រះបាទបសេនទិកោសល ទ្រង់សោយរាជ្យក្នុងនគរនោះ; ព្រះអង្គប្រកបដោយទសពិធរាជធម៌ រក្សាមហាជនដោយសង្គហធម៌ទាំង ៤ យ៉ាង មានព្រះរាជទានព្រះរាជទ្រព្យជាដើម, ទ្រង់មិនប្រើអាការៈកំហែងផ្ទើរទោសលក់ថ្លៃ ទាំងមិនមានប្រហារដោយគ្រឿងសស្ត្រាវុធឡើយ ។ ព្រះអង្គតែងនាំគ្រឿងសក្ការបូជាមានកម្រងផ្កានិងគ្រឿងក្រអូបជាដើម ទ្រង់ស្តេចទៅកាន់វត្តជេតពន ដើម្បីស្តាប់ធម៌

ទេសនា ក្នុងសាយណ្ហសម័យជានិច្ច ៗ មានកាលសម័យថ្ងៃមួយ ព្រះដ៏មានបុណ្យ ទ្រង់តើនចាកសយនាក្នុងបច្ចូសសម័យ ទ្រង់ប្រមើលមើលដោយពុទ្ធចក្ខុ បានឃើញពួកជនដែលមានឧបនិស្ស័យគួរត្រាស់ដឹងនូវមគ្គផលនៅក្នុងទីឆ្ងាយ, ទើបព្រះអង្គទ្រង់ធ្វើសរីរកិច្ចរួចស្រេចស្ដេចប្រដាប់បាត្រចីវរ ទ្រង់ពុទ្ធដំណើរទៅក្នុងទីនោះ, សំដែងធម៌ប្រោសជនអ្នកមានឧបនិស្ស័យនោះឲ្យបានដល់ក្នុងសោតាបត្តិផល ៗ ជួនជាពេលនោះ ព្រះបាទបសេនទិកោសលព្រមទាំងបរិពារ ឲ្យរាជបំរើកាន់គ្រឿងសក្ការបូជា មានគ្រឿងក្រអូបនិងកម្រងផ្កាជាដើម ស្ដេចទៅកាន់វត្តជេតពន ដើម្បីស្ដាប់ធម៌ ក្នុងសាយណ្ហសម័យ; កាលទ្រង់មិនឃើញព្រះតថាគត ក៏មានព្រះរាជហឫទ័យក្តុក្កួលរំជួលជាទុក្ខទោមនស្សត្រាស់ថា ឥឡូវវត្តជេតពនសាបសូន្យហើយតើ, ទាំងបំណងរបស់អាត្មាអញក៏ដាច់មិនបានសម្រេចដែរ ៗ ព្រះរាជាត្រាស់យ៉ាងនេះហើយក៏កើតវិប្បដិសារីសេចក្ដីក្ដៅក្រហាយស្ដាយព្រះចិន្ដា, ទ្រង់បូជាចំពោះពុទ្ធាសនៈ ដោយគ្រឿងសក្ការៈមានទៀនធូបគ្រឿងក្រអូបនិងកម្រងផ្កា ហើយទ្រង់ត្រឡប់ចូលមកកាន់ក្រុងសាវត្ថីវិញភ្លាម ៗ វេលារាត្រីយប់នោះ ព្រះអង្គផ្ទំមិនស្កប់ពេញមួយយប់ ទើបមានព្រះរាជឧង្ការត្រាស់ហៅអាមាត្យនិងព្រាហ្មណ៍គហបតីទាំងឡាយ មកហើយត្រាស់ពិភាក្សាថា ម្នាលអ្នកដ៏ចំរើនទាំងឡាយ, ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលគង់នៅជាប់ជានិច្ចក្នុងកន្លែងណាមួយ ៗ ទេ, បើពួកវេនេយ្យសត្វអ្នកមានឧបនិស្ស័យគួរព្រះអង្គដឹកនាំបាន នៅក្នុងទីណា, ព្រះអង្គតែងធ្វើពុទ្ធដំណើរទៅក្នុងទីនោះៗ ព្រោះ

ព្រះអង្គមានព្រហ្មវិហារ គឺសេចក្ដីអាណិតអាសូរចំពោះសត្វទាំងនោះជាប្រក្រតី, ឯព្រះពុទ្ធជាម្ចាស់នៃយើង ក៏ដូច្នោះដែរ; ចំណែកខាងយើងចង់តែចូលទៅអង្គុយជិតព្រះរតនត្រៃជានិច្ច ប៉ុន្តែបើព្រះដ៏មានព្រះភាគស្ដេចមានពុទ្ធដំណើរទៅក្នុងទីណាមួយ ទ្រង់ផ្ដាច់វត្តរបស់យើងដើម្បីប្រយោជន៍ពួកជនដទៃ, គួរតែយើងសូមឲ្យព្រះដ៏មានព្រះភាគអនុញ្ញាតដើម្បីនឹងកសាងព្រះបដិមាមួយអង្គជាព្រះរូបស្នង ។ ពួកឥស្សរជនទាំងអស់ មានអាមាត្យជាដើម បានស្ដាប់ព្រះរាជឧង្ការហើយ ក៏មានចិត្តរីករាយ ក្រាបបង្គំទូលស្នងព្រះរាជឧង្ការទៅវិញថា បពិត្រព្រះរាជសម្ភារ, ព្រះរាជតម្រិះដែលព្រះអង្គទ្រង់ឈ្វេងយល់នេះប្រពៃពេកណាស់ នឹងបានជាប្រយោជន៍ដល់សព្វសត្វទៅក្នុងព្រះនគរ អស់កាលជាយូរអង្វែង, ឯទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ក៏នឹងបានកសាងព្រះបដិមាតាមកំឡាំងរៀង ៗ ខ្លួនដោយសារព្រះអង្គផង ។ លុះដល់វេលាព្រឹកឡើង ព្រះរាជាត្រាស់ហៅពួកឥស្សរជនមានអាមាត្យជាដើម ឲ្យមកជួបជុំគ្នាក្នុងវេលាថ្ងៃរសៀល ឲ្យកាន់យកគ្រឿងសក្ការៈផ្សេង ៗ មានផ្កាកម្រងនិងគ្រឿងក្រអូបជាដើម ស្ដេចទៅកាន់វត្តជេតពនចូលទៅរកព្រះដ៏មានព្រះភាគ, លុះចូលទៅដល់ ទ្រង់បូជាព្រះដ៏មានបុណ្យ ក្រាបថ្វាយបង្គំ ហើយទ្រង់គង់ក្នុងទីដ៏សមគួរ ។ ព្រះបាទបសេនទិកោសល ទ្រង់គង់នៅក្នុងទីដ៏សមគួរហើយ ទ្រង់មានព្រះរាជឧង្ការចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន, ពីថ្ងៃម្សិលមិញ បណ្ដាជនក្នុងក្រុងសាវត្ថី មកឯវត្តជេតពននេះ ពុំបានឃើញព្រះដ៏មានព្រះភាគ ក៏កើតសេចក្ដីក្ដៅក្រហាយ

ត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ ដោយគិតថា "នុហ៎! វត្ថុដែតពទសាបសូន្យ ហើយតើ; បពិត្រព្រះអង្គដ៏ចំរើន, ព្រោះហេតុនោះសូមព្រះអង្គទ្រង់អនុញ្ញាតឱ្យការកសាងព្រះបដិមាដល់ខ្ញុំព្រះអង្គ ដើម្បីអនុគ្រោះដល់សត្វ-លោក, ប្រសិនបើព្រះដ៏មានព្រះភាគព្រះអង្គព្រមអនុញ្ញាតឲ្យ, ខ្ញុំព្រះអង្គទាំងឡាយ ជាអ្នកមានសទ្ធានឹងកសាងព្រះបដិមា ដម្កល់ទុកជាទីគោរពសួងព្រះអង្គតទៅ" ។ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះសណ្ដាប់ព្រះរាជឧង្ការនោះហើយ ទ្រង់ត្រាស់ថា បពិត្រមហារាជ, ប្រពៃហើយ, ស្រួលហើយ, សូមព្រះអង្គធ្វើព្រះបដិមាចុះ, តថាគតអនុញ្ញាតឲ្យតាមព្រះរាជបំណង ។ ព្រះរាជាបសេនទិកោសល ទ្រង់ព្រះសវនាការព្រះពុទ្ធដីកាព្រះតថាគតហើយ ក៏មានព្រះរាជហឫទ័យត្រេកអរស្កប់ស្កល់ ដោយព្រះបីតិជ្រះថ្លា លើកព្រះហស្ដាថ្វាយបង្គំទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគ ហើយគង់នៅស្ដាប់ធម៌ទេសនាដរាបដល់ចប់ ទើបក្រាបថ្វាយបង្គំលាព្រះសាស្ដា នាំពួករាជបរិពារចូលទៅកាន់ព្រះរាជបុរីវិញ ។ ព្រឹកឡើង ទ្រង់ត្រាស់ឲ្យហៅពួកជាងឈើមក ទ្រង់ត្រាស់ព្រះរាជបញ្ជាឲ្យជាងនោះសាងព្រះបដិមាដោយខ្លឹមចន្ទន៍(១) មានថ្ងៃច្រើន ។ កាលបើកិច្ចកសាងព្រះបដិមានោះសម្រេចហើយ, ទ្រង់ឲ្យលាបលទរំលេចពណ៌ដ៏វិចិត្រ ឲ្យដូចជាគ្រូអង្គព្រះសម្មាសម្ពុទ្ធ ដែលមានព្រះជីវិតពិតប្រាកដ; ទើបព្រះអង្គទ្រង់ចាត់ឲ្យធ្វើមណ្ឌបដ៏វិចិត្រដោយរតនវត្ថុផ្សេង ៗ ហើយទ្រង់ឲ្យនិមន្តព្រះពុទ្ធបដិមាមកគង់លើសីហាសនៈ កណ្ដាលមណ្ឌបនោះ ទ្រង់ធ្វើ

---

១ ក្នុងសៀវភៅនិពាណលពុទ្ធចេតិយ មានសេចក្ដីបដិសេធរឿងនេះថាខុសនិងប្រែបទដទៃ ។

សក្ការបូជាជាមហោឡារិកច្រើនប្រការ ។ លំដាប់ពីនោះមក ព្រះរាជាទ្រង់ស្តេចទៅឯវត្តជាមួយនឹងពួករាជបរិវារ ថ្វាយបង្គំព្រះដ៏មានព្រះភាគក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន, ការកសាងព្រះពុទ្ធបដិមាសម្រេចហើយ, ប្រសិនបើព្រះដ៏មានបុណ្យទ្រង់ទតឃើញ ប្រហែលជាទ្រង់ពេញព្រះរាជហឫទ័យណាស់ ។ សម្តេចព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ទទួលដោយតុណ្ហីភាព ។

ដល់ថ្ងៃស្អែកឡើង ព្រះបរមគ្រូ មានពួកភិក្ខុចោមរោមជាបរិវារ ទ្រង់ពុទ្ធដំណើរចូលទៅកាន់រាជនិវេសន៍, ទ្រង់សំដៅទៅត្រង់កន្លែងដែលព្រះពុទ្ធបដិមាគង់នៅ ។ ខណៈនោះព្រះពុទ្ធបដិមា បានឃើញព្រះបរមគ្រូហើយ ក៏ហាក់ដូចជាមានព្រះចិន្តាគិតថា "អាត្មាអញមិនគួរបើអង្គុយលើអាសនៈខ្ពស់បែបនេះសោះ ព្រោះព្រះសម្មាសម្ពុទ្ធដែលមានព្រះជីវិត ព្រះអង្គទ្រង់ធរមាយុនៅឡើយ" ហើយក៏ប្រុងប្រៀបរៀបចុះចាកសីហាសនៈជាវិការៈនៃកែវ ៧ ប្រការ ។ លំដាប់នោះ ព្រះបរមសាស្តា ទ្រង់ទតឃើញព្រះបដិមាមានអាការៈដូច្នោះ ក៏ព្រះដ៏ទ្រង់យសទ្រង់លាព្រះហស្តខាងស្តាំ ដ៏ល្អឲកាស ទន់ល្វន់ល្មួសដូចជាប្រមោយដំរីពួកវ័ណ្ណ ពយាត់ថា ម្នាលអាវុសោ, អ្នកចូរអង្គុយចុះ, អ្នកកុំចុះចាកអាសនៈឡើយ, មិនយូរប៉ុន្មានទេតថាគតនឹងបរិនិព្វាន, ម្នាលអាវុសោ, ចូរអ្នកថែរក្សាសាសនាតថាគតឲ្យបានគ្រប់ចំនួន ៥០០០វស្សា ដើម្បីប្រយោជន៍ដល់សត្វលោក ។ ព្រះពុទ្ធបដិមានោះ ក៏ហាក់ដូចជាចេះស្តាប់ព្រះពុទ្ធដីកា ថយទៅគង់លើអាសនៈដូចដើមវិញ ។ គ្រានោះ

ពួកមហាជន មានព្រះរាជាជាប្រមុខ ឃើញហេតុជាទីអស្ចារ្យដូច្នោះ ក៏ថ្វាយជីវិតដល់សាសនា ហើយយកសំពត់ធ្វើទង់ជាច្រើនពាន់ ដោតគ្រប់ទីដំបន់សំពោងព្រោងព្រាត ៗ ព្រះបាទបសេនទិកោសលថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ត្រាស់ព្រះរាជបុច្ឆា សួរអំពីអានិសង្សនៃការកសាងព្រះពុទ្ធបដិមាចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន, នរជនណាមួយ ទោះជាបុរសឬជាស្ត្រីដែលបានកសាងព្រះពុទ្ធបដិមា តើនរជននោះត្រូវបានអានិសង្សដូចម្តេច? ព្រះដ៏មានជោគទ្រង់បានសវនាការព្រះរាជបុច្ឆានោះហើយ ទើបបើកព្រះឱស្ឋមានពណ៌ក្រហមទុំដូចសំពត់កម្ពល ត្រាស់ព្រះពុទ្ធដីកាចំពោះព្រះរាជា បពិត្រមហារាជ, នរជនណាមួយ ទោះជាបុរសឬជាស្ត្រី ដែលមានសទ្ធាបានកសាងព្រះពុទ្ធបដិមា អំពីដីស្អិតក្តី ថ្មក្តី ដែកក្តី ស្ពាន់ក្តី ឈើក្តី សំណរក្តី កែវក្តី ប្រាក់ក្តី មាសក្តី ភ្លុកក្តី ស្នែងក្តី គូរជាគំនូរក្តី បណ្តារបស់ទាំងអស់នោះ ណាមួយ, នរជននោះឯង នឹងត្រូវបានផលានិសង្សច្រើន; បពិត្រមហារាជ, ព្រះពុទ្ធបដិមា ឋិតនៅក្នុងលោកដរាបណា សត្វលោកឈ្មោះថាមិនសូន្យចាកព្រះពុទ្ធដរាបនោះ ទាំងបាននូវគ្រឿងទីពឹងក្នុងសាសនាទៀត; បុគ្គលណាមួយ បានកសាងព្រះពុទ្ធបដិមា បុគ្គលនោះ រមែងមានសេចក្តីសុខក្នុងលោកខាងមុខ, បើតាំងសេចក្តីប្រាថ្នាយ៉ាងណា ក៏នឹងបានសំរេចនូវផលតាមសេចក្តីប្រាថ្នាយ៉ាងនោះ; បពិត្រមហារាជ, កាលពីមុន ពោធិសត្វបានធ្វើនូវកុសល គឺគ្រាន់តែធ្វើព្រមព្រះហស្តមួយរបស់ព្រះបដិមាដែលកំបុតឲ្យតាំងនៅជាប្រក្រតីដូច

ដើមវិញ ហើយបូជានូវវត្ថុបន្តិចបន្តួចប៉ុណ្ណោះ, ដោយអំណាចផលនោះ ព្រះពោធិសត្វបានសោយសម្បត្តិទិព្វក្នុងឋានសួគ៌ តាមសេចក្តីប្រាថ្នា, លុះច្យុតិចាកទេវលោកនោះមកបានជាស្តេចឯករាជ្យក្នុងជម្ពូទ្វីបទៀត; តពីនោះមក ព្រះពោធិសត្វ បានគង់ព្រងពោធិមណ្ឌល កំចាត់បង់ពួកពលមារ ដែលមកចោមរោមព័ទ្ធជុំវិញ ហើយទ្រង់បានត្រាស់សព្វញ្ញុតញ្ញាណជាព្រះពុទ្ធប្រាកដឡើងក្នុងលោក ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ព្រះពុទ្ធដីកាតែប៉ុណ្ណោះ ក៏ទ្រង់គង់ស្ងៀមទាល់តែព្រះបាទបសេនទិកោសល ក្រាបទូលសូមឲ្យព្រះអង្គនាំអតីតនិទានមកសំដែង ទើបព្រះអង្គទ្រង់នាំអតីតនិទានមកសំដែងប្រាប់ថា:

អតីតេ កិរ អមរវតិយា នាម នគរេ ឯកោ ពាណិជោ កុលកទ្ទកុមារោ នាម បដិវសតិ ។ បានឮរៀងរាបដរាបមកថា កាលដែលកន្លងទៅហើយ នៅក្នុងនគរអមរវតី មានពាណិជម្នាក់ ឈ្មោះកុលកទ្ទកុមារ ។ សម័យមួយ កុលកទ្ទកុមារនោះបានបររទេះទៅកាន់នគរឯទៀត ជាមួយនឹងពួកពាណិជប្រហែល ១ ពាន់នាក់ ដើម្បីជួញប្រែ ។ កាលដែលកុលកទ្ទពោធិសត្វ កំពុងបររទេះទៅ ក៏ស្រាប់តែបានប្រទះឃើញព្រះពុទ្ធបដិមាមួយព្រះអង្គ ដែលគេកសាងពីដីស្អិត ក្នុងអាកាមដែលតាំងនៅក្នុងព្រៃក្បែរផ្លូវ ។ ព្រះពុទ្ធបដិមានោះ បាក់ម្រាមព្រះហស្តមួយ ដោយត្រូវទឹកភ្លៀង ។ ពោធិសត្វបានឃើញហើយ ក៏ថ្វាយបង្គំព្រះបដិមានោះ បានប្រថាប់ដីស្អិតលាយនឹងប្រេងល្ង តម្រាមព្រះហស្តព្រះពុទ្ធបដិមាឲ្យពេញបរិបូណ៌ដូចដើមវិញ ។ ពោធិសត្វនោះ បានបូជាដោយគ្រឿង

សក្ការៈទាំងឡាយ មានទៀនធូប និងផ្កាកម្រងជាដើម ហើយបានយកប្រាក់ ៨ កហាបណៈ មកប្រគល់ឲ្យតាសីម្នាក់ជាអ្នករក្សាព្រះពុទ្ធរូបនោះ ដើម្បីជាថ្លៃគ្រឿងយញ្ញផង ដើម្បីជាថ្លៃគ្រឿងបូជា មានទៀនធូប គ្រឿងក្រអូបនិងផ្កាកម្រងជាដើមផង, ទើបប្រណម្យអញ្ជលីតាំងសេចក្តីប្រាថ្នាពាក្យនេះថា បពិត្រព្រះអង្គដ៏ចំរើន, ដោយអានិសង្សនៃការកសាងម្រាមព្រះហស្តនេះ ដល់ទៅអនាគត សូមកុំឲ្យសត្រូវទាំងឡាយទាំងពួងមានមកក្នុងទីចំពោះមុខខ្ញុំឡើយ, ហើយខ្ញុំសូមឲ្យបានជាព្រះពុទ្ធប្រាកដក្នុងលោក ។ ចាប់ដើមតាំងពីនោះមក ពលក្តី សត្រូវក្តី ដោយហោចទៅ សូម្បីតែសត្វពស់ដែលមានពិស ក៏មិនហ៊ានទៅចំពីមុខពោធិសត្វនោះឡើយ ។ ពោធិសត្វនៅជាសុខដរាបដល់អស់ជន្មាយុ ច្យុតិចាកអត្តភាពជាមនុស្សនោះទៅ បានទៅកើតក្នុងទេវលោកសោយសម្បត្តិទិព្វសម័យនោះ ពួកអាសុរទាំងអស់ ឥតហ៊ានក្រឡេកមើលចំមុខពោធិសត្វសត្វនោះឡើយ ។ លុះច្យុតិចាកស្ថានសួគ៌នោះមក បានមកចាប់បដិ-សន្ធិក្នុងផ្ទៃនៃអគ្គមហេសីព្រះបាទពារាណសី ។ ចំណែកខាងពួកទេវតាចំនួន១ពាន់ជាបរិវារ ក៏ច្យុតិមកចាប់បដិសន្ធិ ក្នុងផ្ទៃភរិយានៃអាមាត្យទាំងឡាយក្នុងនគរនោះដែរ ។ ព្រះអគ្គមហេសីនោះ លុះទ្រង់គភ៌គ្រប់ទសមាសហើយ ក៏ទ្រង់ប្រសូតិព្រះរាជបុត្រប្រកបដោយបុញ្ញលក្ខណៈ។ ចំណែកខាងភរិយានៃអាមាត្យទាំងឡាយ ក៏សម្រាលបុត្រក្នុងថ្ងៃនោះដែរ ។

ព្រះបរមពោធិសត្វ ទ្រង់ចំរើនធំធេងរុងរឿងដោយពួកកុមារជាបរិវារ ទ្រង់មានពួកកុមារហែហមចោមរោមជានិច្ច ។ ព្រះអង្គមានបុណ្យ

អានុភាពអស្ចារ្យចំឡែក ទោះបីសេះ ឬ ដំរីឯណាដែលកាចសាហាវគេទូន្មានពុំបាន, ដំរីឬសេះនោះ គ្រាន់តែឃើញព្រះពោធិសត្វ ចង្អុលដោយម្រាមព្រះហស្តមួយប៉ុណ្ណោះ ក៏ទ្រោមក្រាបចុះឥតមានពុតអំណាចរឹងរូសសោះ ព្រោះហេតុដូច្នោះបានជា ព្រះរាជវង្សានុវង្សទ្រង់ថ្វាយព្រះនាមព្រះពោធិសត្វនោះថា វដ្តគុលិករាជកុមារ ។ លុះអំណើះអំពីព្រះវររាជបិតាទៅ ព្រះពោធិសត្វទ្រង់បានសោយរាជសម្បត្តិ ក្នុងនគររបស់ព្រះអង្គដោយទសពិធរាជធម៌ ។ ទ្រង់រក្សាប្រជាជនដោយសង្គហវត្ថុទាំង ៤ យ៉ាង ពុំបានបៀតបៀនដោយអាជ្ញាឡើយ ។ ព្រះពោធិសត្វអង្គនោះជាធម្មិករាជ ទ្រង់បំណាយព្រះរាជទ្រព្យកសាងសាលាទាន៦ខ្នង ហើយទ្រង់ព្រះរាជទាន មហាទាន៦សែនកហាបណៈរាល់ៗថ្ងៃ ។ ព្រះអង្គពុំដែលសម្លាប់សត្វបំបាត់ជីវិតឡើយ ដោយហោចទៅ សូម្បីតែញុំាងឈាមមនុស្សសត្វដទៃឲ្យស្រក់ចុះត្រឹមតែរុយតូចមួយស៊ីឆ្អែត ក៏ពុំដែលផង ។ ទ្រង់ពុំដែលកាន់យកវត្ថុដែលម្ចាស់គេមិនបានឲ្យដោយកាយ ឬដោយវាចា សូម្បីតែមួយកាកណិកឡើយ ។ ពុំដែលឆ្មៀងព្រះនេត្រទតប្រពន្ធអ្នកដទៃ ដោយសេចក្តីត្រេកបន្តិចបន្តួចឡើយ ។ ពុំដែលបញ្ឆោតព្រះរាជឧង្ការមិនពិត សូម្បីតែបន្តិចបន្តួចចំពោះអ្នកដទៃឡើយ ។ ពុំដែលសោយសុរាទាំង៥ប្រការ ចំពោះសុរាត្រង់ប្រការណាមួយសោះឡើយ ។

កាលនោះ ព្រះរាជាទាំង១០១ព្រះអង្គនៅក្នុងជម្ពូទ្វីប បានជ្រាបនូវគុណានុភាពព្រះមហាក្សត្រហើយ បានរួមគំនិតប្រជុំប្រឹក្សាគ្នាថា ពួក

យើងនឹងទៅច្បាំងដណ្ដើមយករាជសម្បត្តិរបស់ស្ដេចវដ្ដគុលីនោះ ឲ្យបានដោយងាយ ដូចជារបេះផ្កាឈូកដែលជាប់នៅនឹងទង ។

ព្រះរាជាទាំងអស់នោះ លុះប្រជុំព្រមព្រៀងគ្នាស្រេច ទើបស្ដេចចាត់ការរៀបចតុរង្គអង្គសេនា មានចំនួនពួកពលសកលយោធា ១៨ អក្ខោភិនី ចេញសំដៅទៅក្រុងពារាណសី ។ លុះលើកទ័ពទៅដល់ពាក់កណ្ដាលផ្លូវ ក៏សរសេរព្រះរាជសារបញ្ជូនទូតម្នាក់ឲ្យនាំយកទៅ ថ្វាយវដ្ដគុលីរាជ ។ សេចក្ដីក្នុងព្រះរាជសារនោះយ៉ាងនេះថា អ្នកក្រុងពារាណសីព្រមឲ្យរាជ-សម្បត្តិដល់យើង ឬមួយចង់ច្បាំងជាមួយនឹងយើង? បើចង់យ៉ាងណា ចូរធ្វើយ៉ាងនោះចុះ ។ រាជទូតចូលទៅក្នុងក្រុងពារាណសីហើយឈរនៅនាព្រះរាជលាន ។ មានអាមាត្យម្នាក់បានឃើញរាជទូតនោះហើយ ក៏ទៅក្រាបបង្គំទូលព្រះមហាសត្វ ។ ព្រះអង្គទ្រង់ត្រាស់ឲ្យហៅរាជទូតនោះចូលមកសួរពត៌មាន ។ រាជទូតក៏ចូលទៅថ្វាយព្រះរាជសារ ។ ព្រះរាជាទ្រង់ទតសព្វគ្រប់សេចក្ដី ក៏មានព្រះរាជហឫទ័យក្លៀវក្លាដូចជារាជសីហ៍ ឥតមានសេចក្ដីញាប់ញ័រព្រឺព្រះលោមាសូម្បី១សរសៃឡើយ ហើយទ្រង់ព្រះសម្រួលត្រាស់សួររាជទូតនោះវិញថា ស្ដេចទាំងអស់នោះចំនួនប៉ុន្មាន, មានពួកពលចំនួនប៉ុន្មាន, ដែលមកបំណងនឹងធ្វើសង្គ្រាមជាមួយយើងនេះ? រាជទូតក្រាបទូលថា ស្ដេចទាំងអស់ចំនួន ១០១ ព្រះអង្គ, មានពលចំនួន ១៨អក្ខោភិនី បានមកត្រៀមចាំជាស្រេច ។ (មានត)

# ផ្នែកអក្សរសាស្ត្រ

ពេជ្រព្រះរាជា

លោក ស៊ុន-ហ៊ាន ប្រែរៀបរៀង

លោក យូរ-អ៊ុន ពិនិត្យកែសម្រួល

---

## អ្នកស្រឡាញ់ធម៌គឺជាអ្នកល្អ

ក្នុងសម័យដ៏កន្លងទៅយូរហើយ នៅប្រទេសឥណ្ឌា មាននគរមួយឈ្មោះពារាណសី ជានគរដ៏ធំស្តុកស្តម្ភ, ព្រះមហាក្សត្រគ្រប់គ្រងនគរនេះ ទ្រង់ព្រះនាម "ព្រះធម្មបតីរាជា" ទ្រង់មានព្រះរាជធីតា ៣ ព្រះអង្គ តែគ្មានព្រះរាជបុត្រជារជ្ជទាយាទទេ ។ បណ្ដាព្រះរាជធីតាទាំង ៣ ព្រះអង្គនោះ អង្គបងបង្អស់ព្រះនាម "សុភាទេវី" អង្គកណ្ដាលព្រះនាម "ស្រីឧសា" អង្គប្អូនបំផុតព្រះនាម "កល្យាណី" ព្រះរាជធីតាប្អូននេះមានសរីរៈរាងកាយល្អក្រៃលែង សមនឹងព្រះនាមរបស់ព្រះនាង ។

ប្រជាជនក្នុងនគរពារាណសី មានសេចក្ដីសុខក្សេមក្សាន្តគ្រប់គ្នា ព្រោះព្រះបាទធម្មបតីរាជាទ្រង់គ្រប់គ្រងនគរតាមទសពិធរាជធម៌ ទើបខេត្តខណ្ឌសីមារបស់ព្រះអង្គត្រជាក់ត្រជុំជាសុខស្ថាពរ លុះតមកកាលព្រះរាជធីតាទាំង ៣ ព្រះអង្គ មានវ័យសមគួរល្មមនឹងអភិសេកឲ្យមានព្រះស្វាមីហើយ ព្រះអង្គក៏ទ្រង់ហៅហោរាព្រឹទ្ធាមាត្យមកប្រឹក្សា កាលហោរាព្រឹទ្ធាមាត្យទាំងឡាយមកដល់ហើយ ព្រះអង្គក៏មានព្រះបន្ទូលថា:

" ខ្ញុំចង់ដឹងថា ក្នុងដែនទាំងអស់របស់យើងនេះ តើមានវរបុរសដែលសមគួរនឹងអភិសេកជាមួយនឹងធីតារបស់យើង ឬទេ? ដូច្នេះសូមលោកទាំងឡាយជ្រើសរើសរកមកឲ្យយើង បើបុត្រក្សត្រទាំងឡាយដ៏សមគួរមិនមានទេ ក៏សូមឲ្យលោកចាត់រកបុត្ររបស់ពស្ត្រអ្នកជំនួញក្នុងដែនរបស់យើង ឬអំពីដែនដទៃក៏បាន សូមឲ្យពួកលោកទទួលភារៈក្នុងការណ៍នេះ ដោយយកចិត្តទុកដាក់" ។

ពួកព្រឹទ្ធាមាត្យ ទទួលព្រះរាជបញ្ជាព្រះមហាក្សត្រ ហើយក៏ប្រឹក្សាគ្នា, បណ្ដាអាមាត្យនឹងខុនណាងទាំងឡាយ មានខុនណាងអ្នកធំ ១ រូបឲ្យយោបល់ថា

" នគរពាកណាសី មានសេចក្ដីរុងរឿងមកជាយូរអង្វែងឆ្នាំហើយ ដោយសារបុណ្យសម្ភារបារមីនៃព្រះមហាក្សត្រទ្រង់មានព្រះរាជហឫទ័យទ្រង់ធម៌ មានព្រះករុណាធិគុណ ទ្រង់ប្រកបដោយទសពិធរាជធម៌ប្រចាំព្រះអង្គ ដូច្នេះសូមឲ្យអស់លោកពិនិត្យមើលឲ្យល្អិតល្អសិន" ។

ខុនណាងអ្នកធំ ១ រូបទៀតឲ្យយោបល់ថា

" ដើម្បីសេចក្ដីសុខដល់ព្រះរាជា នឹងប្រជាជនទាំងពួង សូមឲ្យស៊ើបសួរជ្រើសរើសរកចំពោះតែអ្នកដែលមានគុណពិសេស, មិនចាំបាច់តែព្រះរាជបុត្រព្រះមហាក្សត្រទេ ទោះបីជាពស្ត្រស្រុកណាក៏ដោយ ឲ្យតែមានសតិបញ្ញាឈ្លាសវៃនឹងមានគុណធម៌ដ៏ពិសេស ដែលសមគួរនឹងគ្រប់គ្រងនគរជាតំណាងអំពីព្រះធម្មបតីរាជក្សត្ររបស់យើងបាន" ។

កាលប្រជុំព្រមគ្នាជាឯកច្ឆន្ទហើយ ក៏ជ្រើសរើសបានខុនណាងអ្នក

ធំ ៣ រូបសំរាប់ឲ្យចេញទៅស៊ើបរកបុរសរត្នដើម្បីឲ្យជាគូនឹងរាជបុត្រី, ខុនណាងអ្នកធំទាំង ៣ រូបនោះ ឈ្មោះបាលិត ១ សុខសរ្បនៈ ១ ចលិត ១ ទាំង ៣ នេះជាអ្នកមានប្រាជ្ញាវៀងវៃ មានសមត្ថភាពអង់អាចធ្លាប់ធ្វើការតាមព្រះនេត្រព្រះករុណារបស់ព្រះធម្មបតីរាជាមកជាយូរហើយ ។

ទីងថ្លែងអំពីព្រះអង្គម្ចាស់ក្សត្រីទាំង ៣ ព្រះអង្គវិញ, កាលព្រះរាជាបានទ្រង់ប្រគល់ការជ្រើសរើសស្វាមីដើម្បីរាជបុត្រីស្រេចហើយ ក៏ស្ដេចទៅព្រះរាជដំណាក់ ទ្រង់ជួបព្រះរាជធីតាទាំង ៣ ហើយត្រាស់ប្រាប់រឿងរ៉ាវដែលព្រះអង្គបានទ្រង់ធ្វើឲ្យព្រះធីតាទាំង ៣ ព្រះអង្គជ្រាបហេតុការណ៍រៀងៗខ្លួន ។

ព្រះរាជធីតាទាំង៣ព្រះអង្គមានសេចក្ដីអៀនខ្មាសតាមវិស័យក្សត្រីដែលមានស័ក្ដិខ្ពស់, ព្រះនាងបង្គាបបង្គំទូលព្រះរាជបិតាថា:

"បពិត្រព្រះរាជបិតា ខ្ញុំម្ចាស់ជាព្រះរាជបុត្រីរបស់ព្រះអង្គ ព្រះអង្គជាព្រះបិតា ទ្រង់ព្រះករុណាទិគុណដល់ខ្ញុំម្ចាស់ជាបុត្រី កម្រនឹងរកវត្ថុឯណាក្នុងលោកមកប្រៀបឲ្យស្មើបាន, កាលបើព្រះអង្គមានព្រះរាជបំណងយ៉ាងណា ខ្ញុំម្ចាស់ក៏មិនអាចនឹងបដិសេធចោលនូវព្រះរាជបំណងនោះឡើយ" ទូលព្រះរាជបិតាហើយ ព្រះនាងបងក៏គង់នៅស្ងៀម ។

ព្រះធម្មបតីរាជាទ្រង់លាន់ព្រះឱស្ឋ ដោយព្រះទ័យដ៏រីករាយយ៉ាងក្រៃលែង កាលបើព្រះរាជធីតារបស់ព្រះអង្គមានចិត្តប្រកបដោយគុណធម៌ គឺសេចក្ដីកតញ្ញូកតវេទី ដឹងគុណតាំងនៅក្នុងព្រះរាជហឫទ័យយ៉ាងនេះហើយ ទើបទ្រង់ត្រាស់សួរដល់ព្រះរាជធីតាប្អូនទាំងពីរទៅទៀត

"នែបុត្រីសំឡាញ់! បិតាបានស្ដាប់ពាក្យបងនាងហើយ ប្រាកដថាបងនាងត្រេកអរហើយ បានទទួលប្រតិបត្តិតាមបំណងរបស់បិតា, ចុះបុត្រីទាំងពីរវិញ តើនឹងមានការទទឹងទាស់យ៉ាងណាដែរឬទេ?" ។

ព្រះនាងស្រីសុសាទីនព្រះនាងកល្យាណីជប់ព្រះភក្ត្រ ព្រះរាជបិតាក៏ត្រាស់សួរថែមទៀត:

"យ៉ាងដូចម្ដេចទៅបុត្រីសំឡាញ់ទាំងពីរ, នាងមិនមានសេចក្ដីត្រេកអរទេឬ?" ។

ខត្តិយានីទាំងពីរព្រះអង្គងើបព្រះភក្ត្រឡើងហើយក្រាបបង្គំទូលតបព្រះរាជបិតាថា ៖

"ខ្ញុំម្ចាស់ត្រេកអរ, កាលបើព្រះរាជបិតាមានព្រះរាជបំណងយ៉ាងណា ខ្ញុំម្ចាស់ក៏ពុំហ៊ានទទឹងទាស់ទាំងអស់" ។

ព្រះធម្មបតីកជាទ្រង់សោមនស្សយ៉ាងក្រៃលែង; តាំងអំពីនោះមកទ្រង់ក៏រង់ចាំមើលពួកអាមាត្យធំៗ ទាំង ៣ នាក់ដែលចេញទៅស៊ើបអង្កេតរកបុរសរត្ន មកធ្វើជាព្រះរាជសុនិសាដោយព្រះទ័យជំរួសរាក់ ។

ចាប់តាំងអំពីថ្ងៃជាដំបូង, អាមាត្យទាំង ៣ នាំគ្នាដើរតាមផ្លូវចេញអំពីក្រុងពារាណសី ដរាបដល់ផ្លូវមួយបែកជាបី ឆ្ងាយពីក្រុងពារាណសីក៏បញ្ឈប់សេះប្រឹក្សាគ្នា:

"លោកទាំងពីរយល់ឃើញប្រការណាល្អជាង? យើងនឹងរួមគ្នាទៅកាន់ប្រទេសនីមួយៗ ទាំង ៣ នាក់ ឬនឹងបំបែកផ្លូវគ្នាទៅ ទើបប្រពៃ?

បើយើងបំបែកគ្នាទៅ ហើយបានជួបបុរសគ្រួសារក្នុងស្រុកណា យើងត្រូវវិល ត្រឡប់មកជួបគ្នានៅទីនេះ ក្នុងរយៈវេលា ៦ ខែខាងមុខទៀត" ។

អមាត្យធំឈ្មោះបាលិត ជាអ្នកឲ្យយោបល់ដល់អមាត្យសុទស្សនៈ និងអមាត្យទុលិក, ដូច្នេះហើយទាំង ៣ នាក់ក៏យល់ស្របគ្នាទើបបំបែកផ្លូវគ្នាចេញទៅនៅខាងក្រោយពេល ដែលបានណាត់គ្នារួចហើយ ។ បាលិតអមាត្យជាអ្នកចាស់ជាងគេស្ទាត់ជំនាញនូវវិជ្ជាផ្សេងៗ មកតាំងអំពីនៅកម្មោះ ជាអ្នកដឹងដល់ចិត្តថ្លើមមនុស្សណាដែលស្មោះត្រង់ វៀចវេរ ឬមនុស្សល្ងង់ខ្លៅ, ក៏ឡើងជិះសេះបរកាត់តម្រង់ទៅកាន់ក្រុងវេសាលី ដែលជាប្រទេសមួយនៅឆ្ងាយអំពីនគរពារាណសី ។ ក្រុងវេសាលី មានភូមិថ្មែក ១ មានភ្នំជាច្រើន, ទេសភាពក្រុងកំពុងតែប្រជាប់តាក់តែងទៅដោយគោមភ្លើងនឹងទង់ជាតិខ្លួនទៅ ហាក់ដូចជាមានការធ្វើបុណ្យធំក្នុងព្រះនគរ ។ បាលិតអមាត្យទើបចូលទៅសួរបុរសម្នាក់ថា:

"ម្នាលលោកដ៏ចំរើន, ការដោតទង់ជាតិ នឹងប្រដាប់តាក់តែងទៅដោយគោមភ្លើងទូទៅទាំងព្រះនគរយ៉ាងនេះ តើដើម្បីធ្វើពិធីអ្វី? ព្រោះខ្ញុំទើបនឹងមកអំពីព្រៃមិនបាននឹងរឿងរ៉ាវនេះសោះ សូមលោកមេត្តាប្រាប់ខ្ញុំឲ្យបានដឹងផង" ។

បុរសដែលត្រូវគេសួរឃើញអាការៈរបស់អមាត្យបាលិតមានសេចក្តីគួរលំទោន ក៏សើចហើយតបថា៖

"លោករវល់តែនៅក្នុងព្រៃទើបមិនដឹងថា ក្នុង ៧ ថ្ងៃខាងមុខនេះ ព្រះរាជានឹងធ្វើពិធីបូជាយញ្ញយ៉ាងធំឡារិក ក្នុងរោងពិធីមុខព្រះរាជវាំង,

ពិធីនេះមិនបានធ្វើមកអស់វេលាច្រើនឆ្នាំហើយ, ការបូជាយញ្ញត្រូវប្រើសត្វរស់ៗ ជាចំនួនច្រើន, បុណ្យនៃរបៀបនេះយូរៗ មានឡើងម្តង គេធ្វើក្នុងពេលដែលស្រុកទេសកើតកាកេទមិនមានសន្តិសុខ" ។

បាលិតអមាត្យទើបចុះអំពីខ្នងសេះ ដោយសេចក្តីងឿងឆ្ងល់ក្នុងចិត្ត ព្រោះមិនធ្លាប់បានឮបានដឹងអំពីពិធីបូជាយញ្ញ ដោយសត្វរស់ៗ ដែលប្លែកផ្សេងអំពីពិធីដទៃៗ ដែលធ្លាប់បានឃើញមកក្នុងក្រុងពាកណសី ព្រមទាំងឆ្ងល់ថា តើការបូជាយញ្ញដោយសត្វរស់នោះនឹងធ្វើដោយប្រការដូចម្តេច? កាលមានសេចក្តីសង្ស័យដូច្នោះហើយក៏អត់សង្កត់ចិត្តមិនបានទើបសួរទៀត :

"សូមលោកមេត្តាប្រាប់ខ្ញុំឲ្យបានដឹងបន្តិចតទៅទៀត ការបូជាយញ្ញដែលរាប់ថាជាពិធីដ៏សំខាន់ត្រូវប្រើសត្វរស់ៗ នោះ តើកើតអំពីអ្វីដែលជាដើមហេតុ ហើយត្រូវប្រើសត្វអស់ប៉ុន្មាន?" ។

ខណៈដែលបាលិតអមាត្យកំពុងតែសួរ អំពីការធ្វើពិធីបូជាយញ្ញចំពោះបុរសនោះ ក៏ស្រាប់តែមានមាណពម្នាក់ជិះសេះសកម្រែងចូលមកបញ្ឈប់សេះហើយចុះមកសម្ពះសួរដោយអាការទន់ទេរមានលំនាំជាទីគួរសរសើរគួរកោតយ :

"លោកដ៏ចំរើន, សូមមេត្តាប្រាប់ឲ្យខ្ញុំបានដឹងផង តើប៉ុន្មានថ្ងៃទៀតព្រះរាជានឹងធ្វើពិធីបូជាយញ្ញ?" ។

បុរសនោះតបថា "មាណព, ៣ ថ្ងៃទៀត លោកនឹងបានឃើញពិធីធំដុំដែលយូរៗ មានធ្វើម្តង គេបង្គង់ទាំឲ្យតែដល់ថ្ងៃ ១៥ កើតដែល

ព្រះចន្ទរះពេញវង់ ជាថ្ងៃដែលព្រះឥសូរទ្រង់រីករាយព្រះទ័យ ថ្ងៃនោះព្រះរាជានឹងទ្រង់ប្រោសប្រទានឲ្យធ្វើពិធីនេះហើយ ” ។ មាណពនឹកក្បាលហើយអង្គុយស្ងៀមមិននិយាយអ្វីតទៅទៀត ។

បុរសនោះទើបងាកបែរមុខមកនិយាយនឹងបាលិតអាមាត្យ :

“ ការបូជាយ័ញដែលនឹងធ្វើក្នុងថ្ងៃដូចពោលមកនេះ ក៏ព្រោះព្រះធីតារបស់ព្រះរាជាទ្រង់ប្រឈួនជាខ្លាំងក្នុងគ្រានេះ ព្រមទាំងកើតមានអាគេទផ្សេងៗ គឺ សំទូងក្នុងស្រែមិនលូតលាស់ល្អងាប់អស់រលីងព្រោះគ្មានទឹក; ការរាំងភ្លៀងនេះនាំឲ្យកើតរោគរប៉ក្សាទូទៅទាំងស្រុក, ព្រះរាជាបានទ្រង់សួរទៅពួកហោរា នឹងពួកព្រាហ្មណ៍ ។ ឥស្សរជនទាំងនេះ សឹងតែយល់ឃើញស្របគ្នាហើយក្រាបទូលថា “ព្រះឥសូរជាម្ចាស់ទ្រង់ពិរោធ ទើបបានបណ្ដាលឲ្យភ្លៀងរាំងនឹងកើតមានរោគរប៉ក្សា, ត្រូវតែរកពិធីបួងសួងទេវតាទាំងឡាយនឹងព្រះឥសូរ ទើបហេតុអាគេទទាំងឡាយនឹងបន្ធូបង់ស្រាលស្ដើងទៅបាន” ។

អាមាត្យបាលិតបានស្ដាប់ពាក្យអធិប្បាយអំពីពិធីបួងសួង ដោយបូជាយ័ញហើយ ក៏ចង់ឃើញពិធីនោះយ៉ាងក្រៃលែង ទើបអរគុណបុរសនោះហើយក៏លាទៅរកទីស្នាក់តទៅ. ដឹកសេះដើរតាមផ្លូវទៅមិនយូរប៉ុន្មាន ក៏បានដល់ព្រះរាជវាំងនៃព្រះម្ចាស់ផែនដីនៃនគរវេសាលី បានឃើញរោងពិធីធំៗ យ៉ាងមហិមា ក៏ប្រញាប់ស្រូតជើងដឹកសេះចូលទៅមើលជិត ។ មើលទៅខាងក្នុងឃើញមានជើងក្រានភ្លើងធំៗ ដែលគេដោយឥដ្ឋ ព្រមទាំងសសស្ដូបប្រុងប្រៀបទុកសម្រាប់ដុត បន្ទាប់អំពីជើងក្រាន

ភ្លើងធំៗនោះទៅ មានផ្លូវទឹកហូរបាញ់មកអំពីទៃនធំមួយៗ ទៃននោះមានហ៊ុំងសៀតគ្រឿងសស្ត្រាវុធជាវលំពែងគ្រប់បែប មើលទៅគួរឲ្យខ្លាចពន់ពេក អំពីបន្ទោះទៃននោះទៅមានក្រង់សត្វធំៗ សត្វដែលនៅក្នុងក្រង់នោះមាន សេះ, គោ, ក្របី, ពពែ, កែះ ពួសួវតែសំឡេងយំអឺងកង្វល់ទៅទាំងបរិវេណពេធិពិធី, សត្វខ្លះក៏ដេកលក់ស៊ប់ ខ្លះស៊ីស្មៅ ខ្លះក៏ឈរស្ងៀមសម្លឹងមើលទៅខាងក្រៅ ។

បាលិតអមាត្យរកប់សត្វទាំងនោះទៅឃើញប្រមាណជាងពាន់សត្វ ក៏នឹកចំឡែកក្នុងចិត្តចំពោះពិធីនេះ ដែលខ្លួនមិនធ្លាប់បានឃើញពីដើមមកសោះ ។ ខណៈដែលបាលិតអមាត្យកំពុងឈរមើលដោយសេចក្ដីស្ងប់ស្ងៀងនោះ មានបុរសម្នាក់មកកេះគាត់ពីខាងឆ្វេង គាត់ងាកមើលទៅឃើញមាណពតូចម្នាក់ដែលបានជួបអម្បាញ់មិញម្ដងមកហើយ ទើបគាត់សន្ទនានឹងបុរសនោះ ។

មាណពតូចនោះងក់ក្បាលធ្វើគារវកិច្ចហើយប្រស្រ័យ ដោយកិរិយាមិនសូវកែកាយ :

"លោកដ៏មានអាយុ លោកចូលចិត្តក្នុងពិធីបូជាយញ្ញរបស់ព្រះរាជាឬ? តើលោកមានការដឹងយ៉ាងដូចម្ដេចខ្លះក្នុងពិធីនេះ? ។

អមាត្យបាលិត ឃើញអាការរបស់មាណពតូចដូច្នោះហើយ ក៏ពិនិត្យមើលឃើញសព្វពាង្គកាយរបស់គេទៅឃើញបានថា ជាបុរសកម្លោះ ១ រូបល្អធេត ដោយតែងកាយប្លែកអំពីអ្នកស្រុកនេះ ស្លាយជាវសមសួនស្រស់បស់គួរមើល ទើបយល់បានថា គេមិនមែនជាអ្នកស្រុក

នេះដោយពិតប្រាកដ, អាកប្បកិរិយារបស់គេទទួលទានបន្ទន់ខ្លួនក្នុងខណៈដែលបរិបា, បាលិតអមាត្យទើបតបថា:

“ ខ្ញុំដឹងច្បាស់មកតាំងអំពីដំបូង ដោយបានឃើញការតាក់តែងទង់ជាតិខ្លួនទៅទាំងព្រះនគរ លុះកាលបានសាកសួរអ្នកស្រុកដឹងនូវកិច្ចការធ្វើពិធីហើយ ខ្ញុំជាមនុស្សតាំងប្រទេស មិនធ្លាប់បានឃើញពិធីដូច្នេះក្នុងទីណាមកអំពីមុនសោះឡើយ ទើបខ្ញុំចង់ឃើញការធ្វើពិធីនេះឲ្យជាក់ច្បាស់នឹងភ្នែក តើលោកឃើញពិធីនេះប្លែកយ៉ាងដូចម្តេចខ្លះ? ” ។

មាណព ងើបមើលទៅខាងក្រង់ខាំងសត្វនោះមុន ទើបបែរមុខមកនិយាយថា:

“ ខ្ញុំមិនឃើញថា ពិធីនេះជាពិធីប្លែកគួរមើលគួរសរសើរសោះទេ ព្រោះសត្វទាំងឡាយ ដែលគេនាំមកខាំងទុកនៅទីនេះ នឹងត្រូវគេសម្លាប់សាច់ស្បែករបស់វាក៏ត្រូវព្រះអគ្គីឆាបឆេះខ្លោចទៅជាធ្យូងផេះពុំខាន តើនឹងកើតប្រយោជន៍អ្វីដោយការបូជាបែបនេះ? ពេគរប័ក្សារបស់អ្នកស្រុកនឹងការប្រឈួននៃព្រះអគ្គីម្ចាស់ក្យត្រីមិនមែនវិនាសទៅ ព្រោះតែការបូជាយញ្ញបែបនេះទេ ការយល់ឃើញរបស់ខ្ញុំដូច្នេះឯង ” ។

បាលិតអមាត្យ បានស្តាប់ពាក្យរបស់មាណព ក៏យល់ឃើញថាជាពាក្យពិត តែក្នុងចិត្តនៅគិតថា ជាពិធីបូជាយញ្ញនេះជាប្រពៃណីដែលអ្នកនគរនេះធ្លាប់ធ្វើនឹងប្រតិបត្តិមក ឯមាណពអ្នកនិយាយមិនមែនជាអ្នកស្រុកនេះ ព្រោះធម្មតាមនុស្សក្រៅប្រទេសតែងមានគំនិតផ្ទុយគ្នា តែពាក្យរបស់មាណពនោះអាចដាស់សតិគាត់បានខ្លះទើបសួរមាណពថា:

"ចុះលោកបានជ្រាបប្រាកដហើយឬ ថាកាលបើធ្វើពិធីបូជាយញ្ញទៅហើយ អាការប្រឈួននៃម្ចាស់ក្សត្រនឹងកេតរប័ក្សានឹងមិនវិនាស?" ។

មាណពងក់ក្បាលគំទាបតបថា "ខ្ញុំបានដឹងវិសេសជាងនេះទៅទៀត? ព្រោះហេតុនេះ ខ្ញុំទើបនិយាយថាការធ្វើពិធីបូជាយញ្ញនេះ មិនសម្រេចប្រយោជន៍អ្វីក្រៅអំពីការបង្ករឲ្យកើតសេចក្ដីទុក្ខវេទនានឹងការតក់ស្លុតដល់មនុស្សដូចជាខ្ញុំនេះ" និយាយបណ្ដើរលើកដៃចង្អុលទៅត្រង់ទីដែលគេធ្វើទុកក្នុងពេលពិធីដែលមានផ្លូវទឹកហូរមកកាន់គំនរភ្លើង "លោកមើលទីឯណោះ? តើលោកមានសេចក្ដីយល់ឃើញដូចម្ដេច?" ។

អមាត្យបាលិតបានស្ដាប់ពាក្យមាណពហើយ ក៏នឹកឆ្ងល់ថា ហេតុអ្វីបានជាថា ពិធីនេះធ្វើឲ្យកើតនូវសេចក្ដីតក់ស្លុតនឹងទុក្ខវេទនាដល់មាណព? តែលុះដល់សម្លឹងមើលតាមដៃដែលមាណពចង្អុលទៅ ក៏ផ្លាស់ទឹកមុខតបថា:

"ខ្ញុំយល់ថា ជាកន្ទួនដែលគេធ្វើសម្រាប់ឲ្យទឹកហូរមកកាន់គំនរភ្លើង" ។

— មិនមែនទេ ! សេចក្ដីចូលចិត្តរបស់លោកយ៉ាងនេះមិនត្រូវសោះ សេចក្ដីពិត ទរនេះគេធ្វើទុកបំរុងចាំដល់វេលាណាដែលគេនាំសត្វរស់ៗ មកដាក់លើទែនរៀបរយហើយ គេក៏អារកសត្វនោះឲ្យឈាមហូរបាញ់ចេញតាមបំពង់កធ្លាក់ទៅក្នុងទរនេះ ទរនេះក៏គឺទរឈាមនោះឯង មិនមែនទរបង្ហូរទឹកទេ ខ្ញុំឃើញថាគួរស្ញប់ស្ញែងចាំងជាអំពើអាក្រក់ខ្លាំងណាស់ ។

អាមាត្យបាលិតស្តាប់ពាក្យមាណពដែលនិយាយអំពីចោរឈាមហើយ កាលពិចារណាទៅតាមពាក្យនោះ ក៏កើតមានសេចក្តីស្រៀវខ្លាចក្នុងការសម្លាប់សត្វទៀត :

"អើមាណព សូមអ្នកទុកឱកាសទំនេរគ្រាន់បានសន្ទនានឹងខ្ញុំទៀត ព្រោះខ្ញុំទើបនឹងមកដល់នគរនេះក្នុងថ្ងៃនេះឯង មិនទាន់រកទីស្នាក់បាននៅឡើយ ខ្ញុំមិនដឹងជានឹងទៅស្នាក់នៅទីណាទេ ខណៈនេះពេលក៏ជិតដល់ថ្ងៃត្រង់ហើយ ខ្ញុំចង់រកទីស្នាក់សម្រាកឲ្យបានសម្រេចជាមុនសិន" ។

មាណពទើបអញ្ជើញអមាត្យបាលិត :

" បើលោកមិនរង្កៀសទេ សូមអញ្ជើញទៅស្នាក់ជាមួយនឹងខ្ញុំចុះ ព្រោះខ្ញុំបានជួលផ្ទះមួយនៅទីបរិវេណផ្សារ មិនឆ្ងាយអំពីព្រះពន្លាំងនេះប៉ុន្មាន " ។

អមាត្យខ្លាចចិត្តមាណពពន់ពេកទើបតបថា :

"ក្រែងជាការលំបាកដល់លោកនឹងពួកមិត្ត ឬមនុស្សដទៃដែលមកជាមួយនឹងលោកទេដឹង ! បើដូច្នេះសូមកុំលោកព្រួយចុះ គ្រាន់តែប្រាប់ខ្ញុំអំពីទីស្នាក់ដែលល្មមរកបាននៅទីដទៃ ខ្ញុំអរគុណណាស់ហើយ" ។

" មិនមានទេណាទេលោក ! ខ្ញុំនៅតែម្នាក់ឯង, ទាំងផ្ទះស្នាក់ខ្ញុំក៏ទូលាយមានបន្ទប់នៅសល់ទៀត គួរនៅដោយសប្បាយ ផ្ទះសំណាក់នោះតាំងនៅក្បែរមាត់ទឹក, ខ្ញុំកំពុងចង់បានមិត្តម្នាក់ ក៏ទទួលបានមកជួបនឹងលោក ខ្ញុំអរណាស់" ។

(មានត)

## រឿងភ្នំសំពៅនៅខេត្តបាត់ដំបង

និង

## រឿងភ្នំម្ដាយដឹងក្លួននៅវៀតណាមខាងត្បូង

ជារឿងព្រេង

### អ្នកស្រីពេជ្រ-សល់ ហៅសារិះយ៉ាន

ប្រែប្រៀង

---

## រឿងភ្នំសំពៅនៅខេត្តបាត់ដំបង

ភ្នំសំពៅនៅខេត្តបាត់ដំបងក្នុងប្រទេសកម្ពុជាយើងនេះ មានរឿងព្រេងដំណាលថា ក្នុងកាលកន្លងទៅយូរហើយ មានព្រះមហាក្សត្រមួយអង្គព្រះនាម រាជិកុល សោយរាជ្យនៅប្រទេសកម្ពុជា ។ ព្រះបាទរាជកុលទ្រង់សព្វព្រះរាជហឫទ័យ នឹងស្រីម្នាក់ឈ្មោះនាង សុវណ្ណមសា នាងនេះជាកូនអ្នកក្រីក្រទេ ប៉ុន្តែនាងមានរូបឆោមស័ក្តិសមល្អណាស់ នាងចិញ្ចឹមសត្វក្រពើមួយ ដែលមានរិទ្ធិក្លាហាន ឆ្លាតវាងវៃណាស់ ទោះបីនឹងប្រើឲ្យធ្វើអ្វីក៏បានទាំងអស់ ។ ក្រពើនោះមានខ្លួនធំលើសប្រមាណ នាងឲ្យឈ្មោះអាធន់ ។ តាមដំណាលថា នាងសុវណ្ណមសារើសបានពងសត្វមួយយកមកទុក តែនាងមិនស្គាល់ជាពងសត្វអ្វីទេ ប៉ុន្តែលុះដល់ថ្ងៃខែទីងញាស់ ស្រាប់តែឃើញចេញកូនក្រពើមក ។ នាងក៏ចេះតែអាណិតខំចិញ្ចឹមថែរក្សាដោយពេញចិត្តណាស់ ក្រពើនោះទៀតសោត ក៏ប្លែកពីក្រពើទាំងពួង ចេះស្ដាប់បង្គាប់នាងដូចជាមនុស្សស្មោះសាច ។

ឯព្រះបាទពជកុល លុះបាននាងសុវណ្ណមសាមកជាគូស្នេហាហើយ មិនយូរប៉ុន្មានក៏មានព្រះទ័យពុំសូវស្ងុំគ្រោះ ដោយទ្រង់ព្រះចិន្តាឃើញថា ទឹងលើកនាងជាអគ្គមហេសីពេញទីពុំបាន ព្រោះនាងជាកស្ត្រីមានឋានៈពុំស្មើ ពុំសមទឹងរៀបអភិសេកជាឯកអគ្គមហេសីសោះ ។ លុះទ្រង់គិតដូច្នេះហើយ ទ្រង់ស្តេចទៅក្រាបទូលព្រះវររាជបិតាមាតា ។ ក៏ទ្រង់យល់តាមហើយចាត់ឲ្យស៊ើបសួររកស្រីឯណាដែលមានពូជពង្សត្រកូលខ្ពង់ខ្ពស់ ដើម្បីទឹងរៀបអភិសេកជាមួយនឹងព្រះរាជបុត្រារបស់ព្រះអង្គ ។ យូរបន្តិចមក ឮដំណឹងថា នៅស្រុកចន្ទបុរី មានស្តេចមួយព្រះអង្គ មានព្រះរាជបុត្រីមួយព្រះនាមនាង រំសាយសក់ ព្រោះនាងមានសក់ទិព្វ ចង់ប្រាថ្នាអ្វីក៏បានដូចចិត្ត ។ គឺនាងគ្រាន់តែបួតសក់ទៅចង់ឲ្យទឹកសមុទ្រខះទៅជាដីគោកក៏បាន ចង់ឲ្យដីគោកក្លាយទៅជាទឹកសមុទ្រក៏បាន ។ ទើបមាតាបិតាព្រះបាទពជកុល ប្រើសេនាឲ្យនាំសារទៅថ្វាយស្តេចក្រុងចន្ទបុរី ដើម្បីដណ្តឹងនាងនោះតាមច្បាប់ប្រវេណី ។ ស្តេចក្រុងចន្ទបុរីក៏ពុំទ្រង់យល់ទាស់ឡើយ ទ្រង់ក៏បង្គាប់ឲ្យលើកបណ្ណាការមក ។ សេនាបានទទួលព្រះរាជឱង្ការ ហើយក្រាបបង្គំលាត្រឡប់មកក្រាបទូលព្រះវររាជមាតាបិតានៃព្រះបាទពជកុលសព្វគ្រប់តាមដំណើរនោះ ព្រះបាទពជកុលទ្រង់បានព្រះសណ្តាប់ដូច្នោះ ក៏មានព្រះទ័យសោមនស្សជាពន់ពេក ទើបទ្រង់ត្រាស់បង្គាប់រៀបចំគ្រឿងបណ្ណាការយ៉ាងឧឡារិកផ្ទុកក្នុងសំពៅ ដើម្បីធ្វើដំណើរចេញទៅកាន់ក្រុងចន្ទបុរី ។

ចំណែកនាងសុវណ្ណមសាបានដឹងដំណឹងនេះកាលណា ក៏កើតចិត្តក្តៅក្រហាយខ្លាំងណាស់ ទើបប្រើក្រពើឲ្យទៅតាមកល់សំពៅនោះឲ្យលិចវិនាសអន្តរាយ កុំឲ្យព្រះបាទពជកុលបានទៅជួបនឹងនាងរំសាយសក់ ៗ ក្រពើនោះក៏ប្រើបានដូចចិត្តទៀត ក៏បោះពួយកន្ទុយទឹកលឿនដូចព្រួញ លុះដិតដល់ទៅសំពៅព្រះបាទពជកុល ៗ ទ្រង់ក្រឡេកឃើញអាជន់ ក៏ទ្រង់មានព្រះបន្ទូលយ៉ាងខ្លាំង ៗ ប្រាប់ថា ៖

– នែអាជន់ អញទេ កុំមកធ្វើផ្តេសផ្តាស!

អាជន់ឆ្លើយទៅវិញថា ៖

– ស៊ីបាយអ្នកណា យកអាសាអ្នកនោះ ៗ

ពួកពលក្រឡេកឃើញក្រពើធំសំបើម ក៏ភ័យស្រែកឆោឡោពេញទាំងសំពៅ ខ្លះបោះត្រឡាច ក្រពៅ ទ្រង់មាន់ ទ្រង់ទាឲ្យអាជន់ឈប់ស៊ី ដើម្បីឲ្យឃ្លាតឆ្ងាយអំពីសំពៅ តែអាជន់ពុំទទួលស៊ីសោះ ៗ ព្រះបាទពជកុលក៏បួងសួងអស់ទេវតាសូមឲ្យលោកជួយឲ្យផុតពីគ្រោះថ្នាក់ ៗ

ដោយបុណ្យបារមីព្រះអង្គ សេចក្តីបួងសួងនេះ ក៏រំជួលទៅដល់ព្រះឥន្ទ្រាធិរាជ ៗ ក៏ប្រើបំរើឲ្យទៅប្រាប់នាងរំសាយសក់ភ្លាម ៗ នាងរំសាយសក់ក៏បាចព្រះកេសឲ្យទឹកសមុទ្រខះរីងទៅជាដីទាំងអស់ ៗ ឯក្រពើក៏ជាប់កន្ទុយនៅដីនោះដែរ តែមុននឹងស្លាប់ ក្រពើនោះគោះកន្ទុយផងរេកដង្ហើមផង ទាល់តែដាច់ខ្យល់ស្លាប់ ៗ គួខ្លួនក្រពើក៏ក្លាយទៅជាភ្នំមួយធំ ហៅ ភ្នំក្រពើ ទាល់តែដល់សព្វថ្ងៃនេះ ៗ ត្រង់កន្លែងក្រពើគោះកន្ទុយនឹងត្រង់ច្រមុះក្រពើ ក៏ក្លាយទៅជាបឹងទាំងពីរនៅដល់សព្វថ្ងៃ

នេះដែរ ហៅ បឹងកន្ទុយក្រពើ និង បឹងប្រមុះក្រពើ ។ ឯសំពៅនោះក៏ក្លាយទៅជាភ្នំមានរាងជាសំពៅសុទ្ធ ហៅ ភ្នំសំពៅ តែផ្អៀងបន្តិច ព្រោះលោកបោកខ្លាំងណាស់នៅពេលដែលអាធន់ជិតទៅដល់សំពៅ ។ ក្ដោងសំពៅក៏សន្ទុកធ្លាក់ទៅក្នុងទឹក ហើយក្លាយទៅជាភ្នំមួយហៅ ភ្នំក្ដោងសំពៅ រាល់សព្វថ្ងៃនេះ ។

ព្រះបាទរាជកុល លុះសមុទ្រក្លាយទៅជាដី ក៏ប្រើពួកពលឲ្យជញ្ជូនប្រដាប់ប្រដាទាំងពួងដើរទៅកាន់ក្រុងចន្ទបុរី ដើម្បីរៀបអភិសេកជាមួយនឹងនាងរំសាយសក់តាមប្រវេណីទៅ ។ កន្លែងដែលនាងបួងសក់នោះក៏ក្លាយទៅជាភ្នំមួយនៅខាងត្បូងភ្នំសំពៅ ហៅ ភ្នំរំសាយសក់ នៅដល់សព្វថ្ងៃ ។

លុះរៀបអភិសេកស្រេចហើយ ព្រះបាទរាជកុល ទ្រង់នាំនាងរំសាយសក់ជាអគ្គមហេសី ព្រមទាំងពលសេនាជាច្រើនត្រឡប់ទៅកាន់រាជបុរីវិញ ។ ព្រះអង្គទ្រង់គង់លើដំរីជាមួយនឹងភរិយាមានពលហែហមមកជាច្រើន ។ មកដល់ពាក់កណ្ដាលផ្លូវទ្រង់ក្រឡេកទៅឃើញភ្នំសំពៅភ្នំក្រពើ ទ្រង់នឹកទោមនស្សជាខ្លាំងនឹងនាងសុវណ្ណមសា ថាព្រោះតែកាចចិត្តអាក្រក់បានជាឲ្យគេស្លាប់វិនាសអស់យ៉ាងនេះ ។ ព្រះអង្គក៏ទ្រង់ប្រើឲ្យសេនាទៅចាប់នាងសុវណ្ណមសាមកសម្លាប់ចោល សេនាក៏ធ្វើតាមព្រះរាជបញ្ជាចាប់នាងសុវណ្ណមសាមកកាត់ក្បាលសងសឹកវិញ ចោលទៅកើតជាភ្នំមួយ ហៅ ភ្នំសងក្បាល នៅជិតស្រុកមង្គលបុរីសព្វថ្ងៃនេះ ប៉ុន្តែ

ពាក្យអ្នកស្រុកហៅក្លាយទៅជា ភ្នំសង់ក្បាន ទៅវិញ ។ មានវាលមួយនៅជិតភ្នំនោះ សព្វថ្ងៃហៅ វាលបញ្ជាំពោះ ព្រោះពួកសេនាចញ្ជ្រាំពោះវៀននាងពេលនៅទីនោះ; ឯយានរបស់នាង សេនាបានអារគ្រវែងពេលទៅកើតជាភ្នំមួយទៀត ហៅ ភ្នំក្រពាយនាង ហៅក្លាយ ៗ មកទៀតទៅជា ភ្នំបន្ទាយនាង ។

ចំណែកព្រះបាទពជកុល នឹងព្រះអគ្គមហេសីយាងចូលទៅថ្វាយបង្គំព្រះវររាជមាតាបិតាវិញ ហើយទ្រង់គង់នៅជាសុខសាន្តរៀងរៀងជាតទៅ ។

## រឿងភ្នំម្ដាយនឹងកូន

បើកាលណាគេធ្វើដំណើរពី " បាទមីជួត " ទៅ " និងហ្វា " គេនឹងឃើញរូបភាពថ្មធំជាមនុស្សពកូនទៅលើកំពូលភ្នំមួយ ដែលយួនហៅថា " ភ្នំម្ដាយពកូន " ។

ភ្នំនេះមានរឿងព្រេងដំណាលថា កាលនោះមានបុរសក្មេងម្នាក់អាយុប្រមាណជា ១៧ ឆ្នាំ គាប់នឹងឆ្នាំជូត ។ បុរសនេះចេះតែមានចិត្តចង់បានប្រពន្ធ ការរិតក្ដនេះក៏កាន់តែដុះថ្មោសឡើងមួយថ្ងៃបន្តិច ៗ ទាល់តែបុរសនោះទ្រាំពុំបាន ក៏រកហោរម្នាក់ដែលជំនាញឲ្យមកទាយរកគូព្រេងឲ្យ ។

កាលពីបុរាណ គ្រូហោរច្រើនតែចេះកាព្យ ហើយជាអ្នកគណិតសាស្ត្រផងដើម្បីនឹងគន់គូរមើលពេលវេលាទៅអនាគត ។ លុះគន់គូរទៅឃើញការចំឡែកក្នុងអនាគតនៃបុរសក្មេងនេះ ហោរក៏ស្មានថាខ្លួនច្រឡំ

លេខ ប្ដីខ្លួនមានស្មារតីវិកលចរិត គាត់មិនព្រមទាយឲ្យបុរសនោះសោះ តែដោយបុរសនោះបង្ខំពេក គាត់ក៏ប្រាប់ថា "ឱកូនអើយ ! ទំនាយគេម្ដងនេះដូចជាផ្អែកណាស់ លេខឆ្លើយថាគូព្រេងអ្នក គឺប្អូនស្រីអ្នកនេះឯង ហើយអ្នកនឹងបានក្រេបនូវសេចក្ដីស្នេហាមួយយ៉ាងធំបំផុត" ។

លុះបានស្ដាប់សំដីហោរកាលណា បុរសឆ្លើយទៅវិញថា ៖ "ខ្ញុំមិនជឿទេ, ប៉ុន្តែចិត្តខ្ញុំត្រូវការស្នេហានឹងអ្នកដទៃក្រៅវិញ" ថាតែប៉ុណ្ណោះ បុរសក៏រត់ចេញពីមុខហោរទៅ ទឹកក្ដៅចិត្តថា ចុះហោរចំកួតនេះ និយាយអ្វីដូច្នេះ ។ លុះដល់ទៅផ្ទះឃើញមុខប្អូនស្រី, បុរសចេះតែមួម៉ៅក្ដៅក្រហាយ ។ ប្រាំឆ្នាំក្រោយមកឪពុកម្ដាយ ក៏ស្លាប់ចោលអស់ បុរសកំព្រានៅជាមួយប្អូនស្រី រកបានព្រឹកខ្វះល្ងាច រងទុក្ខវេទនាជាមួយគ្នាជាអនេក ។ ប៉ុន្តែកាលណាបុរសនឹកដល់ពាក្យហោរទាយ ក៏កើតចិត្តស្អប់ខ្ពើមប្អូនស្រីក្រៃពេក ។

ថ្ងៃមួយ ដោយមានមានៈនឹងកសនារបស់ខ្លួន បុរសពុំចង់ទុកឲ្យការអាក្រក់នេះបានសម្រេច ។ គិតហើយបុរសក៏ទ្រាក់ពូថៅដោយដៃម្ខាង ទាញប្អូនស្រីដោយដៃម្ខាងនាំចូលទៅក្នុងព្រៃមួយជ្រៅៗ ឯប្អូនស្រីហោត ដោយពុំបានដឹងខ្លួន ស្មានថាបងធ្វើលេង ចេះតែសើចហើយបណ្ដោយឲ្យបងអូសហូតដល់ក្នុងព្រៃជ្រៅងងឹត ដែលមានពន្លឺថ្ងៃចូលតាមតែចន្លោះស្លឹកឈើ ។ បុរសយារពូថៅសំពងក្បាលប្អូនប៉ុង ហើយដោយអំណាចភ័យនឹងប្រព្រឹត្តអំពើឃាតកម្មផង ដោយអាណិតប្អូនផង ដោយឃើញប្អូនដេកស្លូតនៅដីគ្មានស្មារតីផង បុរសតក់ស្លុតខ្លាំងណាស់ ខំស្ទុះរត់

ចេញពីព្រៃលែងអាកក្រោយ គិតតែរត់ឲ្យខានតែបានឆ្ងាយទាល់តែអស់ជើង ទៅទៀតពុំរួច ។

ក្រោយអំពីពេលអាសន្នធំនោះមក បុរសក៏បានសេចក្ដីក្សេមក្សាន្តហាក់ដូចជាបានបំរះរួចអំពីចំណង់អ្វីមួយ ឬដូចជាបានដោះស្រាយបញ្ហាមួយដែលមានន័យដល់ទៅពីរ ឬថាដូចជារត់រួចអំពីចំណោមមនុស្សដែលមានចិត្តស្ពួរកន្ទ្រើស ។ ពីរបីឆ្នាំក្រោយមក បុរសក៏រៀបការនឹងស្រីម្នាក់ដែលខ្លួនពេញចិត្ត នាងនោះមានកងការតូច ទឹកដមក្អែកនាងធ្វើឲ្យគេសំគាល់បានថា នាងជាមនុស្សស្លូតត្រង់ គ្មានពុតអាក្រក់ ។ បុរសនឹកថា « តែប៉ុណ្ណេះហើយអញឆ្ងាយពីពាក្យហោរទាយប្រាកដ » ។

បុរសនឹងប្រពន្ធស្រឡាញ់គ្នាណាស់ ប្រពន្ធយល់អធ្យាស្រ័យប្ដី ។ យកអាសាប្រពន្ធ មិនដែលមានរឿងកករល្អក់អ្វីឡើយ ។ លុះដល់បុរសមានកូន ហើយកូននោះចេះដើរចេះស្ដី ក្នុងគ្រួសារបុរសក៏កាន់តែមានការសប្បាយច្រើនឡើងទៀត ។ ប្រពន្ធនៅតែផ្ទះមើលថែទាំធ្វើអ្វីៗកុំឲ្យតែប្ដីទាស់ចិត្ត ឯប្ដីទៀតសោត តែកាលណាធ្វើការងាររួចហើយ ចូលចិត្តមកលេងបញ្ញាក់ប្រពន្ធលេង ថ្ងៃមួយនាងប្រពន្ធស្រាយក្បួងសក់លាងសំអាតសក់ ហើយដោយសក់នៅទទឹក នាងក៏មិនប្រញាប់នឹងបួងសក់ទៅវិញ ទុកសំផលឲ្យសក់ស្ងួតសិន ។ នៅពេលនោះបុរសប្ដីត្រឡប់មកផ្ទះវិញ ហើយអង្គុយលេងនឹងប្រពន្ធ ។ ជាទេសកាលអ្វីក៏នាំចិត្តនាងឲ្យប្រញាប់ប្រមូលសក់ឡើងបួង លើកផុតអំពីកញ្ចឹងក ។ បុរសប្ដីក្រឡេកភ្នែកទៅឃើញស្នាមនៅក្បាលខាងក្រោយ ស្រាប់តែដូចជាមាន

ខ្យល់ក៏បុកត្បូងកំណាចមួយមកត្រូវបុរសស្ទើរតែបាត់ស្មារតី អ្នកនឹកឃើញប្អូនដែលអ្នកបានបង់សម្លាប់ បុរសស្ទុះទៅចាប់ដៃប្រពន្ធសួរទាំងញ័រចម្រប់ថា “ អ្នកណាធ្វើឲ្យអូនមានស្នាមត្រង់ហ្នឹង ? ” ប្រពន្ធដោយពុំបានដឹងរឿងអ្វី ក៏និយាយរឿងរ៉ាវដែលនាងចាំស្រពេចស្រពិលប្រាប់ប្ដីថា ៖ “ នៅពេលដែលនាងត្រូវបួសសន្ទប់ ពួកចោរបានរើសនាងទៅ ហើយយកទៅលក់ឲ្យគេ ដល់នាងធំដឹងក្ដីកាលណាឡើង នាងនៅតែនឹកខឹងនឹងបង ដោយនាងមិនយល់ថាហេតុអ្វីបានជាបង់សម្លាប់នាងដូច្នេះ ” ។

ចំណែកបុរសជាប្ដី ដែលទទួលសំដីនាងមួយម៉ាត់ៗ ដូចជាទទួលមុខកាំបិត ទោះជាអ្នកខំប្រឆាំងនឹងសេចក្ដីពិតយ៉ាងណា ក៏អ្នកនៅតែមានចិត្តតក់ស្លុត ព្រមទាំងឃើញវាសនាដែលអ្នកជៀសពុំរួចមកតាមទាន់អ្នកវង្វេងស្មារតីដូចជាមនុស្សស្រវឹង តែអ្នកខំទប់ចិត្តមិនធ្វើឲ្យប្រពន្ធដឹង ហើយក៏ដើរចេញពីផ្ទះទៅទាំងក្រៀមក្រំ ដូចជាមនុស្សវិកលចរិត ។

លុះព្រលប់ប្រពន្ធចាំប្ដីបាត់ទៅៗ មិនឃើញត្រឡប់មកផ្ទះវិញ នាងពកូនដើរតាមរកប្ដី នាងឡើងទៅអង្គុយលើភ្នំមើលទៅឆ្ងាយក្រែងឃើញប្ដី តែមួយថ្ងៃជាមួយថ្ងៃ នាងចាំបាត់ៗ ទាល់តែរូបនាងនិងកូនក្លាយទៅជាថ្មនៅលើភ្នំនោះ, អ្នកស្រុកទើបហៅភ្នំនោះថា “ ភ្នំម្ដាយនឹងកូន ” ។

# រឿងសាមកុក

## កណ្ឌទី ២៣

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ស៊ីឡ្យងឆ្លើយទូលថា ខ្ញុំបាទនឹងសុំយកអាសា ទៅចាប់ខ្លួនង៉ាន់លៀងមកឲ្យបាន ។ ចូចូក៏ប្រគល់ទាហានឲ្យស៊ីឡ្យងលើកចេញទៅតតាំងច្បាំងនឹងង៉ាន់លៀងបាន ២០ ភ្លេង ស៊ីឡ្យងធន់កម្លាំងនឹងង៉ាន់លៀងមិនបានក៏ថយត្រឡប់មកចូលបន្ទាយវិញ ។ បណ្ដាទាហានឃើញដូច្នោះក៏តូចចិត្តគ្រប់គ្នា ទទួលពេលព្រលប់យប់ងងឹតទ័ពទាំងសងខាងក៏ត្រូវរក្សាបន្ទាយរៀងខ្លួន ។ ចូចូប្រឹក្សានឹងសេនាទាហានទាំងពួងថានរណានឹងអាចតទល់កម្លាំងនឹងង៉ាន់លៀងបាន ។ ស៊ីម៉ុងថាខ្ញុំបាទយល់ឃើញតែគួនអ៊ូ ១ មានកម្លាំងខ្លាំងពូកែអាចតច្បាំងនឹងង៉ាន់លៀងបាន ។ ចូចូថាបើយើងនឹងឲ្យទៅហៅគួនអ៊ូមកធ្វើការគ្រានេះ បើគួនអ៊ូច្បាំងមានជ័យក៏នឹងដោះដៃទៅពីយើងជាអសារ ។ ស៊ីឡ្យងឆ្លើយថា ខ្ញុំបាទយល់ឃើញ

ថាឡោពីទៅអាស្រ័យនៅនឹងអ៊ួនសៀវ បើប្រសិនគួនអ៊ូសម្លាប់សេនាទាហានអ៊ួនសៀវម្នាក់នេះបាន អ៊ួនសៀវដឹងក៏នឹងសម្លាប់ឡោពីជាប្រាកដ បើឡោពីអស់ជីវិតកាលណា គួនអ៊ូក៏អស់ប្រាជ្ញានឹងទៅរក មុខជាបានមកធ្វើកម្លាំងៈនៅនឹងយើងតទៅ ។ ប៊ូឆ៊ូយល់ឃើញត្រូវក៏ប្រើទាហានទៅហៅគួនអ៊ូជាប្រញាប់ ទាហានក៏ចូលទៅប្រាប់គួនអ៊ូថា មហាឧបរាជឲ្យអញ្ជើញលោកទៅឯកងទ័ព ។ គួនអ៊ូបានស្តាប់ក៏រៀបខ្លួនចូលទៅដល់មាត់ទ្វារគំនាប់បងថៃទាំង ២ ថា ឥឡូវមហាឧបរាជឲ្យមកហៅខ្ញុំបាទទៅធ្វើការសឹកសង្គ្រាម ។ បងថៃទាំង ២ ក៏ឆ្លើយតបភ្លាមថា ប្អូនទៅធ្វើការឲ្យមានជ័យជំនះឈ្នះសត្រូវចុះ តែឲ្យចាំស្តាប់ដំណឹងជាបងប្រុសអ្នកនៅឯណា ។ គួនអ៊ូក៏គំនាប់លាបងថៃចេញមក យកសេះសឹកជាវជាជំនិះ គួនអ៊ូក៏ឡើងជិះកាន់ដាវនាំទាហានប្រហែល ១០ នាក់ចេញមកក្រៅ បរស្រូតទៅដល់បន្ទាយប៊ូឆ៊ូ ។ ក្រឡេកឃើញគួនអ៊ូទៅដល់ ក៏មានសេចក្តីត្រេកអរណាស់និយាយថា ង៉ាន់លៀងសេនាអ៊ួនសៀវមានចំដៃខ្លាំងពូកែ សម្លាប់ស៊ុងហៀននឹងនុយសុកស្លាប់ទៅហើយ យើងទើបឲ្យទៅរកអ្នកប្រាជ្ញាដើម្បីនឹងឲ្យជួយលៃលកចូលច្បាំងនឹងង៉ាន់លៀងសងសឹកវិញ ។ គួនអ៊ូឆ្លើយថា ខ្ញុំបាទនឹងសុំចេញទៅមើលកលការសិន ។ ប៊ូឆ៊ូក៏នាំគួនអ៊ូឡើងទៅលើភ្នំ ទទួលក្រឡេកឃើញង៉ាន់លៀងលើកទាហានចេញមកជិតមុខបន្ទាយ ប៊ូឆ៊ូក៏និយាយប្រាប់គួនអ៊ូថា អ្នកមើលទៅចុះ ដែលជិះសេះបាំងឆ័ត្រកាយនោះឈ្មោះង៉ាន់លៀងជានាយទាហានទ័ពមុខ ។ គួនអ៊ូថា ង៉ាន់លៀងនោះខ្ញុំបាទនឹងតស៊ូបាន លោកកុំវិតក្កឡើយ

ខ្ញុំបាទទីងទៅកាត់ក្បាលឆាន់លៀងយកមកជូនលោកឲ្យបាន ។ ចុច្ច
ក៏និយាយទីងគួនអ៊ូថា អ្នកកុំអាលប្រមាទមើលងាយឆាន់លៀងនោះ
ឡើយ ។ គួនអ៊ូថាខ្ញុំបាទក៏មានថ្វីដៃខ្វះដែរ បានជាហ៊ានសុំយកអាសា
ទៅកាត់ក្បាលឆាន់លៀងមកជូនលោក ព្រោះឃើញថាមិនជាការក្រ
លំបាកប៉ុន្មាន ប្រមាដូចយកចង្កើសតាប់ដុំសាច់បរិភោគ ។

ឆៀវលៀវបានស្ដាប់ពាក្យនិយាយតបទៅគួនអ៊ូថា ឯធម្មតាការសឹក
សង្គ្រាមនោះ បើទីងនិយាយការអ្វីដល់មេទ័ពមេកង ប្ដូរប្រមាណការ
នោះឲ្យទៀងទាត់ប្រាកដសិនសឹមនិយាយ ។ គួនអ៊ូថា "អ្នកកុំព្រួយ
រំលឹកខ្ញុំឡើយ" ហើយក៏លាចុច្ចឡើងសេះបំផាយពុះទាហានឆាន់លៀង
ចូលទៅ, ឯទាហានឆាន់លៀងមិនទាន់ដឹងខ្លួន លុះឃើញគួនអ៊ូបំផាយ
សេះទំលុះចូលមក ក៏ភ័យតក់ស្លុតទាំងអស់គ្នានាំគ្នាស្ទុះរត់ខ្ចាត់ខ្ចាយចេញ
ទៅជាច្រើន ។ គួនអ៊ូក៏បរសេះបំផាយចូលទៅដោយកំឡាំងដ៏រហ័ស
ជិតទីងបះទំគិចទីងសេះឆាន់លៀង។ ក្រឡេកឃើញសេនាមុខក្រហមប្លែក
ខុសពីទាហានធម្មតា, ក៏សំគាល់ថាប្រហែលគួនអ៊ូប្អូនឡៅពី ហៀប
ទីងហាមាត់ប្រាប់ដំណឹងពីឡៅពីតែប្រាប់មិនទាន់ ទួលគួនអ៊ូលើកដាវ
ឡើងកាប់កឆាន់លៀងដាច់ជ្រុះធ្លាក់ទៅដី ។ ទាហានចុច្ចឃើញដូច្នោះ
ក៏ស្ទុះស្រែចូលទៅសំដៅកាប់តាក់ ទាហានឆាន់លៀងស្លាប់ពីការជាច្រើន
ហើយរើសយកគ្រឿងសស្ត្រាវុធបានជាច្រើន ។ គួនអ៊ូក៏លើកយក
ក្បាលឆាន់លៀងយួរចូលទៅជូនចុច្ចក្នុងបន្ទាយ ចុច្ចក្រឡេកឃើញទួល

អំណរណាស់ សរសើរគួនអ៊ូថា ខ្លួនអ្នកនេះមិនមែនទាហានមនុស្សធម្មតា ដែលមានថ្វីដៃវៃរហ័សដូច្នេះ សមជាទាហានទេវតា ។

គួនអ៊ូឮចូចថាដូច្នោះ ក៏ក្រាបទូលខ្លួនថាថ្វីដៃខ្ញុំបាទប៉ុណ្ណេះគ្រាន់តែជាប្រមាណ ប្អូនខ្ញុំឈ្មោះតៀវហ៊ុយមានកំឡាំងថ្វីដៃខ្លាំងពូកែលើសខ្ញុំបាទទៅទៀត ទោះទាហានប៉ុន្មានរយម៉ឺនការពារនាយទ័ពដូចម្ដេចក្ដី តៀវ-ហ៊ុយក៏អាចចំលុះតុះពារទៅកាត់ក្បាលយកមកបានដោយរហ័ស ឧបមាដូចគេចាប់យកផ្លែក្រូចនៅក្នុងឡាំង ។

ចូចបានឮដូច្នោះក៏គិតញញើតខ្លាចថ្វីដៃតៀវហ៊ុយ ទើបបង្គាប់ពួកទាហានឲ្យសរសេរអក្សរទុកក្នុងអាវគ្រប់គ្នាថា បើនរណាជួបប្រទះនឹងតៀវហ៊ុយក៏កុំអាលតស៊ូច្បាំងឲ្យរង់ស្ដាប់កំឡាំងមើលសិន ។

ឯទាហានង៉ាន់លៀង ក៏បែកខ្ចាត់ខ្ចាយរត់ទៅដល់កងទ័ពអ៊ួនសៀវ ហើយចូលទៅអធិប្បាយរឿងរ៉ាវឲ្យអ៊ួនសៀវស្ដាប់គ្រប់ប្រការ, អ៊ួនសៀវបានឮដូច្នោះក៏ភ័យស្លុតចិត្ត ហើយគិតពិកាល់ថា ពីដើមមកមិនបានប្រាកដជាទាហានចូចមុខក្រហមពុកមាត់វែង មានកំឡាំងខ្លាំងពូកែដូច្នេះសោះ ។ ឈ័ស៊ុីវថាទាហានមុខក្រហមពុកមាត់វែងនោះ ខ្ញុំបាទស្មានថា ប្រាកដជាគួនអ៊ូប្អូនឡាវពីនោះឯង ឯអ្នកដទៃក៏មិនបានស្គាល់ជាប្រាកដ ។ អ៊ួន-សៀវបានស្ដាប់ក៏ខឹងណាស់ និយាយប្រាប់ឡាវពីថា "ប្អូនអ្នកឯងចូលទៅធ្វើសេនាចូច ហើយមកសម្លាប់សេនាឯករបស់យើងស្លាប់ដូច្នេះ ក៏ឃើញថាអ្នកឯងជាពួកម៉ាកខាងចូច ក្រែងមកនៅនឹងយើងជាកលសឹក

យើងនឹងចិញ្ចឹមទុកក៏មិនបាន" អ៊ួនសៀវក៏បង្គាប់ទាហានឲ្យចាប់ឡេវពីនឹងយកទៅសម្លាប់ ។

ឡេវពីបានឮដូច្នោះក៏ភ័យណាស់ និយាយទៅអ៊ួនសៀវវិញថា ហេតុម្ដេចលោកមកស្រាលត្រចៀកស្ដាប់តែពាក្យម្នាងដូច្នេះ សុំឲ្យលោកជំរះមើលឲ្យគួរសិន ខ្លួនខ្ញុំបាទបង់ស្រុកទេសទីងទិពសពាកបុត្រភរិយាទ្រព្យអស់ស្ម័គ្រចក្រពួកតែប្លួលមកជ្រកកោននៅនឹងលោកតែខ្លួន ១ ដោយហេតុចូចូលើកទ័ពមកធ្វើអន្តរាយ គួនអ៊ូគៀវហ៊ុយប្អូនខ្ញុំបាទទាំង ២ នាក់ ក៏ខ្ចាត់ខ្ចាយព្រាត់គ្នាទៅមិនដឹងជារស់ឬស្លាប់ សាបសូន្យដំណឹងសោះ ដែលថាទាហានមុខក្រហមពុកមាត់វែងនោះ នឹងបំពោះមានតែគួនអ៊ូ ១ ក៏ទេគង់មានរូបអ្នកឯទៀតទៅខ្វះដែរ លោកចូរពិគ្រោះពិចារណាឲ្យជួនថៃទៅសិន ។

អ៊ួនសៀវនោះជាមនុស្សមិនមានតារិកមាំមួន លុះបានស្ដាប់សំដីឡេវពីអធិប្បាយក៏រសាយកំហឹង ត្រឡប់គ្រោធខឹងនឹងឈើសីវវិញថា "ខ្លួនជាមនុស្សអ័ប្បឥតប្រាជ្ញា រកូងមកបរបាញ់ញុះញង់ឲ្យយើងសម្លាប់ឡេវពីដូច្នេះមិនគួរសោះ" ថាហើយក៏ក្រោកស្រើង ហៅឡេវពីទៅបរិភោគអាហារ ពិគ្រោះគ្នានឹងលើកទ័ពទៅកំចាត់ចូចូ ។

ប៊ុនធីវផឹកបអ៊ួនសៀវថា សេនាចូចូដែលសម្លាប់ឆាន់លៀងនោះ ខ្ញុំបាទនឹងសុំយកអាសាចេញទៅច្បាំងនឹងចូចូម្ដងទៀត ។ អ៊ួនសៀវឮហើយក៏ធ្វើយទទួល ព្រោះឃើញប៊ុនធីវមានកម្លាំងប្រើនខ្ពស់ ៦ ហត្ថ មុខខ្មៅដូចសម្បុរខ្លាឃ្មុំ ទាំងមានថ្វីដៃខ្លាំងពូកែសមគួរនឹងតតាំងច្បាំងនឹង

សេនាបច្ចបាន ទើបមានវាចាថា "អ្នកនឹងទទួលយកអាសាចេញទៅគ្រា នេះ យើងមានសេចក្ដីត្រេកអរណាស់" ហើយអ្នូនសៀវក៏ប្រគល់ ចាហានឲ្យប៊ុនធីវ ១០ ម៉ឺន ចាត់សុទ្ធតែទូកចំបាំងឲ្យប៊ុនធីវលើកចូលទន្ទ ហាងហោទៅតស៊ូនឹងបច្ច ។

ឈីស៊ីវដំកបអ្នូនសៀវថា បច្ចនោះជាមនុស្សប្រេះគិតល្អិតល្អណាស់ មានជ័យជំនះដូច្នេះហើយក៏មានបិត្តកំរើប ដែលលោកគិតស្រាលឲ្យប៊ុន ធីវលើកចូលទន្ទទៅនោះ ខ្លាចបច្ចជីងលើកចាហានមកចាំស្កាត់វាយកាត់ កណ្ដាលផ្លូវ ក៏នឹងត្រូវប៉ះការអេសារទទេ ។ អ្នូនសៀវត្រូហើយខឹង ណាស់ តំហកដេរឈីស៊ីវថា អាមនុស្សកំឡូអប្បសុតប្រាជ្ញា វាគិតការ ឲ្យតែយើងបង្ក្រៀត ។ ឈីស៊ីវមិនបានឆ្លើយទៀតថាម្ដេច គេចក្រោក ដើរទៅខាងក្រៅហើយក៏ដកដង្ហើមធំ និយាយកណ្ដាលចំប្រជុំចាហានថា អ្នកទាំងឡាយជានាយទ័ពនាយកងកលគ្នា បើនាយហៅហ្វាយយើងគិត ការបានសម្រេច យើងទាំងឡាយក៏បានរបួតរួចពីសេចក្ដីស្លាប់ បើហៅ- ហ្វាយនាយយើងមិនព្រមស្ដាប់ទំប្រឹក្សា ធ្វើការប្រមាថមើលងាយដល់ បច្ចដូច្នេះ យើងក៏យល់ថាគង់នឹងប៉ះការ នរណា ៗ ជួយរំលឹកពន្យល់ ក៏ចេះជឿស្ដាប់ អ្នកទាំងឡាយនឹងយកសាកអសុកមកចោលទុកនៅទីនេះ ជាប្រាកដហើយ ។ តាំងពីថ្ងៃនោះមកឈីស៊ីវក៏ធ្វើជាឈឺមិនបានទៅមក រកអ្នូនសៀវជួយប្រឹក្សាពិគ្រោះសោះ ។ ក្នុងខណៈនោះ អ្នូនសៀវ ក៏បង្គំចាត់ចែងឲ្យប៊ុនធីវលើកទ័ពទៅ ។

ទៀតពីក៏និយាយនឹងអ្នូនសៀវថា ខ្ញុំមកនៅជ្រកកោននឹងលោកក៏បាន

សេចក្ដីសុខ លោកមានគុណូបការនឹងខ្ញុំជាច្រើន ឥឡូវខ្ញុំសុំយកអាសាទៅជាមួយនឹងប៊ុនធីវ ដើម្បីជាទីតបស្នងសងគុណលោក ប្រការ១ នឹងបានស៊ើបមើលឲ្យដឹងឃើញថា ទាហានមុខក្រហមពុកមាត់វែងនោះប្រាកដជាគួនអ៊ូ ឬ អ្នកឯណាឯទៀតទេ ។ អួនសៀវបានស្ដាប់ដូច្នោះក៏មានសេចក្ដីត្រេកអរណាស់ និយាយនឹងប៊ុនធីវថា ឡេវពីជាមនុស្សមានសតិបញ្ញា យើងនឹងឲ្យចេញទៅជាមួយនឹងអ្នក ដើម្បីនឹងបានជួយគ្នាគិតការធ្វើសង្គ្រាមតនឹងប៊ូឆូ ។ ប៊ុនធីវតបថា ឡេវពីជាមនុស្សមានដំរេះប្រាជ្ញាមែនហើយ តែនៅខ្លាចថ្វីដៃប៊ូឆូ ដែលលោកនឹងឲ្យឡេវពីទៅជាមួយនឹងខ្ញុំនោះ ខ្ញុំនឹងបែងចែកទាហាន ៣ ម៉ឺនឲ្យឡេវពីលើកទៅជាកងមួយផ្សេង ។ អួនសៀវយល់ឃើញត្រូវក៏ប្រគល់ទាហាន ៣ ម៉ឺនឲ្យឡេវពីលើកចេញទៅជាកងក្រោយ ។ លុះបានឫក្សជោគល្អ ប៊ុនធីវក៏លាអួនសៀវលើកទ័ពចេញទៅជាកងមុខ ឆ្លងទន្លេហាងហោទៅ, តែឡេវពីចេញតាកទីនៅមិនទាន់ឆ្លងទន្លេ ។

ខណៈកាលប៊ូឆូមានជ័យជំនះនោះ ក៏មានចិត្តត្រេកអរសប្បាយតែងបុតហ្វាយស្មើគុណបំណាច់របស់គួនអ៊ូ ចូលទៅក្រាបទូលព្រះចៅហៀនតេ ។ ទ្រង់ជ្រាបសេចក្ដីក៏មានព្រះទ័យសោមនស្សពន់ប្រមាណ ទើបទ្រង់ព្រះរាជទានត្រាស្រមាប់ងារ តាំងគួនអ៊ូជា ហាក់ស៊ីតែងហៅ គឺមន្ត្រីមានយសខ្ពស់ធំក្នុងព្រះចៅហៀនតេ, បំរើក៏ទទួលយកត្រាតាំងនោះទៅប្រគល់ឲ្យគួនអ៊ូ ។ ទទួលបំរើសេះចូលមកប្រាប់ប៊ូឆូថា ឥឡូវអួនសៀវប្រើប៊ុនធីវឲ្យលើកទាហានមកប្រហែល ១០ ម៉ឺនឆ្លងទន្លេហាងហោ ។ (មានត)

ដំណើរតាមខ្យល់ក្នុងកាន្តារ:

# លោក ផេង-ជ្រើវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

*ប្រែពីភាសាបារាំងមកជាភាសាខ្មែរ*

(តមក)

---

អ៊ីស្មាអ៊ីលឆ្លើយថា:

— ព្រះតេជៈគុណវរសេនីយ៍ឯក! ខ្ញុំបាទបានជឿតែមួយយ៉ាង អំពីបទពាណិជ្ជកម្មប៉ុណ្ណោះ គឺថាជាតិអ៊ីរ៉ុបចេះរៀបចំ ហើយប្រសប់ជាងយើងជាតិអារ៉ាប់និងតួគី ។ សូមព្រះតេជព្រះគុណពិចារណាមើលនូវការអន្តរាយក្នុងផ្លូវគមនាគមន៍របស់យើងដែលមានពួកវិលុម្បកៈ ពួនស្ទាក់ចាំប្លន់ពួកឈ្មួញជានិច្ច ។ នៅបណ្តាពួកឈ្មួញទាំងនោះ បច្ចាមិត្តរបស់យើងតែងនឹងមានអ្នកបន្តនិយាយការណ៍ ដែលធ្លាប់ប្រសប់មានការទាក់ទងនឹងជាតិអ៊ីរ៉ុប ហើយមានគំនិតប្រាជ្ញាជាងអ្នកនៅភូមិ នឹងពួកបពចរក៍ទៅទៀត ។

« ផ្លូវណាដែលគ្មានវិលុម្បកកម្ម ហើយដំរំព្រឹក្សមានជាប់បន្តគ្នា រជឹកការៈពេលដំណើរក៏ខ្លីជាងពាក់កណ្តាល ។ ការដឹកលក់ផលិតផល អីវ៉ាន់របស់ជាតិអ៊ីរ៉ុប នឹងការទិញដូរទំនិញអ្នកស្រុកអាយក៏នឹងមិនសូវយូរដូចសព្វថ្ងៃនេះៗ ត្រូវគិតទុកបីឆ្នាំមុនឡើយហើយជាស្រេច រវាងការធ្វើដំណើរពីទ្រីប៉ូលីនឹងការត្រឡប់មកវិញរបស់ឈ្មួញម្នាក់ ។

លោកវរសេនីយ៍ឯក ទ្រង់គិតយូរ ៗ រំឭងខាងពាណិជ្ជកម្ម លោក

មិនបេះសោះ ។ លោកចេញមកពីសាលានាយពាហានជាន់ចាស់ដែលមានការបង្ហាត់តែអំពីកិច្ចសង្គ្រាម ជាការតយុទ្ធត្រូវមានជាវយ៉ាងមុត ត្រូវបណ្ដុះទ័ពឬត្រូវពាក់ស្រោមដៃឲ្យស្អាត ដើរពីមុខកងអនុសេនាធំ ។ លោកនេះមិនយល់អំពីសង្គ្រាមឥឡូវ គឺសង្គ្រាមខាងសេដ្ឋកិច្ចខ្លាំងជាងសង្គ្រាមនៅឯសមរភូមិ ។

ប្រាកដមែនហើយលោកអនុសេនីយ៍ឯកនេះផ្លាស់យោបល់ទាំងអស់ដោយកាន់គំនិតថ្មី ៗ មិនបាច់សង្ស័យឡើយ គឺប្រាកដជាមនុស្សក្បាលអាក្រក់ ។ លោកវរសេនីយ៍ឯកតាំងចាប់ផ្ដុំការយល់ហើយនិយាយថា:

– អើ! មែនហើយ អ៊ឺរ៉ុប!... អារ្យធម៌... លោកចូលចិត្តខាងណោះជាងអាណាចក្រតួរគី... យើងមិនគាប់ចិត្ត ដោយបាននាយពាហានបែបលោកនេះទេ !

ក្នុងឱកាសនោះ លោកវរសេនីយ៍ឯក ចាប់កាំបិតស្នាសម្រាប់កាត់ក្រដាសបង្វិលលេងចុះឡើង ហើយហាក់ដូចជាបញ្ជូនចិត្តទៅកាន់អារម្មណ៍ផ្សេងពីការសន្ទនាជាមួយនឹងអ៊ីស្មាអ៊ីល រួចស្រាប់តែបែរផ្ទាំងចំពោះអ្នកកំឡោះហើយសួរយ៉ាងខ្លីថា:

– ហេតុអ្វីបានជាលោកសម្លាប់ស៊ៀមបេន - អាប់ដាឡ្យ: នៅសម័យដែលគេប្រឹងនឹងធ្វើប្រតិបត្តិការតទប់នឹងពួកខ្មោល ?

អ៊ីស្មាអ៊ីលសំឡឹងចំលោកវរសេនីយ៍ឯកគ្មានព្រិចភ្នែក តែឥតមានឆ្លើយ ៗ

លោកមេទ័ពសួរទៀតថា:

– លោកមិនត្រូវយករឿងស្រីមកអាងដូចគេថាឡើយ ។

លោកមេទ័ពមានសេចក្តីសង្ឃឹមថា មុខជានឹងបានចម្លើយមួយមិនខាន អំពីអ៊ីស្មាអ៊ីល ទោះបីជាថាទេឬទទួលព្រម បើដ្បិតតែចិត្តលោករឹងរឹងរូស កាចអាក្រក់ ក៏លោកនៅមានសេចក្តីគោរពចំពោះការក្លាហានដែរ លោកឃើញកិរិយារបស់នាយទាហានកំឡោះ បរិបូណ៌ដោយការរឹងត្អឹងឥតញាប់ញ័រ ដោយសេចក្តីវិសារទៈឥតរន្ធត់, អាការទាំងនេះមិនមែនជាមិនធ្វើឲ្យលោកមេទ័ពរំជួលទេឡើយ ។ លោកមានបំណងនឹងចង់ជួយសង្គ្រោះអ៊ីស្មាអ៊ីលដែរ ប៉ុន្តែ រឹងរូសភាពនៃអ៊ីស្មាអ៊ីលនាំឲ្យលោកអនុសេនីយ៍ឯកមានទោសៈ ។

ឥឡូវបើអ៊ីស្មាអ៊ីលមិនព្រមឆ្លើយទទួលសារភាពថា មរណភាពនៃសៀម គឺជាមូលហេតុមកពីការប្រដែងប្រឆាំងគ្នាបែកខាងកាមភគទេ នោះទៀងតែមានមូលហេតុដទៃធ្វើឲ្យដៃគេកាន់អាវុធលើកឡើង ហើយការណ៍នេះឆាយយល់ពេក គឺគ្មានអ្វីក្រៅពីរឿងនយោបាយឡើយ ។

អ៊ីស្មាអ៊ីលសម្លាប់សៀម ដើម្បីបំបាត់ការជំនួយដ៏ថ្លៃថ្លារបស់ជាតិតួរគី ។

រឿងនេះជាឧក្រិដ្ឋទោសយ៉ាងធ្ងន់ហួសព្រំដែនទាំងឡាយ នៃមនុស្សឃាតកម្ម គេត្រូវទៅឆ្លើយនៅចំពោះមុខតុលាការសង្គ្រាម ។

លោកមេទ័ពដឹងច្បាស់ដោយការពិសោធន៍ថា ជាធម្មតា ការឃុំរបស់តុលាការសង្គ្រាមឥតមានមេត្តាករុណាឡើយ ហើយច្រើនតែមិនបាច់ហៅអ្នកទោសមកសួរផង ។

លោកមេទ័ពដកដង្ហើមធំ ហើយនិយាយថា:

អី លោកចេះតែចូលចិត្តនៅស្ងៀម . . . ការកុហករបស់លោកឈ្មោះថា ការប្រមាថមើលងាយដល់ព្រះអាឡស់ . . . ។

ឥឡូវនេះ នៅចំពោះមុខនៃហេសភាពឥតកំរើករបស់អ៊ីស្មាអ៊ីល, លោកមេទ័ពឈប់សង្ស័យតទៅទៀត គឺកូនប្រុសនៃលោកតាកា៊ុដប្រាកដជាមានទោសខាងបទនយោបាយ ។ បើដូច្នេះ មិនត្រូវមានចិត្តអាណិតដល់អ្នកទោសឡើយ ។ ប៉ុន្តែ លោកអនុសេនីយ៍ឯកនៅតែធ្វើយ៉ាងព្រងើយ យ៉ាងរឹងត្អឹង ឥតរន្ធត់ ។ គឺមិនមែនជាមិនស្តាយទេ ដែលលោកវរសេនីយ៍ឯកស្រែកហៅនាយទាហានរងឲ្យចូលមក ហើយបង្គាប់ថា:

— លោកអនុសេនីយ៍.អ៊ីស្មាអ៊ីលបេន-អៃយ៉ាដ ត្រូវការនៅក្នុងគុកងងឹតបន្ទប់លេខ ២ ។

នាយទាហានរងគំនាប់ ហើយចាត់ការតាមបទបញ្ជាភ្លាម ។ មនុស្សបួននាក់ ដាវនៅចុងកាំភ្លើងមកដល់មួយរំពេច ។ គេនាំគ្នាឈរព័ទ្ធអ៊ីស្មាអ៊ីល ហើយតាមការបង្គាប់នៃនាយទាហានរង គេបណ្តើរអនុសេនីយឯកជាបុត្រលោកតាអៃយ៉ាដសំដៅគុកក្នុងបន្ទាយ ។ ទ្វារគុកលេខ២បិទទៅវិញសូរគ្រាំង រក្សាទុកនូវគូសង្សារបស់នាងឡៃឡានៅខាងក្នុង ។

បន្ទប់គុកលេខ ២ នេះ គឺជាបន្ទប់ដែលបំរុងសម្រាប់ឃុំទុកនូវនាយទាហានណាដែលតុលាការសង្គ្រាមត្រូវជំនុំជំរះ គឺជាបន្ទប់សម្រាប់ស្លាប់!

*

* *

តាំងពីថ្ងៃដែលនាងខានបានសេចក្ដីសុខ ដោយបានជួបនឹងអ៊ីស្មាអ៊ីល ឡូឡាចេះតែស្រងូតស្រងាត់រីងរៃ ពោះបីមានការថែរក្សាដ៏សុខុមរបស់ស្ដ្រីជាមិត្រទាំងឡាយក៏ដោយ ។

នៅបណ្ដាក្រុមស្រីជាបរិវារទាំងនោះ គេគ្រាន់តែដឹងថា អ៊ីស្មាអ៊ីលចេញទៅធ្វើសង្គ្រាម តែប៉ុណ្ណោះទុកជាការស្រេច ។ គ្មានអ្នកណាដឹងច្បាស់នូវព្រេងវាសនារបស់គេទេ ។ ម្ល៉ោះហើយ ការសង្រែងសង្រែចេះតែលុកលុយក្នុងសន្ដាននៃនាងឡូឡា ។

អ៊ីស្មាអ៊ីល គឺជាគូសង្សារឯករបស់នាង នាងមានបំណងយ៉ាងធំហើយតែមួយក្នុងជីវិតនាង ។ ឥឡូវស្រាប់តែជម្នាតមកបំបែកនាងចេញទាំងក្ដៅស្រស់ ។

ក្នុងវេលា តាំងពីប៉ុន្មានថ្ងៃមកហើយ នាងឡើងទៅអង្គុយច្រត់ដៃលើពនទាហានសង់នៅលើដំបូលផ្ទះ ហើយចក្ខុនាងសំឡឹងទៅទីឆ្ងាយឯណោះ ត្រង់បាពយណ៍ខ្សាច់ដែលបងស្រីនាង ដេកសម្រាកមិនក្រោកត្រង់វាលកន្ទារៈ ដែលគូសង្សារបណ្ដូលចិត្តរបស់នាង នៅពីខាងមុខទ័ពអូដ្ឋដើរឆ្លងខ្សាច់ ។

តើសង្សាររបស់នាងសុខទុក្ខដូចម្ដេច?

ប្រហែលបច្ចាមិត្របាញ់សម្លាប់ហើយទេដឹង? សេចក្ដីរិះគិតទាំងរហេសកាតនេះធ្វើឲ្យនាងរីងរៃតែព្រួយឡើង ៗ ឈាមក្នុងបេះដូងឡើងត្រជាក់កកដូចមនុស្សស្លាប់ ។ នាងដើរចុះឡើងទាំងស្រងូត តាមច្រកក្នុងផ្ទះ ដើម្បីស្វែងរកមុខប្រកបដោយទឹកមេត្រីស្នេហា ប្រកបដោយការញញឹម

ត្រជាក់ គួរឲ្យទុកចិត្តទុកថ្លើម ។ ការណ៍កំប៉ិកកំប៉ុកមួយរយដំពូកនៃអាជីវៈរាល់ថ្ងៃ ចេះតែបណ្ដាលឃើញមានឡើងក្នុងចិត្ត, ការណ៍ទាំងនេះជារឿងឥតប្រយោជន៍សោះ ប្រសិនបើនាងមិនបានរលឹកឃើញនូវអនុស្សាវរីយ៍ដែលជាស្រមោលនៃគូសង្សាររបស់នាង ក្នុងការដង្ហោយហៅរក ។

ក្នុងសម័យដែលវិប្បយោគទុក្ខកំពុងញាំញីខ្លួនសន្ធាន ដូចជាទឹកជ្រោះដ៏ចត់ល្វីងបាញ់ចេញពីដួងហទយៈនៃនាង ខណៈនោះនាងនឹកឃើញសព្វ អំពីអនុស្សាវរីយ៍ជាអនិដ្ឋារម្មណ៍ក្នុងជីវិតរបស់នាង មរណភាពនៃលោកអាពុក, ការចាកចោលភូមិកំណើត, ការរងទុក្ខវេទនាតែម្នាក់ឯងរបស់បងស្រីនៅកណ្ដាលវាលខ្សាច់, ម្ដាយត្រូវជាប់ជាឈ្លើយឥតដឹងដំណឹងសោះ ។ ម្ល៉ោះហើយ ការអាសោរទៈបុករុកដួងព្រលឹងនៃនាងក្រមុំព្រហ្មចារិយ៍នេះកាន់តែខ្លាំងឡើង ។

ប្រាកដមែនហើយ គឺនាងមានជំនឿក្នុងយុត្តិធម៌នៃព្រះអាឡស់ ប៉ុន្តែអនិដ្ឋារម្មណ៍ទាំងនោះដូចជាធំពេក ហួសកម្លាំងរបស់នាងដែលជាស្ត្រីមានអាយុទើបតែម្ភៃឆ្នាំ ។ ក្នុងវ័យអាយុត្រឹមប៉ុណ្ណោះដែលជីវភាពកំពុងប្រកបដោយសេចក្ដីត្រេកអរដូចជាផ្កាកំពុងរីករងអារម្មណ៍ គឺជារដូវដែលពួកស្ត្រីក្រមុំមានការខ្នះខ្នែងត្រឹមតែធ្វើខ្លួនឲ្យសប្បាយស្រួល និងធ្វើដូចម្ដេចឲ្យតែគេស្រឡាញ់ ចំណែករូបនាងត្រឡប់ជាយំទាំងយប់ទាំងថ្ងៃ ឥតសង្ឃឹមនឹងបានប្រទះដួបនូវសេចក្ដីសប្បាយនិងសេចក្ដីសុខជាថ្មីឡើងវិញ ។

ក្នុងពេលដែលនាងកំពុងតែស្រងូតស្រងាត់ជាធម្មតា ដូចបព្វជង

រៀងមក ទោះបីព្រះអាទិត្យរះចាំងពន្លឺច្បាស់ក៏ដោយ ទោះបីសូរស័ព្ទនៃបក្សីទាំងឡាយស្រែកយំអឹងអាប់នឹងមេឃស្រឡះក៏ដោយ វត្ថុទាំងនេះដូចជាមានភាពអាក្រក់ទៅវិញ កាលណាចិត្តកើតទុក្ខ ៗ ស្រាប់តែលោកតាអៃយ៉ាជសួររកនាង ៗ លោកតាអៃយ៉ាជញញឹម ៗ យកដៃអង្អែលសក់ទន់ល្មើយរបស់នាងហើយប្រាប់ថា:

– នែមីនាង មានឥដ្ឋារម្មណ៍នៅរង់ចាំនាង ៗ

រួចលោកចាប់ដៃនាងនាំដើរសន្សឹម ៗ ទៅក្នុងបន្ទប់មួយធំដែលសម្រាប់ប្រើជាបណ្ណាល័យ ៗ

មានស្ត្រីម្នាក់ទទូរសំពត់ខ្មៅ ឈរនៅពីមុខបង្អួចមួយ គេអាចមើលឃើញមុខស្រីនោះ ដោយពន្លឺចាំងតាមរន្ធតូច ៗ នៃសំពត់ ៗ

ឡីឡាស្រែកថា:

– ម៉ែ !

រួចនាងក្រមុំស្ទុះទៅក្នុងដៃនៃនាងចាឌីយ៉ា ដែលយំដោយប្រទះដួងនឹងសេចក្តីសុខ ៗ

គឺជាសេចក្តីស្រណោះស្រណោកមួយស្របក់ សូម្បីលោកតាអៃយ៉ាជ ដែលជាបុរសភាពធ្លាប់មានការពិសោធន៍ដ៏យូរអង្វែងក្នុងជីវិតមកហើយក៏អាចទប់អាត្មា មិនឲ្យញាប់ញ័រដល់ដួងវិញ្ញាណបាន ៗ

សេចក្តីរីករាយរបស់នាងកំសត់ចាឌីយ៉ា សំដែងអាការគួរឲ្យស្តុតចិត្តដល់គេឯងរាល់គ្នា ៗ នាងស្មានតាំងពីយូរណាស់មកហើយថានាងឡីឡាក៏មានវាសនាអាក្រក់ដូចជាបងស្រីកំសត់ដែរ គឺជាកូនស្រីទាំងពីរ

មុខជាស្លាប់នាកណ្តាលវាលខ្សាច់មិនខាន ។ លុះគិតឃើញដូច្នោះ ហើយនាងម្តាយមានសេចក្តីទុក្ខព្រួយឥតឧបមា ស្ទើរតែនឹងវង្វេងស្មារតី ។ លុះទីបំផុត មានមួយថ្ងៃ នាងបានជួបតាម៉ាព្រែក ១ បានឲ្យដំណឹងអំពីវាសនានៃនាងឡីឡា ទើបនាងតាឌីយ៉ាអន់ព្រួយបន្តិច ។

លុះប៉ុន្មានថ្ងៃជាខាងក្រោយមក រាជការតួរគីបានយកអង្កេតយ៉ាងរិតត្បិតរួចហើយ ៗ ទទួលស្គាល់ថាពួកអ្នកដើរទេសក្នុងកុលសម្ពន្ធនៃអែលយ៉ាឌីគឺសុទ្ធតែពួកអ្នកជំនួញសុចរិត ឥតលាយឡំដោយពួកអ្នកទៅកុម្មឡើយ ។ ហេតុដូច្នេះ មិនត្រូវខ្លាចអំពីការបះបោរ ។ ទើបគេសម្រេចថាត្រូវទុកអារ៉ាប់ពួកនេះឲ្យមានសេរីភាពចុះ ។

លុះរួចផុតពីគ្រោះថ្នាក់ជាអ្នកឈ្លើយវេលាណា នាងតាឌីយ៉ាស៊ើបសួរដំណឹងតាមមនុស្សអ្នកទៅក្នុងផ្ទះរបស់លោកតាកាអិដ្ឋ ។

ឥឡូវនេះ នាងឧបរតកូនស្រីដ៏ដើមទ្រូង ហើយមិនអាចផាកក្អុកចេញពីមុខនាងក្រមុំដែលនាងស្មានថា អស់បានជួបប្រទះហើយ ។ ការត្រេកអរក្រៃបំផុតគ្មានកើតមានពេញទាំងដួងហឫទ័យ ។

លោកតាអៃយ៉ាដទាយទឹកចិត្តនាងឡីឡាមិនខុស លោកដឹងច្បាស់ថា ការរីករាយនៃនាងដោយបានជួបម្តាយ នឹងត្រឡប់អន់ថយទៅវិញ ព្រោះនាងនារីមានសេចក្តីស្តាយអាល័យ អំពីការចេញចាកផ្ទះដែលនាងធ្លាប់បានសុខពីដើមរៀងមក ។ លោកយល់បែបនេះប្រហែលជាត្រូវ?

លោកចូលមកជិតនាងឡីឡា យកដៃដាក់លើស្មាដូចជាឪពុក ហើយនិយាយដោយសុន្ទរកថាថា ;

— នៃមីនាង ព្រះអាឡស់មានបំណងចង់ឲ្យនាង វិលទៅកាន់កុលសម្ពន្ធ ជិតម្ដាយនាងវិញ ។

នាងនារីបែរទៅលោកតាអៃយ៉ាដ ទាំងភ្នែកក្រលួងរលេងរលោង ហើយនិយាយថា:

— ឱលោកម្ចាស់! ខ្ញុំម្ចាស់ត្រូវតែស្ដាប់បង្គាប់ការស៊ូត្រនៃព្រះអាឡស់ ប៉ុន្តែខ្ញុំម្ចាស់នឹកមិនភ្លេចឡើយគិតវេលាដែលខ្ញុំម្ចាស់បានធ្វើឲ្យប្រព្រឹត្តទៅក្នុងគេហស្ថានជាទីគោរព ។

រួចនាងក្រមុំឈប់និយាយ ព្រោះមានការរំភើបយ៉ាងធំមកធ្វើឲ្យអួលដើមក ។ ភ្នែកទាំងគូរបស់នាងក៏ចាំងផ្ទុកៗ ដោយជលនេត្រ ។

នាងចាប់និយាយឡើងទៀតទាំងត្រសិតង៉ក់ៗ ថា:

— ឱលោកម្ចាស់ថ្លៃខ្ញុំ បើអ៊ីស្មាអ៊ីលត្រឡប់មកវិញ សូមលោកប្រាប់គាត់ផងថា ខ្ញុំរលឹកគាត់ករបស់អ៊ីប្រៀបគ្មាន ហើយខ្ញុំម្ចាស់បៀមនាំយកស្រមោលរូបដ៏ក្លាហានសប្បុរសរបស់គាត់ទុក ក្នុងកណ្ដាលដួងព្រលឹងនៃខ្ញុំម្ចាស់ទៅជាមួយផង ។

ត្រង់ណោះត្រូវលើវេនលោកតាអៃយ៉ាដម្ដងវិញ លោកដឹងដូចជាមរណទុក្ខមកគៀបបេះដូងរបស់លោក ។ លោកដឹងតាំងពីយូរណាស់មកហើយ ថាកូនលោកមានការស្នេហាដ៏ជ្រួលចំពោះនាងក្រមុំ ហើយឪពុកកំសត់នេះមិនអាចទប់ទល់នឹងសេចក្ដីព្រួយ ដោយនឹកដល់វាសនារបស់កូនកំឡោះលោក ។

អ៊ីស្មាអ៊ីល?

តើ គេដឹងជាស្លាប់ ឬរស់ពេលនេះ ។ ប្រហែលពួកត្រូវគេលបចាំធ្វើទុក្ខតាមផ្លូវបាពាយណ៍ខ្សាច់ ដែលទៅបន្ទាយកស្រាមុំតហើយទេដឹង ។ ហើយនៅឯយមបន្ទាយឯណោះ មិនដឹងពទទួលការធ្វើទុក្ខបុកម្នេញយ៉ាងណា មិនដឹងគេចម្លាក់ទោសមកលើពយ៉ាងណា ដើម្បីផ្ដន្ទាមកតែពីពមានសេចក្ដីគោរពស្ចូពបាទឹងការពារនូវវត្ថុជាទីស្រឡាញ់ ដែលអាចោរក្បត់ចង់ដណ្ដើមយក ។ ៗ

ហេតុដូច្នេះ សេចក្ដីស្នេហាដ៏បរិសុទ្ធ ដ៏ជិតស្និទ្ធនៃនាងក្រមុំធ្វើឲ្យរំភើបដល់ចិត្តខាងក្នុងរបស់លោកតាកាស៊ីដ ក្នុងពេលដែលជោគពសនាមកកន្ទ្រាក់យកនាងឡីឡាចេញពីផ្ទះ ហើយនាំនាងទៅកាន់អាជីវៈកណ្ដាលពលខ្សាច់ ៗ លោកតាសប្បុរស់បេន-អៃយ៉ាដយល់ថា ពេលនេះខ្លួនលោកដូចជាគិតដល់នាងក្រមុំជាងសព្វដង ៗ ការអាស្រ័យនៅនៃនាងក្រមុំព្រហ្មចារិយក្នុងផ្ទះ ហាក់ដូចជាបានសេចក្ដីសុខគ្រាន់បើ ៗ លោកធ្លាប់ឃើញពជាទិច្ច កាលដែលពទៅអណ្ដូងទឹកជាមួយនឹងកូនស្រីក្មួយស្រីរបស់លោក ហើយលោកមានចិត្តពេញអានដូចគ្នាទាំងអស់ ឥតប្រកាន់ ៗ លោកដែលគេធ្លាប់ដឹងយូរមកហើយថា ជាមនុស្សមិនញាប់ញ័រ ជាមនុស្សអាចសង្កត់ចិត្តខ្លួនបាន ឥឡូវត្រឡប់ទៅជារកកល់ទប់ចិត្តមិនបង់កើត ៗ លោកខំទប់ការអួលអាក់ដែលឡើងមកត្រង់បំពង់ក ហើយមានពពាថា សូមការស្ញប់ត្រៃនៃព្រះអាឡស់សារម្រែបចុះ ។

រួចលោកលើកដៃដាក់លើក្បាលនាងឡីឡា និងម្ដាយនាង ហើយលោកប្រកត់ប្រសិទ្ធិឲ្យពរទាំងចិត្តទុក្ខព្រួយ ៗ

ឥឡូវនាងឡូឡាត្រូវរស់ទៅដើរតាមគេពីជំរុំព្រឹក្សមួយទៅជំរុំព្រឹក្សមួយវិញ ។

ចម្បាំងច្រើនតែកើតមាននៅតាមមាត់សមុទ្រទឹងខាងក្នុងកូម៉ិកណ្តាល ប៉ាកយណ៍ខ្លាច់ ហើយសភាពធម្មជាតិក៏មិនទាន់ផ្លាស់ប្រែប្រួលណាស់ណានៅឡើយទេ ។ ប៉ុន្តែការផ្លាស់ប្តូរប្រែប្រួលមានសភាពដ៏ធំចំពោះនាងឡូឡា ។ ជីវភាពនាកណ្តាលព្រៃលំបាកដោយសេរីភាព ដែលនាងធ្លាប់ប្រព្រឹត្តមកជាយូរអង្វែង ឥឡូវ ឥដ្ឋារម្មណ៍នេះ នាងមិនទទួលដូចពីមុនឡើយ ។ ដោយបានទទួលផលទុជាសនៃសេចក្តីស្នេហារួចមកហើយ ក្រៅពីអនុស្សាវរីយ៍ចំពោះ អ៊ីស្មាអ៊ីល នាងឥតមានសប្បាយនឹងអ្វីទាំងអស់ ។ ទីកន្លែងទាំងប៉ុន្មានគ្រាន់តែជាហេតុនាំឲ្យនាងកើតទុក្ខនឹងបាត់ការក្លាហាន ។

កាលណានាងនាំហ្វូងពពែឲ្យស៊ីស្មៅ នាងតែងតែនឹកទាំងទុក្ខ ដល់រូបស្រមោលដ៏ថ្លៃថ្លាដែលបានជូននាងដើរកាត់តាមដើមត្នោតនឹងផ្កាកូឡាបដើម ។ លុះការស្រម៉ៃនេះរលុបបាត់ទៅ នាងនឹកដល់រូបស្រមោលនៃអ្នកជិះសេះសបរមករកនាង ។

មូលហេតុដើមដំបូងនៃការជួបប្រទះនឹង អ៊ីស្មាអ៊ីលត្រឡប់កើតឡើងក្នុងចិត្តទុក្ខព្រួយនៃនាងវិញម្តងទៀត ។ នាងនឹកឃើញថា កាលនោះ អ៊ីស្មាអ៊ីល ស្លៀកពាក់បែបនេះ គ្រឿងអាននសេះបែបនេះ សូរសំដីអ៊ីស្មា-អ៊ីល បែបឯនេះ នាងនឹកឃើញសព្វគ្រានសល់ត្រង់កន្លែងណា ។

(មានត)

# រឿងបល្ល័ង្កទិព្វ សាមសិបពីររឿង

រឿងព្រេងតំណាល

## លោកសមិន មុត្យនជិមៈតែង

## លោករ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិតទី ១៦

មានកាលមួយថ្ងៃ ព្រះបាទភោជៈទ្រង់យាងចូលទៅជិតបល្ល័ង្កទិព្វ, រូបទេពនិម្មិតទី ១៦ ក្រាបបង្គំទូលថា:

"បពិត្រ ព្រះបាទភោជៈ, ទូលបង្គំសូមថ្លែងអំពីព្រះរាជគុណសម្បត្តិដែលធ្វើឲ្យមហារាជវិក្រមាទិត្យ អាចគង់នៅលើបល្ល័ង្កទិព្វនេះបាន សូមព្រះអង្គទ្រង់ព្រះសណ្ដាប់!

មានព្រះមហាក្សត្រិយ៍មួយព្រះអង្គទ្រង់ព្រះនាមចន្ទ្រសេខរៈ (Candraçekhara) មានមួយថ្ងៃស្ដេចកំពុងទ្រង់គង់ប្រថាប់ក្នុងមហាសន្និបាតរដ្ឋមន្ត្រី, មានបរជាតិថ្មអ្នកប្រៀនម្នាក់ចូលមកក្រាបបង្គំគាល់ព្រះអង្គ ថ្លែងសរសើរអំពីព្រះរាជកិត្តិគុណនៃព្រះបាទវិក្រមាទិត្យថា: "ព្រះបាទវិក្រមាទិត្យទ្រង់ប្រកបដោយព្រះរាជកិត្តិគុណសម្បត្តិគ្រប់យ៉ាង ព្រោះហេតុដូចនេះ អ្នកទាំងអស់ចូលទៅពុំនាក់អាស្រ័យនឹងព្រះអង្គ; ទ្រង់ជាទីជ្រកកោននូវគុណសម្បត្តិគ្រប់យ៉ាង ព្រោះព្រះអង្គជាឧត្តមមនុស្សម្នាក់ ដែលមានព្រះប្រាជ្ញាអាចបំពេញនូវគុណសម្បត្តិទាំងអស់បាន, ជាឯកមនុស្ស មិនមានមនុស្សណាអាចយកមកប្រៀបធៀបនឹងព្រះអង្គបានឡើយ ។

ព្រះបាទចន្ទ្រសេខរៈ កាលទ្រង់ព្រះសណ្ដាប់នូវសេចក្ដីពណ៌នានៃអ្នកប្រៀន (សមជ្ឈបុរស Mévestrel) ទ្រង់មានព្រះបន្ទូលទៅកាន់អ្នកប្រៀនថា "ម្នាលវេទកៈបុរស អ្នកឯងបានត្រាច់ទៅកាន់ប្រទេសជាច្រើន តើធ្លាប់បានឃើញបុគ្គលណាមានចរិយាល្អ ដូចព្រះបាទវិក្រមាទិត្យឬទេ? ។ វេទកៈបុរសក្រាបបង្គំទូលថា ទូលព្រះបង្គំបានឃើញតែព្រះបាទវិក្រមាទិត្យ ដែលទ្រង់មានព្រះគុណធម៌ច្រើនជាងគេ ។ ព្រះបាទចន្ទ្រសេខរៈ ទ្រង់ព្រះសណ្ដាប់នូវសព្វវេតាធិប្បាយនៃវិញ្ញូជន អំពីព្រះគុណធម៌នៃព្រះបាទវិក្រមាទិត្យ ទ្រង់មានព្រះរាជបំណងចង់ឲ្យមានព្រះគុណធម៌ដូចមហារាជអង្គនោះដែរ ហើយទ្រង់បួងសួងចំពោះទេវបុត្រ ។ ពេញព្រះរាជហឫទ័យទីងសម្បូងសង្រួងនៃព្រះបាទចន្ទ្រសេខរៈ ក៏បានថ្វាយមកព្រះអង្គនូវអត្តភាព ហើយមានព្រះបន្ទូលថា "កន្លងមួយថ្ងៃៗ សូមព្រះអង្គបូជាព្រះកាយព្រះអង្គចំពោះព្រះអគ្គី, ហើយរូបកាយឆេះអស់ ប្រែទៅជារូបកាយមួយផ្សេងទៀត មានធម្មជាតិដ៏ឧត្តម ។ ក្រោយដែលបានមានព្រះបន្ទូលយ៉ាងនេះ ទេវបុត្រក៏បាត់ខ្លួនពីទីនោះទៅ ។ ព្រះបាទចន្ទ្រសេខរៈ ទ្រង់ក៏បានយកព្រះរូបព្រះអង្គទៅធ្វើព្រះរាជពលីកម្មរាល់ៗថ្ងៃ ហើយព្រះរូបព្រះអង្គទៅជាមានសម្ផស្សដ៏ទិព្វ ។ ដល់ទ្រង់មានបុព្វសិទ្ធិជាអមតភាព, ទ្រង់ក៏មានព្រះគុណក្រៃយ៉ាង ។

សមជ្ឈបុរសក៏បានក្រាបបង្គំទូល ចំពោះព្រះបាទវិក្រមាទិត្យនូវរឿងរ៉ាវនៃព្រះបាទចន្ទ្រសេខរៈ ។ ព្រះបាទវិក្រមាទិត្យក្រោយដែលបានទ្រង់ព្រះសណ្ដាប់នូវវេតារបស់វេទកៈបុរស ទ្រង់ព្រះដម្រិះក្នុងព្រះ

រាជហ្ឫទ័យថា៖ “ បើអ្នកណាបានធ្វើពលិកម្មដូចព្រះបាទចន្ទ្រសោទរៈ អ្នកនោះជាឧត្តមមនុស្ស ជាឯកបុគ្គលគួរជាទីគោរព គួរជាទីបូជា ” ។ ដល់ទ្រង់ព្រះតម្រិះដូចនេះ ព្រះបាទវិក្រមាទិត្យទ្រង់ក៏បួងសួងចំពោះទេវបុត្តៗ បញ្ចេញរូបមកចំពោះព្រះភ័ក្ត្រទ្រង់ ។ ក៏មានព្រះរាជឧង្ការទៅកាន់ទេវបុត្តថា “ សូមទេវបុត្តឈប់លែងឲ្យព្រះបាទចន្ទ្រសោទរៈលោតទៅក្នុងព្រះអគ្គី ដើម្បីនឹងធ្វើរូបឲ្យបានប្រែកបដោយអត្តភាព, សូមទេវបុត្តប្រគល់ការៈដ៏ធ្ងន់នោះ គឺឲ្យខ្ញុំលោតទៅក្នុងព្រះអគ្គីវិញ, ហើយសូមប្រគល់ឲ្យអមតភាពនោះទៅព្រះបាទចន្ទ្រសោទរៈវិញ ” ។ ទេវបុត្តក៏យល់ព្រមតាមព្រះរាជបំណង ហើយហោះទៅឲ្យដំណឹងដល់ព្រះបាទចន្ទ្រសោទរៈថា តាំងពីថ្ងៃស្អែកនេះទៅទ្រង់មិនបាច់លោតទៅក្នុងព្រះអគ្គីទេ ការៈនេះគឺព្រះបាទវិក្រមាទិត្យទ្រង់ទទួលទៅហើយ, ព្រះអង្គចាំតែទទួលនូវអមតៈចុះ ហើយព្រះរូបព្រះអង្គប្រែជាអមតរូប គឺលែងចាស់-ឈឺ-ស្លាប់ តាំងពីថ្ងៃនេះតទៅ ” ។

តាំងពីថ្ងៃនោះមក, ព្រះបាទវិក្រមាទិត្យទ្រង់តែងលោតទៅក្នុងព្រះអគ្គីរាល់ព្រឹក, ឯព្រះបាទចន្ទ្រសោទរៈចាំទទួលនូវអមតៈ ។ រូបទេពនិម្មិតទី ១៦ ពោលដូច្នេះហើយ, ក៏ងាកទៅរកព្រះបាទភោជៈ ហើយទូលថា បើទ្រង់មានកិច្ចការធ្វើពលិកម្មបែបនេះបាន សូមទ្រង់ស្តេចចូលទៅគង់លើបល្ល័ង្កទិព្វនេះចុះ ។ ព្រះបាទភោជៈ ទ្រង់យល់ថា កិច្ចនេះហួសវិស័យព្រះអង្គនឹងធ្វើបាន, ទ្រង់ក៏ថយចេញឆ្ងាយពីបល្ល័ង្កទិព្វ ពុំបានធ្វើរាជាភិសេកក្នុងពេលនោះ ។

# និទាននៃរូបទេពនិម្មិតទី ១៧

មានកាលថ្ងៃមួយ, ព្រះបាទភោជៈ ទ្រង់ចិត្តចូលទៅជិតបល្ល័ង្កទិព្វ ដើម្បីនឹងឡើងរាជាភិសេក ។ រូបទេពនិម្មិតទី ១៧ ក្រាបបង្គំទូលព្រះអង្គថា: សូមទ្រង់ព្រះមេត្តាប្រោស, ទូលបង្គំនឹងពណ៌នាព្រះរាជចរិយាដ៏ពិសេសនៃព្រះបាទវិក្រមាទិត្យដូចតទៅនេះ៖

ក្នុងរជ្ជកាលព្រះបាទវិក្រមាទិត្យ ទ្រង់សោយរាជសម្បត្តិនៅនគរអវន្តី ។ ក្នុងពេលនោះពួកប្រជារាស្ត្រទាំងអស់ពេញចិត្តខាងការប្រព្រឹត្តនូវគុណធម៌ ដោយព្រះមហាក្សត្រិយ៍ ទ្រង់ទសពិធរាជធម៌ ។ ស្ត្រីស្គាល់តែបុរសម្នាក់, គេលះបង់ចោលបាបអកុសល, គេពេញចិត្តខាងប្រតិបត្តិតាមបទបញ្ញត្តិច្បាប់, គេប្រព្រឹត្តតាមបទបែបដែលបានចារិកទុកក្នុងសាស្ត្រៈ, គេគោរពកោតក្រែង, ស្តាប់បង្គាប់ទៅ មាតា-បិតា ព្រះមហាក្សត្រិយ៍ . . . ល . . . គេប្រព្រឹត្តតាមសីលធម៌ ដូចបានត្រាទុកក្នុងវិទ្យាសាស្ត្រនៃអត្តា (la science de l'âme suprême) បើពោលដោយសង្ខេប ប្រទេសទាំងអស់ក្តីរុងរឿងដោយបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ ។ ព្រះបាទវិក្រមាទិត្យទ្រង់ទំនុកបម្រុងរក្សាជីវសត្វ, ធ្វើទណ្ឌកម្មពួកពាលសាមាន្យ តាមបទបញ្ញត្តិក្នុងទណ្ឌនីតិ (Dandaniti) (Dandaniti Code pénal) ហើយនឹងរាជនីតិ, (Râjâniti Code politique) ហើយទ្រង់សប្បាយព្រះរាជហឫទ័យក្នុងរាជសម្បត្តិ បានប្រកបដោយសុភមង្គលគ្រប់យ៉ាង ។

មានមួយថ្ងៃនាយទ្វារ បានចូលមកក្រាបបង្គំទូលព្រះបាទវិក្រមា-

ទិត្យថា "បពិត្រព្រះអង្គដ៏ចំរើន មានជ្រូកព្រៃមួយធំសម្បើមអស្ចារ្យ មានរូបប៉ុនភ្នំដូចជាព្រះយមៈ (យមរាជ) មកដល់, បានចូលទៅក្នុងគុម្ពោតឈើ ដែលជាទីកន្លែងព្រះអង្គម្ចាស់ធ្លាប់ស្តេចយាងទៅកំសាន្តព្រះរាជហឫទ័យ ។ ជ្រូកព្រៃនោះធ្វើឲ្យខ្ញុំព្រះបង្គំខ្លាចតក់ស្លុតពន់ប្រមាណ, ទាល់តែខ្ញុំព្រះបង្គំរត់ចេញពីព្រះរាជឧទ្យាន មកសូមពំនាក់អាស្រ័យនឹងព្រះអង្គ សូមទ្រង់ព្រះមេត្តាត្រាស់បង្គាប់ឲ្យទាក់កងយោធាទៅដេញជ្រូកព្រៃនោះពីព្រះរាជឧទ្យាន ។

"កាលណាព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យនាយឧទ្យានបាល, ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះរាជបំណងចង់យាងទៅបាញ់សត្វ, ទ្រង់ឡើងគង់លើព្រះទីនាំងហត្ថីតែមួយព្រះអង្គ ដើម្បីនឹងដេញជ្រូកព្រៃនោះចេញពីព្រះរាជឧទ្យាន ។ ដល់ព្រះបាទវិក្រមាទិត្យ ទ្រង់ស្តេចយាងចូលទៅក្នុងព្រះរាជឧទ្យាន ស្រាប់តែជ្រូកព្រៃនោះភ័យតក់ស្លុតឥតឧបមា, ក៏រត់ចេញពីទីនោះទៅ ។ ព្រះមហាក្សត្រិយ៍ទ្រង់ដេញតាមជ្រូកព្រៃ, កាត់តាមព្រៃជាច្រើនសង្កាត់ទើបយាងទៅដល់ព្រៃក្រាស់ធំមួយ ។ ទ្រង់ក៏ស្តេចដេញប្រកិតតាមពីក្រោយ ។ ដល់ជ្រូកព្រៃនោះទៅដល់មាត់ទ្វារគុហាភ្នំ ក៏យកចៃទំលាយទ្វារធំនោះរត់ចូលទៅខាងក្នុង ។ ព្រះបាទវិក្រមាទិត្យទ្រង់ស្តេចយាងចុះពីព្រះទីនាំងហត្ថី ព្រះហស្តកាន់ព្រះខ័ន ហើយនឹងខែលចូលទៅក្នុងគុហានោះទៅ ។ គុហានោះមានទំហំធំពន់ពេក ដូចជាប្រទេសទាំងមូល ។ ទ្រង់ក៏បានស្វែងរកជ្រូកព្រៃគ្រប់ទិសទីតែមិនឃើញ ។ ទ្រង់ក៏ត្រាច់ទៅក្នុងគុហា, ស្រាប់តែទ្រង់បាន

ដូចប្រទះនឹងនគរមួយ ដែលទ្រង់មិនដែលឃើញសោះឡើយ ។ ទ្រង់បានទតទៅឃើញព្រះរូបព្រះនារាយណ៍ ដែលមានអាកប្បកិរិយាដូចជាថ្វាយដង្វាយ នៅចាំមាត់ទ្វារនគរ ។ ទ្រង់ក៏បានថ្លែងព្រះបសំសន-កថា នឹងបណាមកថា ហើយទ្រង់បានធ្វើព្រះរាជប្រទក្សិណ ចំពោះព្រះរូបព្រះនារាយណ៍នោះ ហើយទ្រង់គង់ប្រថាប់ដោយលើកព្រះហស្តធ្វើអញ្ជលីកម្ម ។

ព្រះនារាយណ៍ទ្រង់មានព្រះរាជហឫទ័យ សោមនស្សពន់ពេកដោយព្រះបាទវិក្រមាទិត្យ ទ្រង់បានគោរពនមស្សការដ៏ស្មោះស្ម័គ្រ ។ ទ្រង់ក៏បានព្រះរាជទានមកព្រះបាទវិក្រមាទិត្យ នូវវត្ថុដ៏ជាទិព្វពីរយ៉ាងគឺរស: (Rasa) នឹងរសាយន: (Rasâyana) ដែលទ្រង់បានពន្យល់អំពីរបៀបយកទៅប្រើ ព្រះនារាយណ៍ទ្រង់មានព្រះបន្ទូលថា: បពិត្រមហារាជ ចំពោះវត្ថុនេះដែលហៅថារស: របស់អ្វីដែលទ្រង់ព្រះតម្រិះទៅដល់ហើយនាំឲ្យត្រេកត្រអាលក្នុងសន្ដាន ទ្រង់អាចសម្រេចបានទៅតាមព្រះរាជបំណងដោយសារវត្ថុនេះ ។ ចំណែកឯវត្ថុដ៏ទិព្វមួយទៀតដែលមានឈ្មោះថារសាយន:នេះ បើទ្រង់ព្រះតម្រិះអំពីវត្ថុ គឺវត្ថុដែលមានសភាពខ្ពស់ជាងពិភពលោក; ទ្រង់នឹងអាចសម្រេចទៅតាមព្រះរាជបំណងទាំងអស់ ។

ព្រះបាទវិក្រមាទិត្យ ដល់ទ្រង់បានវត្ថុដ៏ទិព្វទាំងពីរដោយព្រះរាជអំណោយនៃព្រះនារាយណ៍ ទ្រង់ក៏ចេញពីគុហា ។ ទ្វារនៃគុហានោះក៏បិទជិតទ្រង់ក៏ក្ដាប់ព្រះហស្តដាល់ទៅលើទ្វារនោះរបើក ហើយទ្រង់ក៏យាងវិលត្រឡប់មកកាន់ព្រះរាជធានីវិញ ។ នៅតាមផ្លូវ, ទ្រង់បានជួប

ប្រទះនឹងព្រាហ្មណ៍ពីរនាក់បិតានឹងបុត្រជាពួកវិញ្ញូជន ធ្លាប់ចេះដឹងសស្ត្រៈទាំងអស់, មានទុក្ខជាទម្ងន់ ។ ក្រោយដែលទ្រង់ព្រះសណ្ដាប់នូវរឿងរ៉ាវនៃព្រាហ្មណ៍ទាំងពីរនាក់ ទ្រង់ក៏មានព្រះរាជហឫទ័យអាណិតអាសូរដល់ព្រាហ្មណ៍ដូចជាទុក្ខរបស់ព្រះអង្គ ហើយទ្រង់ព្រះរាជទាននូវវត្ថុទិព្វទាំងពីរ គឺសេះនឹងសោយនៈទៅព្រាហ្មណ៍ ។

រូបទេពនិម្មិតទី ១៧ ទូលបន្ថែមថា: បពិត្រព្រះបាទភោជៈ នេះហើយជាព្រះមហាវីរភាព ព្រះមហាសប្បុរសនៃព្រះបាទវិក្រមាទិត្យ បើទ្រង់មានព្រះចរិយាដូចព្រះបាទវិក្រមាទិត្យបែបនេះ, ទ្រង់អាចគង់នៅលើបល្ល័ង្កទិព្វនេះបាន ។

ក្នុងពេលនោះ ព្រះបាទភោជៈក៏ទ្រង់មិនបានធ្វើរាជាភិសេក ទ្រង់បានថយចេញពីបល្ល័ង្កទិព្វនេះទៅ ។ (មានត)

## រស់នៅបែបណាទុកថាជាការរស់ប្រសើរ ?

៤៤ – ក្នុងលោកនេះ អ្នកណារស់នៅតែមួយស្របក់ តែប្រកបដោយសម្បទាដែលមនុស្សលោកប្រាថ្នា គឺចំណេះវិជ្ជា, សេចក្ដីអង់អាចក្លាហាន, ទ្រព្យសម្បត្តិ នឹងគុណដ៏ប្រសើរទាំងឡាយ, អ្នកដឹងការណ៍នោះច្បាស់លាស់ តែងពោលសរសើរជីវិតអ្នកនោះថាជាជីវិតដ៏ប្រសើរ; ឯសត្វក្អែករស់នៅបានយូរដោយគ្រាន់តែស៊ីបាយសល់អំពីគេធ្វើពលិកម្ម ចាត់ជារស់ពុំប្រសើរ ។

បញ្ចតន្ត្រៈ

# សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## នៅពុទ្ធសាសនបណ្ឌិត្យ

### បរិយាយពីល្បែងត្រុដិ

## លោក ឋាប-ពិន រៀបរៀង

ក្នុងនាមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ខ្ញុំសូមបរិយាយចំពោះល្បែងខ្មែរមួយបែប ហៅថា "ល្បែងត្រុដិ" ដែលអ្នកខេត្រសៀមរាប និងបាត់ដំបងគេតែងលេងនៅរដូវចូលឆ្នាំខ្មែររាល់ឆ្នាំ ៗ

របាំគ្រប់ចំពូកដែលមានទាំងរាំទាំងច្រៀងទាំងភ្លេង ហៅតាមភាសាសំស្រ្កឹតថា "មហោស្រព" ។ មហោស្រពខ្មែរមានច្រើនចំពូក - មានល្ខោន ល្ខោនខោល ល្ខោនយក្ខ រាំត្រុដិ រាំស្នែងទន្សោង រាំកន្តែរ៉ែជាដើម ។ ក្នុងទីនេះ សូមយកតែល្បែងត្រុដិមួយមកថ្លែងជាមុនសិន ថ្ងៃមុខសឹមថ្លែងពីល្បែងឯទៀត ដោយឃើញថាល្បែងត្រុដិជាល្បែងខ្មែរតែខ្មែរយើង ក្រៅតែពីអ្នកខេត្រសៀមរាបនិងអ្នកបាត់ដំបងចេញ ពុំសូវមានគេស្គាល់ទេ ។

ពាក្យថា ត្រុដិ ជាភាសាសំស្រ្កឹត ប្រែថា "ការកាត់ផ្តាច់ គឺផ្តាច់ឆ្នាំទីមួយ ៗ" ឯល្បែងនេះបានជាបុរាណឲ្យឈ្មោះថា ល្បែងត្រុដិ ព្រោះជាល្បែងដែលគេត្រូវលេងចំពោះតែរដូវផ្តាច់ឆ្នាំចាស់ចូលឆ្នាំថ្មី ។

តាមសេចក្តីឲ្យការណ៍របស់ព្រះតេជព្រះគុណ ព្រះវនរ័តន៍ ព្រះនាម អ៊ីវ-ទួត មេគណខេត្របាត់ដំបងថា លោកបានជួបនឹងជនជាតិខ្មែរ នៅ

ស្រុកស្គុរិន ១ នាក់ឈ្មោះ ព្រឹម ឲ្យការណ៍ថា អ្នកស្រុកនោះ គេនៅរក្សាទំនៀមទម្លាប់ល្បែងត្រុដិល្អណាស់, ថាអ្នកស្រុកនោះ គេតែងលេងល្បែងនេះនៅវេលាចូលឆ្នាំរាល់ឆ្នាំ, ថាចាស់ៗ នៅស្រុកនោះដំណាលថា កាលព្រះមហាក្សត្រខ្មែរគ្រងរាជ្យនៅអង្គរធំ វេលាដាច់ឆ្នាំចាស់ចូលឆ្នាំថ្មី ពួកត្រុដិតែ ទៅលេងថ្វាយពរសព្ទសាធុការជារាល់ឆ្នាំ, ព្រះមហាក្សត្រតែងស្ដេចចេញទទួលពរអំពីពួកនោះ ហើយតែងទ្រង់ព្រះរាជ-ទានរង្វាន់ ទ្រង់ប្រោះទឹកព្រះរាជទានពរគេប ។

សេចក្ដីឲ្យការណ៍នេះ ឃើញសមហេតុផល ព្រោះអ្នកខេត្តសៀមរាបសព្វថ្ងៃនេះនៅរាប់អានល្បែងត្រុដិណាស់ តែជិតដល់ថ្ងៃចូលឆ្នាំពួកអ្នកលេងល្បែងនេះ តែងត្រៀមគ្រឿងប្រដាប់លេងសព្វគ្រប់ ដល់ថ្ងៃចូលឆ្នាំចេញលេងតាមភូមិស្រុក លុះដល់ថ្ងៃឡើងស័កនាំគ្នាទៅលេងថ្វាយឯនគរវត្ត ជាទំនៀមរៀងរាល់ឆ្នាំ ។

ឯរបៀបត្រុដិមិនបានបិតនៅទៀងទាត់ជាបែបមួយទេ ចេះតែផ្លាស់ប្ដូរទៅតាមកាលសម័យ ទាំងគ្រឿងប្រដាប់សម្រាប់លេងនឹងទំនុកច្រៀងក៏មានប្លែកៗគ្នា ទៅតាមខេត្ត តាមស្រុក តាមភូមិ ហើយគ្រឿងប្រដាប់នោះសោតក៏មានតិចច្រើនតាមវង់តូចវង់ធំ, វង់តូចគ្នាតិចគ្រឿងប្រដាប់តិច វង់ធំគ្នាច្រើនគ្រឿងប្រដាប់ច្រើន ។

ឯត្រុដិវង់ធំមានអ្នកលេងច្រើន ចំនួន ៣២ នាក់ នឹងមានគ្រឿងប្រដាប់ច្រើន ដូចរៀបរាប់តទៅនេះ ៖

- ប្រុស ៣ នាក់ ជាអ្នកកាន់ដងកញ្ជារ សម្រាប់បុកឲ្យឮធារៗ តាមចង្វាក់ស្គរ,
- ប្រុស ២ នាក់ ជាអ្នកកាន់ស្គរដៃដែលហៅថាស្គរអារក្ស សម្រាប់ទះឲ្យឮទ្រឹបៗ ទ្រមៗ តាមចង្វាក់ភ្លេង;
- ប្រុស ១ នាក់ ជាអ្នកកាន់ប៉ីពក សម្រាប់ផ្លុំតាមបទភ្លេង;
- ប្រុស ២ នាក់ ជាអ្នកកាន់ទ្រ សម្រាប់កូតតាមបទភ្លេង;
- ប្រុស ៣ នាក់ ជាអ្នកកាន់ដងចន្ក្រន់ដំបែរ សម្រាប់បុកឲ្យឮរ៉ៃៗ តាមចង្វាក់ស្គរ;
- ប្រុស ២ នាក់ ជាអ្នកពាក់ស្នែងប្រើសមែនទែនឬធ្វើពត់ជាស្នែងប្រើសដើរក្រោយគេ សម្រាប់ឲ្យព្រានព្រៃបាញ់;
- ប្រុស ៤ នាក់ ជាអ្នកពាក់ស្នែងទន្សោងមែនទែនឬធ្វើពត់ជាស្នែងទន្សោងដើរក្រោយគេ សម្រាប់ឲ្យព្រានព្រៃបាញ់;
- ប្រុស ១ នាក់ ជាព្រានព្រៃឬយក្សបងចន្ក្រន់រ៉ូងជុំវិញចង្កេះ ដៃកាន់ធ្នូ សម្រាប់បាញ់ប្រើស និងទន្សោង;
- ប្រុស ៤ នាក់ ជាអ្នកទាំមុខ ជួតក្បាលក្រហម សម្រាប់ដើរនាំហ្វូង;

- ប្រុស ១ នាក់ ជាមេថ្មើរព្រៃជួតក្បាលក្រមា ស្ពាយបាយ កញ្ចប់ សម្រាប់ដើរមើលផ្លូវមុនព្រានព្រៃ;

  ប្រុស ១នាក់ ជាអ្នកដើមបទ ពាក់ក្រចកវែងដែលធ្វើពីទ្រនុងស្លឹកដូង សម្រាប់ច្រៀងបើកបទឲ្យអ្នកលេងទាំងអស់គ្នាចាំច្រៀងបន្ទរតាម;

- ប្រុស ២ នាក់ ជាតួឯកស្លៀកសំពត់ចងក្បិនខ្លួនពាក់សង្វារ ក្បាលពាក់មកុដ ឬ កញ្ចាំង មុខផាត់ម្សៅ កាន់កន្ទុយក្ងោកសម្រាប់រាំនាំមុខគេ;

- ស្រី ២ នាក់ ជានាង ពាក់ក្រចកវែង ក្បាលពាក់បៃ ស្លៀកសំពត់ហូលសំឡុយ ពាក់អាវបំពង់ខ្លី បង់កសំយុង សម្រាប់រាំគូនឹងតួឯក;

- ប្រុស ២ នាក់ ជាអ្នកកាន់ដងសន្ទូចប្រវែង ២ ម៉ែត្រ ចង ចង់សំពត់ទៅចុង សម្រាប់រុញទៅកផ្ទះអ្នកស្រុកឲ្យម្ចាស់ផ្ទះដាក់សូត្រ អំបោះ នឹងប្រាក់;

- ប្រុស ១ នាក់ ជាអាចារ្យ ស្លៀកពាក់ស ពាទាស ស្ពាយ យាម សម្រាប់ផ្តើមបើកពិធីលេងនឹងដើរមុខ អ្នកលេង ចាំទទួលសូត្រអំបោះនឹងប្រាក់ ។

តាមទំនៀមអ្នកលេងត្រូវដើរទៅស្រុកតាក្រាមខែត្របាត់ដំបង, មុនពេលលេងគេធ្វើកទះទេវតា ៣ ថ្នាក់ ដាក់បាយសី ១ គូ ស្លាធម៌ ១ គូ

តែ ១ ស្ទឹត កញ្ចក់ រមៀត ម្សៅ ស្លាបារី កន្ទោងបាយម្ហូបចំណី ទឹកអប់ ១ ផ្តិល អំពោះ ១ កម្រង ទីងមុខស្លាប់ ហើយឲ្យពួកអ្នកលេងទាំងប៉ុន្មានមកជួបជុំនៅមុខពាន ។ ពួកអ្នកភ្លេងកាន់ គ្រឿងភ្លេងអង្គុយ ១ ជួរ, អ្នកកាន់គ្រឿងប្រដាប់លេងផ្សេង ៗ អង្គុយ ១ ជួរ, អាចារ្យអង្គុយចំកណ្តាល អុជទៀនធូបសូត្របួងសួងសែនអារក្សអ្នកតា ។ ស្រេចកាលណា អាចារ្យលើកមុខស្លាប់ទីងស្នែងប្រើសបំពាក់ឲ្យគ្រប់គ្នា ហើយជយចេញទៅក្រៅរង់ ។ លំដាប់ពីនេះ ពួកអ្នកលេងក្រោកឈរទាំងអស់គ្នាហើយ

ក្លងកស្រែកច្រៀងឡើងថា:

ខ្ញុំសូមថ្វាយបង្គំ ហត្ថខ្ញុំប្រណម្យ ព្រះរតនត្រ័យ

ឱ ! ព្រះគុណខ្ញុំហើយ ព្រះរតនត្រ័យ សូមមានជោគជ័យ សេចក្តីក្សេមក្សាន្ត ។

អ្នកទទួល ៗ ព្រមគ្នាថា:

ឱណានាងណា ! សេចក្តីក្សេមក្សាន្ត ។

ក្នុងពេលបួងសួងក្តី ពេលណា ៗ ក្តី, កាលពួកអ្នកច្រៀង ៗ ឡើង, ពួកអ្នកកាន់ដងកញ្ចារកំបុកកញ្ចារតាមចង្វាក់ស្គរ, ចំណែកអ្នកកាន់ស្គរក៏ទះតាមរយៈដែលគេកំណត់ គឺ ទ្រឹបទ្រឹម ទ្រិមទ្រិប ទ្រឹបទ្រឹម ជួនកាលយូរ ៗ គេបំភ្លេងត្រង់ចុងគឺ ទ្រិប ៗ ទ្រិម ៗ ទ្រឹប ទ្រឹម ដូច្នេះ, គ្មានវិសេសជាងនេះទៅទៀតទេ ។

កាលស្រេចពិធីពីការគេនាំគ្នាចេញលេងតទៅ ។

បើពេលលេងមានអ្នកស្រុកឲ្យទានវត្ថុប្រាក់កាសច្រើន, ក្រោយ

ពេលលេងពួកត្រុដិចាត់ការនិមន្តព្រះសង្ឃសូត្រមន្តប្រស់ទឹកឲ្យពីល្ងាច, ព្រឹកឡើងនិមន្តឆាន់ ។

បើបានវត្ថុតិចមិនល្មមធ្វើដូច្នោះបាន, ពួកត្រុដិប្រមូលវត្ថុទាំងឡាយ មានអំបោះសូត្រជាដើមទៅប្រគេនព្រះសង្ឃឯវត្ត សូមឲ្យលោកប្រស់ទឹករម្ងាប់ចង្រៃ ។

យើងស្រង់ចំនុកច្រៀងត្រុដិមកចារិកទុកក្នុងទីនេះខ្លះ ដើម្បីបញ្ជាក់ជូនអ្នកប្រវត្តិសាស្ត្រ ដែលត្រូវការសង្កេតស្រាវជ្រាវរកដើមកំណើតល្បែងនេះ ។

ចំនុកច្រៀងត្រុដិនៅខែត្រសៀមរាប ដូចតទៅនេះ:

អ្នកដើមបទថា:

ត្រុដិនេះ អគ្គីត្រុដិអាយ ៗ
ត្រុដិលោកចៅហ្វាយ ប្រើខ្ញុំមកលេង ៗ

អ្នកទទួលថា:

ទណា នាងណា ! ប្រើខ្ញុំមកលេង ៗ

អ្នកដើមបទថា:

ផ្ទះធំចង្ហាក់ ៗ ជណ្ដើរកាំប្រាក់ សមគាត់មានបុណ្យ ៗ

អ្នកទទួលថា:

ទណា នាងណា សាក៏មុំមបង ៗ

អ្នកដើមបទថា.

ទៃ ! វ៉ឺយកុំធោត ៗ ជញ្ជាំងស្លឹកត្នោត គង់មានថ្នាំខ្លាំង ៗ

អ្នកទទួលថា:

ណ៎ានាងណ៎ា ! គង់មានថ្នាំខ្លាំង ។

អ្នកដើមបទថា:

បានមួយផ្ការ៉ី គង់មានកម្លាំង

គាត់មានថ្នាំខ្លាំង មួរដាក់ជើងពាន ។

អ្នកទទួលថា:

អាគៈទីងតារ សាក៉ម៉ុមបង ។

អ្នកដើមបទថា:

ក្របីស្នែងទប់ ស្នែងទុបចង្កា

ក្របីនរណា ចូលហ្វូងយើងហើយ ។

អ្នកទទួលថា:

អាគៈទីងតារ សាក៉ម៉ុមបង ម៉ុមបង ម៉ុមបង ។

។ ល ។ ល ។

ទំនុកច្រៀងត្រដិនៅខែត្រសៀមរាបនៅមានច្រើនយ៉ាងទៀត ដែលស្រង់មកថ្លែងក្នុងទីនេះដោយសង្ខេបទេ ។

ឯទំនុកច្រៀងនៅខែត្របាត់ដំបងក៏មានច្រើនយ៉ាងដូចគ្នា តែស្រង់មកថ្លែងដោយសង្ខេប ដូចតទៅនេះ:

អ្នកដើមបទថា:

ត្រដិនេះ អង្គីត្រដិអាយៗ

ត្រដិលោកចៅហ្វាយ ខែត្របាត់ដំបង

យើងខ្ញុំរាល់គ្នា ព្រួយចិត្តអឺងកង

ពួកតែផ្គរផង គ្មានភ្លៀងឡើយណ៎ា ។

អ្នកទទួល ២ នាក់បន្ទរថា:

យោនៗយោនៗ ទន្សាយលេចកូន
ក្បែរគុម្ពចែនម៉ែន រកគេជួយសែន
លេចស្នែនចង្រ្កឹន ៗ

អ្នកទទួលទាំងអស់គ្នាបន្ទរថា:

អាតៈទីនឆារ អាពាំម៉ុមបន
អំបោះកម្រែន បនដៃកញ្ញារ ៗ

ៗ ល ៗ ល ៗ

តាមធម្មតាអ្នកប្រៀនត្រជិ បើគេត្រូវការប្រៀនចូលឆ្នាំក៏គេប្រៀនតាមទំនុកដែលធ្លាប់ប្រៀនហូរហែដូចពោលមកហើយ, បើគេត្រូវការប្រៀនឈោសនាសានវត្តក៏គេសរសើរបៀនទាន មានទំនុកដូចតទៅនេះ:

អ្នកដើមបទថា:

លោកឪលោកម៉ែ! ខ្ញុំបាទសូមប្រាក់
ជ្រួតមានធុរៈ គិតសាន់វិហារ ៗ

អ្នកទទួលថា:

ទុណាំនានណាំ! គិតសាន់វិហារ ៗ

អ្នកដើមបទថា:

ថ្វាយដល់ព្រះសង្ឃ ដោយចិត្តសទ្ធា
កសាន់វិហារ យកបុណ្យទៅមុខ ៗ

អ្នកទទួលថា:

ទុណាំនានណាំ! អ្នកថៃអាដែន
មែនហើយ!ៗ ៗ

យើងសូមធ្វើការសង្កេតស្រាវជ្រាវរកដើមកំណើតល្បែងត្រុដិ លើអ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រ, ឯចំណែកយើងសន្និដ្ឋានថា ល្បែងត្រុដិទាក់ទងដោយរឿងនិទានមួយក្នុងសាស្ត្រាសុប់ទដែលមានដំណាលថា:

"កាលពីព្រេងនាយ មានទេសទម្នាក់ឈ្មោះ ព្រាន ប៊ុន ប្រពន្ធ
"ឈ្មោះនាង នុម ។ វេលាមួយ ព្រាន ប៊ុន បាញ់បានស្តេចប្រើស
"មួយឈ្មោះនិគ្រោធម្រឹគ មានរោមភ្លឺដូចមាស ស្នែងភ្លឺដូចកែវ ។
"ព្រានប៊ុន យកស្បែកនិងស្នែងប្រើសនោះ ទៅថ្វាយព្រះរាជា ទ្រង់
"ព្រះរាជទានយសសក្តិជាចៅហ្វាយខេត្ត ។"

យើងសន្និដ្ឋានថា ដល់ព្រាន ប៊ុន បានធ្វើជាចៅហ្វាយខេត្តបានបង្កើតល្បែងត្រុដិនេះឡើង បានជាក្នុងថ្លៃល្បែងនេះមានន័យ ២ យ៉ាង គួរឲ្យយើងសង្កេតហើយជឿបានថាប្រាកដជាព្រាន ប៊ុន នោះបង្កើតឡើង គឺព្រោះ :

– ន័យទី ១ ទំនុកច្រៀងត្រុដិទាំងប៉ុន្មាន ទោះនៅខេត្តសៀមរាបក្តី បាត់ដំបងក្តី សុទ្ធតែមានពាក្យមួយបទថា "ត្រុដិនេះ អគ្គីត្រុដិកាយ ត្រុដិលោកចៅហ្វាយ ប្រើខ្ញុំមកលេង" ដូច្នេះជាដរាប;

– ន័យទី ២ ល្បែងត្រុដិតាមតែនៅទីណា ក៏ឥតមានលេងរឿងអ្វីវែងដូចល្ខោនទេ, មានតែលេងធ្វើព្រានព្រៃបាញ់ប្រើសដកយកស្នែងមកលក់ឲ្យអ្នកមើល ។ ឲ្យប្រាក់និងវត្ថុនានាដល់ពួកត្រុដិ ហើយយកអំបោះចងដៃពួកត្រុដិ យករមៀតម្សៅប្រស់ព្រំឲ្យពួកត្រុដិ ហើយពួកត្រុដិច្រៀងឲ្យពរអ្នកមើល ។

មួយទៀត យើងសន្និដ្ឋានថា ល្បែងត្រដិជាល្បែងខ្មែរសុទ្ធ មានដើមកំណើតនៅស្រុកខ្មែរ សម័យអង្គរ ព្រោះមានន័យគួរឲ្យជឿបាន ២ យ៉ាង គឺ

— ន័យទី ១ អ្នកស្រុកសៀមរាបសព្វថ្ងៃនេះនៅប្រកាន់ល្បែងត្រដិណាស់ តែជិតដល់ថ្ងៃចូលឆ្នាំ តែងត្រៀមប្រដាប់លេងសព្វគ្រប់ ដល់ថ្ងៃចូលឆ្នាំតែងចេញលេងតាមភូមិស្រុក, លុះដល់ថ្ងៃឡើងស័កក៏តែងនាំគ្នាទៅលេងថ្វាយឯនគរវត្តជាទំនៀមរាល់ឆ្នាំ;

— ន័យទី ២ ទំនុកច្រៀងត្រដិតាំងពីបុរាណ ទោះនៅខេត្តសៀមរាបក្តី បាត់ដំបងក្តី សុទ្ធតែមានពាក្យមួយបទថា "ត្រដិនេះ អគ្គីត្រដិសាយ ត្រដិលោកទៅហើយ ប្រើខ្ញុំមកលេង" ដូចគ្នាគ្រប់ស្រុក, សូម្បីស្រុកសុរិន្ទដែលតាមឈ្មោះព្រម នៅស្រុកនោះឲ្យការណ៍ថា: ស្រុកសុរិន្ទឯណោះពិតមែនតែបាននៅសៀមយូរហើយ ប៉ុន្តែសព្វថ្ងៃនេះនៅតែមានទំនុកច្រៀងមួយបទជាពាក្យខ្មែរសុទ្ធថា "ត្រដិនេះ អគ្គីត្រដិសាយ ត្រដិលោកទៅហើយ ប្រើខ្ញុំមកលេង" ត្រូវគ្នាបេះបិទនឹងទំនុកមួយបទនៅស្រុកខ្មែរឯនេះដែរ ។

យើងសន្និដ្ឋានថា នៅប្រទេសកម្ពុជាយើងសម័យបុរាណមានល្បែងត្រដិពាសពេញព្រះរាជអាណាចក្រ, តែសព្វថ្ងៃនេះខេត្តឯទៀតៗល្បែងត្រដិសាបសូន្យរូបអស់រលីងទៅហើយ សូម្បីតែឈ្មោះថាល្បែងត្រដិក៏ឥតមានអ្នកណាស្គាល់ផង នៅតែខេត្តសៀមរាបជាទីក្រុងចាស់មួយទេ

មានល្បែងត្រដិរច្រើន, ក្រៅពីនេះ ខែត្របាត់តំបង់មានដែរតែមិនច្រើនដូចសៀមរាប ដែលជាស្រុកកំណើតល្បែងនេះ ។

ដោយល្បែងត្រដិ ជាល្បាំង៍ល្អមួយគួរទស្សនា, យើងយល់ថាប្រទេសខ្មែរគួរតែរក្សាទុកកុំឲ្យបាត់បង់ ហើយគួរតែបង្កើតឡើងវិញនូវល្បែងនេះឲ្យមានគ្រប់ខែត្រនូវទៅទាំងព្រះរាជអាណាចក្រកម្ពុជាផង ប៉ុន្តែពួកអ្នកលេងត្រដិគួរប្រែសម្លៀកបំពាក់ឲ្យល្អសមរម្យឲ្យថ្លៃថ្នូរ ហើយឲ្យសមតាមសម័យបុរាណនឹងបច្ចុប្បន្នផង ដើម្បីញុំាងអារ្យធម៌ខ្មែរឲ្យមានវឌ្ឍនភាពកន្លងលោកតទៅ ។

---

## បំណាច់កើតមកជាមនុស្សត្រៅធ្វើឲ្យវង្សត្រកូលរុងរឿង

៦៦ - អ្នកណាកើតមកមិនបានលើករង្សត្រកូលខ្លួនឲ្យខ្ពស់ដូចទង់ជ័យលើកំពូលដងកើទេ អ្នកនោះកើតមកម្ដងនឹងគេ តើបានប្រយោជន៍អ្វី? បានត្រាន់តែបំផ្លាញវ័យក្មេងនៃមាតាខ្លួនប៉ុណ្ណោះ ។

កន្លងសង្សារវដ្ដដែលប្រព្រឹត្តកន្លងទៅនេះ នរណាមួយស្លាប់ហើយមិនកើតទៀត? ក្នុងលោកនេះ អ្នកណាធ្វើឲ្យកើតសេចក្ដីរុងរឿងក្នុងត្រកូលដោយក្រៃលែង អ្នកនោះលោកពប់ថាកើតមកជាមនុស្សមែនទែន ។

-បញ្ចតន្ត្រៈ

## កំណត់ និង ប្រត្តិការណ៍

### ពិធីអនុសំវច្ឆរៈមហាសន្និបាតលើកទី ១២

### នៃមន្ត្រីសង្ឃសំរាប់ឆ្នាំ ១៩៥៦ នៅមន្ទីរព្រះសទ្ធម្ម

### ក្នុងវត្តព្រះកែវមរកត

របស់ពុទ្ធសាសនបណ្ឌិត្យ

---

ពិធីអនុសំវច្ឆរៈមហាសន្និបាតលើកទី ១២ នៃមន្ត្រីសង្ឃសំរាប់ឆ្នាំ ១៩៥៦ ដូចមានសេចក្ដីរៀបរាប់តទៅនេះ ៖

នៅព្រឹកថ្ងៃទី ១០ មករា វេលាម៉ោង ៧ មានការជួបជុំព្រះសង្ឃនៅមន្ទីរព្រះសទ្ធម្មក្នុងវត្តព្រះកែវមរកត ដែលត្រូវស្វាធ្យាយធម៌ចំរើនសត្តប្បករណ៍ ឧទ្ទិសថ្វាយព្រះរាជកុសលចំពោះព្រះបិតរនៅចេតិយព្រះកែវមរកត ។ នៅម៉ោង ៨ នឹង ១៥ នាទី ឯកឧត្តមប្រធានរដ្ឋសភា, ឯកឧត្តមប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ, គណៈរដ្ឋមន្ត្រី, រដ្ឋលេខាធិការក្រសួងធម្មការ, សមាជិកសភាទាំងពីរ, ឯកឧត្តមចៅហ្វាយក្រុង ព្រមទាំងឥស្សរជនជាពុទ្ធបរិស័ទច្រើនទៀត បានអញ្ជើញទៅរង់ចាំក្រាបថ្វាយបង្គំគាល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នៅមុខព្រះវិហារព្រះកែវមរកត ។

នៅម៉ោង ៨ នឹង ៣០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានស្ដេចយាងចេញពីព្រះបរមរាជវាំង ដោយមានអ្នកកញ្ញា វាំងវរៈ-

វៀនជ័យ , សមាជិកឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រិយ៍ ព្រមទាំងព្រះរាជបរិវារបានហែហមអមព្រះរាជដំណើរផង ។ នៅពេលដែលព្រះនរបតីស្តេចយាងចុះពីព្រះទីនាំងរថយន្ត ឯកឧត្តម ទៀញ-ហ៊ញ រដ្ឋលេខាធិការក្រសួងធម្មការក្រាបថ្វាយបង្គំ ហើយប្រធានសភាទាំងពីរ នឹងឯកឧត្តមនាយករដ្ឋមន្ត្រីក្រាបថ្វាយបង្គំនៅទីនោះដែរ ។ បន្ទាប់មកក្រុមតូរ្យតន្ត្រីព្រះរាជទ្រព្យបន្ទឺបទនគររាជជាទីគោរព ហើយបន្ទឺបទល័លាជូនព្រះរាជដំណើរ ស្តេចយាងចូលទៅកាន់មន្ទីរព្រះសទ្ធម្ម ដែលមានមន្ត្រីសង្ឃទាំងឡាយគង់នៅទីនោះ ។

ក្រោយដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ក្រាបថ្វាយបង្គំព្រះសង្ឃរួចហើយ ព្រះនរបតីទ្រង់មានព្រះរាជឱង្ការទទួលព្រះអំណរប្រាស្រ័យយ៉ាងជិតស្និទ្ធទៅរកមន្ត្រីសង្ឃ ដោយព្រះភក្ត្រញញឹមព្រមទាំងព្រះរាជហឫទ័យ ទ្រង់រីករាយយ៉ាងក្រៃលែង តមកឯកឧត្តម ទៀញ-ហ៊ញ រដ្ឋលេខាធិការក្រសួងធម្មការ អញ្ជើញចាប់ផ្តើមសុន្ទរកថាមានសេចក្តីដូចតទៅនេះ ៖

សូមព្រះតេជះដ៏គល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានទទួលនូវព្រះរាជអំណរដ៏ជ្រាលជ្រៅ ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលបានស្តេចយាង

មកជាព្រះរាជាធិបតី ក្នុងឱកាសពិធីអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទី ១២ សម្រាប់ឆ្នាំមមែនេះ ដោយមនោសញ្ចេតនាដ៏ឧត្តម ។

ក្នុងករៈជាដំបូងនេះ, ទូលព្រះបង្គំជាខ្ញុំសូមព្រះរាជទាន ព្រះបរម-រាជឱកាសល្អងធូលីព្រះបាទ ដើម្បីប្រស្រ័យនឹងព្រះមហាថេរានុត្ថេរៈទាំងឡាយ មានសម្តេចជាប្រធានដែលបាននិមន្តមកកាន់មហាសន្និបាតនេះ ដោយបំណងនឹងទូលដល់ព្រះសង្ឃទាំងឡាយឲ្យបានជ្រាបច្បាស់នូវកិច្ចការសំខាន់ៗ ខាងពុទ្ធចក្រ ដែលជាប់ទាក់ទងនឹងអាណាចក្រក្នុងកាលៈទេសៈនេះ ។

សូមថ្វាយបង្គំសម្តេចព្រមទាំងព្រះថេរានុត្ថេរៈទាំងឡាយគ្រប់ព្រះអង្គ ដោយគោរព ។

ខ្ញុំព្រះករុណាសូមទទួលអំណរគុណដ៏ក្រៃលែង ចំពោះសម្តេចព្រមទាំងព្រះករុណាគ្រប់ព្រះអង្គដែលបានទទួលនិមន្តមកកាន់ព្រះរាជពិធីអនុសំវច្ឆរៈមហាសន្និបាតនេះ ព្រោះការជួបជុំនេះ ទុកជាទស្សនានុត្តរិយៈមួយដ៏ប្រសើរ ដែលជាហេតុញុំាងព្រះករុណាគ្រប់ព្រះអង្គឲ្យបានជ្រាបច្បាស់ នូវកិច្ចការទាំងពួងខាងពុទ្ធចក្រ ដែលទាក់ទងនឹងអាណាចក្រ ។

សម្តេច !

ព្រះករុណាគ្រប់ព្រះអង្គ !

ប្រទេសកម្ពុជា ដែលមានព្រះពុទ្ធសាសនាប្រតិស្ឋាននៅនេះ ទុកជាភ័ព្វមួយប្រសើរផុត ព្រោះព្រះពុទ្ធបរមគ្រូទ្រង់ទូន្មានសត្វលោកឲ្យដើរត្រង់ទៅរកសេចក្តីស្ងប់ស្ងាត់ គឺសន្តិភាព ដែលមនុស្សក្នុងសាកលនិយម

ពេញចិត្តគ្រប់គ្នា ព្រោះព្រះអង្គទ្រង់ប្រដៅសត្វ ទាញយកកម្មផល ដែលសត្វធ្វើល្អអាក្រក់មកជាគោល ដូចព្រះករុណាគ្រប់ព្រះអង្គជ្រាបស្រាប់ហើយ ។ ខ្ញុំព្រះករុណាមានសេចក្តីសង្ឃឹមយ៉ាងមាំលើព្រះសង្ឃ ដែលជាសិស្សផ្ទាល់នៃព្រះពុទ្ធផងគ្រហស្ថ នឹងប្រកាន់យកសេចក្តីប្រតិបត្តិខាងសន្តិភាព តាមគម្រោយនៃព្រះពុទ្ធដែលព្រះអង្គបានត្រាយទុកឲ្យដើរជាប្រាកដ ។

ដោយអាស្រ័យហេតុនេះហើយ បានជាព្រះពុទ្ធសាសនាមានអាយុឋិតនៅគង់សាកលលោក ដរាបមកដល់សព្វថ្ងៃនេះ ហើយផ្សាយឥទ្ធានុភាពរីកសាយពេញសាកលលោកទាំងមូលរហូតដល់ជនជាតិអឺរ៉ុបទៀត ដូចជាជាតិបារាំង, អង់គ្លេស, អាមេរិកាំង, អូស្ត្រាលីជាដើម គេនិយមជឿតាមកាន់តែច្រើនឡើងហើយ ដោយគេយល់ថា ព្រះពុទ្ធសាសនា ជាសាសនាធ្វើមនុស្សឲ្យស្ងប់ស្ងាត់ ប្រាសចាកការសង្កត់សង្កិនបៀតបៀនគ្នាទៅវិញទៅមក ដូចព្រះករុណាគ្រប់ព្រះអង្គជ្រាបស្រាប់ហើយ ។

លំដាប់តទៅនេះ ខ្ញុំព្រះករុណាសូមពិតទូលព្រះតេជព្រះគុណគ្រប់ព្រះអង្គ ឲ្យបានជ្រាបច្បាស់អំពីល្បឿននៃការសិក្សាប៉ែកខាងព្រះពុទ្ធសាសនា ដូចមានសេចក្តីតទៅនេះ ៖

១ — **អំពីសាលាបាលីរង:** សាលាបាលីរងគ្រប់ខេត្តនឹងក្រុង មានចំនួន ៣៥៧ សាលា ឯសិស្សនៃសាលានេះមានចំនួន ៤.៤៧៥ រូប ។ ឥឡូវនេះ ក្រសួងធម្មការបានបង្កើតការសិក្សាគរុកោសល្យ សម្រាប់អប់រំពួកអាចារ្យបង្រៀនសាលាបាលីរងទាំងអស់ចំនួន ៣០០ រូប ដើម្បីញ៉ាំង

ការសិក្សានៅសាលានេះ ឲ្យមានរបៀបរៀបផែនល្អតាមប្រកាសក្រសួងធម្មការលេខ ៤.៥២៣ ចុះថ្ងៃ ២៣ តុលា ១៩៥៥ ។

២– អំពីពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត: ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ទ្រង់សព្វព្រះរាជហឫទ័យ ព្រះបរមរាជានុញ្ញាតឲ្យកែប្រែសាលាបាលីជាន់ខ្ពស់ជាគ្រឹះស្ថានមធ្យមសិក្សា ហើយផ្លាស់នាមបញ្ញត្តិនៃសាលានេះជា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត វិញ តាមសេចក្តីក្រាបបង្គំទូលស្នើនៃក្រសួងធម្មការ ។ សព្វថ្ងៃនេះកំពុងរិះរកមធ្យោបាយបង្កើតគ្រឹះស្ថានមធ្យមសិក្សាឲ្យបានចំនួន ៥ កន្លែងទៀត នៅទីប្រជុំជនខេត្តនានា ដើម្បីអនុគ្រោះដល់សិស្សដែលប្រឡងជាប់សាលាបាលីរង ហើយ គ្មានកន្លែងសម្រាប់រៀនបន្តវិជ្ជាទៅទៀត ព្រោះគ្រឹះស្ថានមធ្យមសិក្សាបច្ចុប្បន្ននេះ ទទួលបន្ទុកសិស្សឲ្យចូលរៀនក្នុងមួយឆ្នាំ ៗ បានត្រឹមតែ ១៥០ រូបប៉ុណ្ណោះ ហើយសិស្សដែលប្រឡងជាប់សាលាបាលីរងក្នុងមួយឆ្នាំ ៗ មានចំនួនដល់ទៅ ២ ពាន់ជាយរូប, ឃើញថាមិនមានតុល្យភាពសោះ ។

៣– អំពីមហាវិទ្យាល័យ: កាលក្នុងឆ្នាំ ១៩៥៥ គហបតី ប េ - យាន ពាណិជនៅភ្នំពេញ បានធ្វើពិធីសម្ពោធវេរប្រគល់ជូនព្រះរាជរដ្ឋាភិបាល នូវគ្រឹះស្ថាន ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ១ ខ្នងមានថ្នាក់ ៦ ។ គ្រឹះស្ថាននេះ គហបតី ប េ - យាន បានកសាងចំណាយធនធានផ្ទាល់ខ្លួន សាងឧទ្ទិសចំពោះព្រះពុទ្ធសាសនា ដោយមាន

សម្តេចព្រះឧបយុវរាជ កាលព្រះអង្គបិតនៅគង់សិរីរាជសម្បត្តិនៅឡើយ ទ្រង់មានព្រះរាជបញ្ជាឲ្យរាជរដ្ឋាភិបាលចំណាយដីនេះ សម្រាប់សង់មហាវិទ្យាល័យ បានជាគណៈកម្មការបានសម្រេចសូមព្រះរាជានុញ្ញាតព្រះបរមនាមព្រះអង្គដាក់ថា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។ មិនតែប៉ុណ្ណោះសោត ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ បរិច្ចាគនូវព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ១ សែនរៀលទៀត ក្នុងការកសាងសាលានេះ ។

តមក, ព្រះអង្គទ្រង់ប្រោសព្រះរាជទានបន្ថែមនូវប្រាក់អំណោយ ១ លាន ៥ សែនរៀល ដើម្បីកសាងនូវគ្រឹះស្ថានមហាវិទ្យាល័យ ១ ខ្នងទៀត ដែលកំពុងតែចាត់ការធ្វើសព្វថ្ងៃនេះ ។ មួយវិញទៀត មូលនិធិអាស៊ីបានសុំចូលជាបច្ច័យក្នុងការកសាងគ្រឹះស្ថាននេះផង ។ ឯការសិក្សានៅមហាវិទ្យាល័យនេះ ប្រហែលជានឹងបានបើកបង្រៀនក្នុងរវាងឆ្នាំ ១៩៥៧ ឬ ១៩៥៨ ព្រោះក្បួនច្បាប់សម្រាប់បង្រៀននៅមហាវិទ្យា-ល័យ ក៏នៅមិនទាន់មាននៅឡើយផង ។

ដោយហេតុនេះហើយ បានជាព្រះរាជរដ្ឋាភិបាល បានចាត់ព្រះតេជព្រះគុណព្រះ ញាណវង្ស ហួត-តាត ជាអគ្គាធិការ នៃក្រុមអធិការដ្ឋានទីង ជាក្រុមអភិបាលនៃគ្រឹះស្ថានសិក្សាបាលីខាងគណៈមហានិកាយ ឲ្យនិមន្តទៅកាន់ប្រទេសថៃចំនួន ២៩ ថ្ងៃ ពីថ្ងៃទី ៧ ធ្នូ ១៩៥៥ ដោយមានលោក យឹម-វ៉ែន ជាទីប្រឹក្សាបច្ចេកទេសនិងលេខាធិការម្នាក់ ទៅអមជាមួយផង ដើម្បីពិនិត្យមើលការសិក្សាខាងផ្លូវព្រះពុទ្ធសាសនាក្នុងប្រទេសនេះ ។

៤– អភិសាលាធម្មវិន័យៈ សាលានេះ កើតឡើងដោយព្រះរាជក្រឹត្យលេខ ២១៤ ចុះថ្ងៃ ២៨ សីហា ១៩៥០ មានគុណានុភាពអាចញ៉ាំងសេចក្ដីប្រតិបត្តិនៃពុទ្ធសាសនិក ឲ្យមានបែបតែមួយ ដើម្បីកំចាត់បង់នូវការទាស់ទែងខ្វែងគំនិតគ្នាចំពោះធម៌វិន័យ ដើម្បីញ៉ាំងព្រះពុទ្ធ-សាសនា ឲ្យមានពន្លឺរស្មីរុងរឿងទៅអនាគតជន ។

ព្រះករុណា គ្រប់ព្រះអង្គ ! ការសិក្សានៅប្រទេសកម្ពុជា ចែកជា ២ ប្រភេទ គឺប្រភេទទី១ បានដល់ផ្លូវលោក គឺការសិក្សាខាងក្រសួងសិក្សាធិការ, ខាងផ្លូវធម៌បានដល់សាលាបាលីនិងសាលាធម្មវិន័យ ។ ការសិក្សាទាំង ២ ប្រភេទនេះមានគុណានុភាពអាចកំចាត់បង់ នូវសេចក្ដីល្ងង់ខ្លៅដែលដេកកប់នៅក្នុងសន្ដាន នៃប្រជាជនគ្រប់រូប ឬជាអលង្ការសម្រាប់តាក់តែងមនុស្សឲ្យទៅជាមនុស្សពេញលេញ ជាអ្នកមានសមត្ថភាពបរិបូណ៌គ្រប់ការ ដើម្បីឲ្យបុគ្គលមានគុណធម៌ដ៏ល្អ ឲ្យដឹងខ្លួនច្បាស់ក្នុងការគ្រប់គ្រងជីវិត ទាំងដើម្បីត្រៀមឲ្យជាពលរដ្ឋដ៏ល្អ ជាកិច្ចសម្រាប់អប់រំចិត្តយុវជន ឲ្យចេះដឹងជ្រើសរើសសេចក្ដីល្អទាំងពួង ។

ហេតុនេះ ការសិក្សា គួរចាត់ថាជាកិច្ចមួយ ប្រចាំជីវិតមនុស្សគ្រប់រូប មិនថាស្ដ្រីបុរសព្រះសង្ឃ ឬគ្រហស្ថឡើយ ។

ឯការសិក្សានោះ ត្រូវប្រកបដោយអង្គ ៣ គឺ:

១– បរិយាសិក្សា បានដល់ការសិក្សាអប់រំផ្លូវកាយនិងផ្លូវចិត្ត ឲ្យបានទៅជាអ្នកដឹងខុសត្រូវ តាំងនៅក្នុងសីលធម៌ដ៏ល្អ ដើម្បីជា

ឧបករណ៍ដឹកនាំឲ្យកើតសេចក្ដីសុខសេចក្ដីចំរើនដល់ខ្លួន ដល់ក្រុមគ្រួសារឬដល់សង្គម ។

២— ពុទ្ធិសិក្សា បានដល់ការសិក្សាផ្លូវវិទ្យា គឺចំណេះវិជ្ជាគ្រប់យ៉ាងដើម្បីឲ្យកើតសេចក្ដីចេះដឹងឈ្លាសវៃ ក្នុងការប្រកបជីវកម្មគ្រប់យ៉ាងដូចជាបណ្ដើរវិជ្ជាផ្សេងៗ អក្សរសាស្ត្រ ភាសាសាស្ត្រ រហូតដល់វិទ្យាសាស្ត្រជាបំផុត ។

៣— ពលសិក្សា បានដល់ការសិក្សាខាងផ្លូវកាយបរិហារឲ្យមានពងកាយមាំមួនដើម្បីការពារពោគាព្យាធិទាំងពួង មានកំលាំងរឹងប៉ឹងល្អ ។

អង្គនៃការសិក្សាទាំង ៣ ប្រការនេះ ជាគុណធម៌ដ៏ល្អបរិសុទ្ធអារ្យប្រទេសទាំងឡាយ និយមប្រកាន់យកថាជាគុណវិសេសរបស់ប្រទេសជាតិគេគ្រប់គ្នា ។

ដូច្នេះ សូមព្រះករុណាគ្រប់ព្រះអង្គជាមន្ត្រីសង្ឃ ជួយឧបត្ថម្ភពុទ្ធសាសនា ដោយប្រើមធ្យោបាយរំលឹកដាស់តឿន ដល់ព្រះសង្ឃគ្រប់វត្ត ឲ្យខំយកព្រះទ័យទុកដាក់ខំរៀនសូត្រធម៌វិន័យបើនព្រះអង្គឡើង ព្រោះធម្មវិន័យនេះហើយ ជាឫសគល់ព្រះពុទ្ធសាសនា ។

ក្នុងឱកាសនេះ, ទូល ព្រះបង្គំជាខ្ញុំសូមឧទ្ទិសព្រះរាជកុសលថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រមទាំងសម្ដេចព្រះមហាក្សត្រិយានី សូមព្រះអង្គស្ថិតនៅជាសុខក្នុងសិរីរាជសម្បត្តិ អស់

កាលជាអង្វែងតទៅ, ១ ទៀត ទូលព្រះបង្គំជាខ្ញុំ សូមឧទ្ទិសព្រះរាជកុសលនេះ ថ្វាយសម្តេចព្រះឧបយុវរាជព្រមទាំងព្រះរាជវង្សានុវង្ស សូមទ្រង់ប្រកបដោយសេចក្តីសុខចំរើនគ្រប់ប្រការ ។

សូមព្រះពុទ្ធសាសនារុងរឿងចំរើនឡើងជាលំដាប់ ។

សូមឲ្យប្រជាជននឹងអស់លោកជាមន្ត្រី គ្រប់តំណែង តាំងនៅក្នុងសាមគ្គីធម៌ពួតដៃគ្នាកសាងមាតុប្រទេស ជាមួយសម្តេចព្រះឧបយុវរាជ ដែលព្រះអង្គជាបិតានៃឯករាជ្យបរិបូណ៌ ចាប់ពីពេលនេះតទៅ ។

នៅពេលដែលចប់នូវសេចក្តីថ្លែងសុន្ទរកថានៃឯកឧត្តមរដ្ឋលេខាធិការក្រសួងធម្មការហើយ ព្រះតេជព្រះគុណព្រះវន្ទរ័ត្ន ហ៊ុវ - ទួត មេគណវត្តពោធិវាលខែត្របាត់ដំបង និមន្តថ្លែងសុន្ទរកថាឆ្លើយតបវិញ មានសេចក្តីដូចតទៅនេះ ៖

## សុន្ទរកថា

សូមថ្វាយព្រះពរបរមបពិត្រព្រះករុណាជាអម្ចាស់ជីវិត

សូមទ្រង់ជ្រាប ។

អាត្មាភាព តាងនាមមន្ត្រីសង្ឃគ្រប់តំណែង ដែលបាននិមន្តមកកាន់អនុសំវច្ឆរៈមហាសន្និបាតជាគំរប់ទី ១២ នេះ សូមព្រះរាជទានព្រះបរមរាជវរោកាសថ្វាយព្រះរាជយោបល់ ដោយសេចក្តីគោរពដ៏ក្រៃលែង ចំពោះព្រះពុទ្ធសាសនា ចំពោះព្រះករុណាជាអម្ចាស់ជីវិត ដោយសេចក្តីសន្ទើបថ្វាយដូចតទៅនេះ ៖

ពិធីបុណ្យអនុសំវច្ឆរៈមហាសន្និបាត ជាពិធីបុណ្យដែលរាជរដ្ឋា-

គិបាលបានរៀបចំធ្វើរៀងរាល់ឆ្នាំ ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណា ជាអម្ចាស់ជីវិតតាំងពីព្រះអង្គ ។ ពិធីបុណ្យនេះ មានឧត្តមប្រយោជន៍ យ៉ាងសំខាន់ក្នុងការប្រស្រ័យទាក់ទងគ្នា រវាងពុទ្ធចក្រនឹងអាណាចក្រ ហើយជាពិសេសបំផុតក្នុងការលាតត្រដាង ឲ្យព្រះសង្ឃទាំងឡាយព្រម ទាំងពុទ្ធបរិសទ្យ ក្នុងព្រះរាជអាណាចក្រ បានឃើញជាក់ស្តែង នូវ សេចក្តីចំរុងចំរើននៃព្រះពុទ្ធសាសនា នូវគុណានុភាពនៃព្រះពុទ្ធសាសនា ដែលរីកសាយឡើងជាលំដាប់ ដោយសារព្រះរាជហឫទ័យដ៏បរិសុទ្ធនៃ ព្រះករុណាជាអម្ចាស់ជីវិត ជាឯកអគ្គពុទ្ធសាសនូបត្ថម្ភក ។ សេចក្តីដូច មានក្នុងសុន្ទរកថា ដែលឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ បានក្រាបបង្គំ ទូលថ្វាយក្នុងពេលអម្បាញ់មិញនេះ ។

អាត្មាភាពទាំងឡាយ សូមថ្លែងនូវសេចក្តីគោរពដ៏លើសលុបចំពោះ ព្រះពុទ្ធសាសនា និងសូមថ្លែងនូវសេចក្តីកតញ្ញូដ៏ស្វាមិភក្តិចំពោះព្រះ ករុណាទិគុណនៃព្រះករុណាជាអម្ចាស់ជីវិត ចំពោះសម្តេចព្រះមហា-ក្សត្រិយានី ព្រមទាំងសម្តេចព្រះឧបយុវរាជ ជាអតីតព្រះមហាក្សត្រ នៃប្រទេសកម្ពុជា ដោយបូជាជីវិតប្រកាន់ធ្វើតាមព្រះពុទ្ធសាសនា និង ព្រះរាជយោបល់នៃព្រះករុណាជាអម្ចាស់ជីវិតគ្រប់ព្រះអង្គជាដរាប ។

នៅទីបញ្ចប់នេះ គុណនៃសីលធម៌ណា ដែលអាត្មាភាពគ្រប់រូប ព្រមទាំងសិស្សានុសិស្ស និងពុទ្ធបរិស័ទទាំងឡាយជាចំណុះវត្តនីមួយៗ ក្នុងកម្ពុជរដ្ឋទាំងមូល បានប្រព្រឹត្តប្រតិបត្តិ ដ៏ត្រឹមត្រូវតាមលំអានព្រះ ពុទ្ធសាសនា សូមគុណសីលធម៌ដ៏ប្រសើរទាំងនោះ ជួយអភិបាលរក្សា

ព្រះករុណាជាអម្ចាស់ជីវិត សម្ដេចព្រះមហាក្សត្រិយានីព្រមទាំងសម្ដេចព្រះឧបយុវរាជ និងព្រះរាជវង្សានុវង្សគ្រប់អគ្គសេវកាមាត្យមុខមន្ត្រីគ្រប់តំណែង សូមមានសិរីសួស្ដីជ័យជំនះជា ៗ ឡារិក ៈ សូមឲ្យប្រទេសកម្ពុជាដែលបានឯករាជ្យបរិបូណ៌ដែលបានចូលធ្វើជាសមាជិកពេញទី នៃអង្គការសហប្រជាជាតិហើយនេះ បានប្រកបដោយសន្តិភាព និងអាយុកាលដរាបដល់កល្បាវសាន ។

ក្រោយដែលចប់សេចក្ដីសូត្រគាថានៃព្រះតេជព្រះគុណព្រះវន្ន័តមេគណខេត្តបាត់ដំបងហើយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់មានព្រះរាជឧត្ដារចំពោះមន្ត្រីសង្ឃទាំងអស់ថា ៖

ខ្ញុំករុណាមានសេចក្ដីត្រេកអរយ៉ាងក្រៃលែង ដែលនៅឱកាសនេះជាឱកាសមួយដ៏កម្រណាស់ ដែលនាំឲ្យខ្ញុំករុណាបានជួបព្រះភក្ត្រថ្វាយបង្គំព្រះករុណាគ្រប់ព្រះអង្គជាមន្ត្រីសង្ឃនៅពេលនេះ ខ្ញុំករុណាសូមផ្ញើនូវការបីបាច់ថែរក្សាព្រះពុទ្ធសាសនាឲ្យបានរៀបរយល្អ ឲ្យសមតាមឋានៈប្រទេសឯករាជ្យ ហើយសូមផ្ដាំចំពោះពលរដ្ឋជាពុទ្ធបរិស័ទ្យ សូមឲ្យជួយជុសជាត់ព្រះពុទ្ធសាសនា ឲ្យរឹតតែមានរស្មីរុងរឿងចំរើនតទៅមុខទៀត ខ្ញុំករុណាសូមប្រគេនពរសព្ទសាធុការចំពោះព្រះករុណាគ្រប់ព្រះអង្គ សូមឲ្យបានជួបនូវសេចក្ដីសុខចំរើនអស់កាលតរៀងទៅ ។

នៅពេលដែលចប់ព្រះរាជឧត្ដារនៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូងហើយ ព្រះសង្ឃទាំងអស់ក៏និមន្តសូត្រជ្ឈាយន៍ធម៌ជយន្តោប្រសិទ្ធ-ពរ ថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងឥស្សរជនទាំងអស់ ។

ក្នុងពេលដដែលនោះ ព្រះមហាក្សត្រិយ៍ទ្រង់សព្វព្រះរាជហឫទ័យ ទ្រង់ព្រះរាជសណ្ដាប់ធម៌ព្រះសង្ឃនិមន្តមកពីលង្កាទ្វីប ព្រះនរបតីទ្រង់និមន្តព្រះសង្ឃទាំង ៣ ព្រះអង្គស្វាធ្យាយទ៍ជាព្រះសណ្ដាប់ដែលមានអក្ខរសខាងភាសាបាលី ដូចជាព្រះសង្ឃប្រទេសកម្ពុជាយើងដែរ ។

នៅម៉ោង ៩ និង ៣០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងថ្វាយបង្គំលាព្រះសង្ឃ ស្ដេចយាងចូលព្រះបរមរាជវាំងវិញ ដោយមានព្រះរាជបរិពារដែលហែហមអមព្រះអង្គផង ។ ចំណែកឥស្សរជនទាំងអស់ក៏អញ្ជើញទៅកាន់ដំណែងរៀងខ្លួនវិញ ។ នៅម៉ោង ១០ និង ៣០ នាទី ប្រគេនកត្តក្នុងព្រះបរមនាម នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងដល់ព្រះសង្ឃចំពោះមុខរដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងមន្ត្រីក្រសួងធម្មការ-ឧបាសកឧបាសិកានៅមហាកុដិវត្តឧណ្ណាលោម ។

---

## កូនបែបណាសូម្បីអ្នកធំក៏គោរពដែរ?

៣០– កូនណា សូម្បីអ្នកធំទាំងឡាយក៏គោរពបូជាដែរ អ្នកប្រាជ្ញលោករំលឹកទុកថា មាតាដែលពផ្ទៃនៃកូននោះ ជាមាតាដែលមានគុណធ្ងន់ បុគ្គលគួរគោរពកន្លងមិនបាន ។

— បញ្ចតន្ត្រៈ —